# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៧ លេខ ៨ ខែ សីហា

ព.ស. ២៥០៧ គ.ស. ១៩៦៥

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

១- អំពីគិហិវត្ត ព្រះមុនីកោសល សួរ ហាយ រៀបរៀង . . . . . . ៧៦៨

២ អប្បមាទធម៌ សហជីវិន ទ្រី-ញ-ភីញ រៀបរៀង . . . . . . ៧៧៥

៣- ប្រស្នាព្រះឥន្ទ លោក ប៊ូ ប៊ូ រៀបរៀង . . . . . . . ៧៧៩

*ផ្នែកអក្សរសាស្ត្រ*

៤- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . ៧៩៦

៥- រឿងសាមកុក អ្នកទកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង(ត) . . . ៨០០

៦- ប្រវត្តិវត្តពោធិប្រជុំជន លោក ចាប-ពិន រៀបរៀង . . . . . ៨១២

៧- ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង . . . . ៨១៦

៨- សិលាចារឹកត្រពាំងរុន លោក ឧ. គាម ស្រាវជ្រាវ . . . . . ៨៣២

៩- ព្រះរាជនិពន្ធកាមកេរ្តិ៍ លោក ឧ. គាម ស្រាវជ្រាវ (ត) . . . . . ៨៤៧

១០- ពិធីសម្ពោធបណ្ណាល័យវត្តសារវ័នតេជោ ព្រះវិន័យធរ អ៊ុម-ស៊ុម រៀបរៀង . . ៨៥៩

១១- ព្រះរាជដំណើរនៃសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ស្ដេចយាងទៅកាន់វត្តប៉ាត់ដំបង
លោក ឌីក-គាម រៀបរៀង . . . . . . . ៨៧០

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អពៅ,
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ច.ព.

# អំពីគិហិវត្ត

(ក)

*ព្រះមុនីកោសល សូរ-ហាយ*

អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក រៀបរៀង

## កិច្ចវត្តនៃសមណព្រាហ្មណ៍និងកុលបុត្ត

សមណៈ លោកសំដៅយកបព្វជិតអ្នកស្ងប់រម្ងាប់កិលេស ជាអ្នកមិនបណ្តោយឲ្យកិលេសគ្របសង្កត់ញាំញីបាន ។ ព្រាហ្មណ៍ ក៏លោកសំដៅយកអ្នកប្រព្រឹត្តធម៌ល្អ បន្សាត់បង់នូវកិលេស ពុំមែនសំដៅយកព្រាហ្មណ៍ដោយជាតិនោះទេ ។

សមណព្រាហ្មណ៍ទុកជាទិសខាងលើ ដែលកុលបុត្តគប្បីទំនុកបម្រុង ដោយហេតុ ៥ យ៉ាង

១- មេត្តាកាយកម្ម កាយកម្មប្រកបដោយមេត្តា

២- មេត្តាវចីកម្ម វចីកម្មប្រកបដោយមេត្តា

៣- មេត្តាមនោកម្ម  មនោកម្មប្រកបដោយមេត្តា

៤- អនាវដទ្វារតា  ភាពជាអ្នកមិនបិទទ្វារផ្ទះ

៥- អាមិសានុប្បទានៈ  ការផ្តល់នូវអាមិសទាន ។

## អធិប្បាយពង្រីកសេចក្តី

១- មេត្តាកាយកម្ម  កាយកម្មប្រកបដោយមេត្តា ។

ពាក្យថា កាយកម្មប្រកបដោយមេត្តា បានដល់ការធ្វើនូវអំពើដោយកាយ ប្រកបដោយចិត្តស្រឡាញ់ស្និទ្ធស្នាលចំពោះសីលធម៌របស់សមណ-ព្រាហ្មណ៍ ដូចយ៉ាងការជួយធ្វើកិច្ចការរបស់សង្ឃដោយកម្លាំងកាយមានប្រភេទដោយសង្ខេបតទៅនេះ គឺ

១) ការជួយធ្វើកិច្ចធុរៈរបស់សង្ឃ,

២) ជួយការពារអន្តរាយផ្សេង ១ មានជម្ងឺតម្កាត់ជាដើម ឬកិច្ចការណាមួយដែលជានវកម្ម,

៣) ធ្វើបដិសណ្ឋារៈចំពោះសង្ឃដោយការគោរពថ្វាយបង្គំជាដើម ។

៤- មេត្តាវចីកម្ម  វចីកម្មប្រកបដោយមេត្តា ។

ពាក្យថា វចីកម្ម បានដល់ការធ្វើនូវអំពើដោយវាចា ដូចយ៉ាងការជួយរំលឹកដាស់តឿនចំពោះសមណៈ ដែលមានសេចក្តីភ្លាំងភ្លាត់ ឬហេតុការណ៍ណាមួយក្នុងផ្លូវលោកឬក្នុងផ្លូវធម៌ ដែលសមណៈពុំទាន់បានដឹង គួរគុណ-បុគ្គលនិយាយប្រាប់ឲ្យបានដឹង ។ ការនិយាយកិច្ចការក្នុងផ្លូវលោក ឬក្នុងផ្លូវ

ធម៌ គួរនិយាយប្រកបដោយមេត្តា ឲ្យមានសភាពពីរោះទន់ភ្លន់ មិនគួរប្រើពាក្យរឹងរូសគ្រោតគ្រាតចំពោះសមណព្រាហ្មណ៍ ។

៣. មេត្តាមនោកម្ម  មនោកម្មប្រកបដោយមេត្តា ។

ពាក្យថា មនោកម្ម បានដល់អំពើរបស់ចិត្ត ដូចយ៉ាងចិត្តរបស់កុលបុត្តជាគ្រហស្ថ គួរធ្វើចិត្តល្អជាកុសលជាបុណ្យចំពោះសមណព្រាហ្មណ៍ ។ ការធ្វើអ្វីដោយកាយក្តី ដោយវាចាក្តី ដែលជាកិច្ចការរបស់សមណព្រាហ្មណ៍ គួរធ្វើចិត្តឲ្យល្អបរិសុទ្ធ ប្រកបដោយមេត្តាករុណាចំពោះសង្ឃ ដោយចិត្តគិតថា លោកទាំងនេះហើយ ជាអ្នកប្រព្រឹត្តល្អ គោរពព្រះពុទ្ធសាសនាផ្ទាល់ខ្លួន ពុំមែនជាសឹកសត្រូវរបស់អ្នកស្រុកឡើយ ។

៤. អនាវដទ្វារតា  ភាពជាអ្នកមិនបិទទ្វារផ្ទះ ។

ពាក្យថា មិនបិទទ្វារផ្ទះ បានដល់ការបវារណាបើកឱកាសឲ្យសមណព្រាហ្មណ៍ ទទួលត្រេកអរចំពោះបច្ច័យ៤ គឺ ចីវរប្បច្ច័យ ១ បិណ្ឌបាតប្បច្ច័យ ១ សេនាសនប្បច្ច័យ ១ គិលានភេសជ្ជប្បច្ច័យ១ ។ បវារណាចំពោះសមណព្រាហ្មណ៍ថា បើលោកម្ចាស់ត្រូវការបច្ច័យទាំង៤ បច្ច័យណាមួយ យើងខ្ញុំនឹងចាត់ចែងតាមសេចក្តីត្រូវការរបស់លោកម្ចាស់ ។

៥. អាមិសានុប្បទានៈ  ការផ្តល់នូវអាមិសទាន ។

ពាក្យថា អាមិសទាន បានដល់គ្រឿងឧបភោគនិងបរិភោគគ្រប់

យ៉ាងដែលសមណព្រាហ្មណ៍អាចប្រើប្រាស់បាន ដែលគ្រហស្ថគប្បីធ្វើដោយបានបវារណាមុនក្តី មិនដែលបានបវារណាក្តី ជាការធ្វើអាមិសទានដោយចិត្តជ្រះថ្លាចំពោះសមណព្រាហ្មណ៍ ឬជាកិច្ចទក្ខិណាទុប្បទានចំពោះលោកអ្នកមានគុណមានមាតាបិតាជាដើម ដោយយកសមណព្រាហ្មណ៍ជាបដិគ្គាហកបុគ្គល (បុគ្គលអ្នកទទួលទាន) ។ មួយទៀត សមណព្រាហ្មណ៍ ដែលត្រូវការដោយសម្ភារៈផ្សេងៗ មានគម្ពីរដីកាឬសៀវភៅច្បាប់ណាមួយសម្រាប់សិក្សារៀនសូត្រ គួរគ្រហស្ថជួយផ្តល់សម្ភារៈទាំងនោះចំពោះសមណព្រាហ្មណ៍ដោយចិត្តជ្រះថ្លា ។

សមណព្រាហ្មណ៍ កាលបើបានទទួលសេចក្តីទំនុកបម្រុងអំពីកុលបុត្តដូច្នេះហើយ គប្បីអនុគ្រោះកុលបុត្តវិញ ដោយហេតុ៦យ៉ាង

១- បាបនិវារណា: ការហាមឃាត់កុលបុត្តពាក់អំពើអាក្រក់,

២- កល្យាណនិវេសនៈ ញ៉ាំងកុលបុត្តឲ្យតាំងនៅក្នុងអំពើល្អ,

៣- កល្យាណមនសា អនុកម្បនៈ អនុគ្រោះកុលបុត្តដោយចិត្តដ៏ល្អ,

៤- អស្សុតសាវនៈ ញ៉ាំងកុលបុត្តឲ្យស្តាប់ នូវពាក្យដែលមិនធ្លាប់ស្តាប់,

៥- សុតបរិយោទបនៈ បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ,

៦- សគ្គមគ្គាចិក្ខនៈ ប្រាប់ផ្លូវឋានសួគ៌ដល់កុលបុត្ត, ។

# អធិប្បាយពង្រីកសេចក្តី

១- បាបនិវារណា: ការហាមឃាត់កុលបុត្តចាកអំពើអាក្រក់ ។

ពាក្យថា អំពើអាក្រក់ បានដល់ការប្រព្រឹត្តទុច្ចរិតទាំង៣យ៉ាងមានកាយទុច្ចរិតជាដើម ទុច្ចរិតណាមួយ ។ ការប្រព្រឹត្តទុច្ចរិតក្រៅអំពីទុច្ចរិត ៣យ៉ាង ដូចជាការប្រព្រឹត្តខ្លួនក្នុងអបាយមុខ៦ យ៉ាងមានល្បែងស៊ីសងជាដើម ទាំងនេះហៅថាអំពើអាក្រក់ ។ មួយទៀត អំពើណាមួយដែលសា-សនាបញ្ញត្តហាមប្រាម ឬច្បាប់ខាងអាណាចក្របញ្ញត្ត បុគ្គលដែលហ៊ានប្រព្រឹត្តបំពានបំពារលើបញ្ញត្តិទាំងនោះ ហៅថាបុគ្គលប្រព្រឹត្តអំពើអាក្រក់ ។

២- កល្យាណនិវេសនៈ: ញ៉ាំងកុលបុត្តឲ្យតាំងនៅក្នុងអំពើល្អ ។

ពាក្យថា អំពើល្អ បានដល់សុចរិត ៣ យ៉ាងមានកាយសុចរិតជាដើម ។ ការស្គាល់បុណ្យបាបគុណទោស ស្គាល់ហេតុមានប្រយោជន៍និងឥតប្រយោជន៍របស់ជាតិសាសនា ហើយតម្កល់ខ្លួនក្នុងបុណ្យ ក្នុងគុណធម៌ លះបាប វៀរចាកទោស ទាំងនេះហៅថាអំពើល្អ មួយទៀត ការប្រព្រឹត្តខ្លួនឲ្យប្រកបដោយទិដ្ឋធម្មិកត្ថៈ (ប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាង) មានឧដ្ឋានសម្បទាជាដើម នេះហៅថាអំពើល្អ ។

៣- កល្យាណមនសា អនុកម្បនៈ: អនុគ្រោះកុលបុត្តដោយចិត្តដ៏ល្អ ។

ការទំនុកបម្រុងផ្ចុងផ្ដើមកុលបុត្តជាគ្រហស្ថ គឺសមណបព្វជិតគប្បីធ្វើ

ដោយចិត្តមេត្តាករុណា ផ្សាយចំពោះគ្រហស្ថ ដើម្បីចង់ឲ្យគ្រហស្ថកប់ប្រ-សប់នូវពរ ៤ ប្រការ កាលបើសមណបព្វជិតឃើញគ្រហស្ថប្រព្រឹត្តអំពើអាក្រក់ណាមួយ គួរជួយអនុគ្រោះ ដោយការរំលឹកដាស់តឿន ពន្យល់ហេតុផល ដោយឧបាយដ៏ល្អ ដើម្បីឲ្យលះបង់នូវអំពើអាក្រក់នោះចេញ ។

៤- អស្សុតំ សាវេតិ: ញុំាងកុលបុត្តឲ្យស្តាប់ នូវពាក្យដែលមិនធ្លាប់ស្តាប់ ។

ពាក្យនេះ បានដល់រឿងរ៉ាវណាមួយ ជារឿងព្រេងព្រឹទ្ធក្តី ជារឿងទើបនឹងកើតថ្មី ដែលគេមិនទាន់ចេះដឹងក្តី កាលបើសមណបព្វជិតឃើញថារឿងនោះ ជារបស់មានប្រយោជន៍ ដើម្បីជាដំបូន្មាន ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញាស្មារតី គួរសំដែងរឿងនោះឲ្យកុលបុត្តស្តាប់ ទឹងបានចេះដឹងរឿងនោះតទៅ ។ ពាក្យពេចន៍ក្នុងផ្នែកវប្បធម៌អក្សរសាស្ត្រ ដែលកុលបុត្តមិនធ្លាប់ចេះដឹង ឬប្រើប្រាស់និយាយមិនត្រឹមត្រូវតាមរបៀបវប្បធម៌របស់ជាតិ ក៏ត្រូវសមណបព្វជិតសំដែងដោះស្រាយ ពន្យល់ ឲ្យបានចេះដឹងច្បាស់លាស់ឡើង ។

៥- សុតំ បរិយោទបេតិ: បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ ។

ពាក្យថា បំភ្លឺសេចក្តី សំដៅយកការសំដែងរាតពង្រីកសេចក្តីដែលសង្ខេបឲ្យពិស្តារឡើង សេចក្តីដែលជ្រាលជ្រៅល្អិតញាកស្តាប់បានដោយក្រ គួរសមណបព្វជិត វែកញែកអធិប្បាយរំលាយសេចក្តី ដោយទាញ

ទតាហរណ៍ខ្ទុចមា ឲ្យឃើញសេចក្តីកក់ក្តៅ ដើម្បីរីករាយស្តាប់ ឲ្យយល់សេចក្តីនោះតែតែច្បាស់លាស់ឡើង ទាល់តែក្លីច្បាស់ឥតសង្ស័យ ។

៦- សគ្គមគ្គាចិក្ខាន: ប្រាប់ផ្លូវឋានសួគ៌ដល់កុលបុត្ត ។

សេចក្តីនេះ បានដល់ការសំដែងធម៌ប្រាប់មូលហេតុនៃការប្រព្រឹត្តល្អនិងការប្រព្រឹត្តអាក្រក់ ។ ការប្រព្រឹត្តល្អ រមែងនាំសត្វទៅកាន់សុគតិសួគ៌ទេវលោក ការប្រព្រឹត្តអាក្រក់ រមែងនាំសត្វទៅកាន់អបាយភូមិទាំង ៤ គឺ នរក១, ប្រេត១, តិរច្ឆាន១, អសុរកាយ១, អបាយភូមិណាមួយ ។

ពាក្យថា ប្រាប់ផ្លូវឋានសួគ៌ បានដល់ការចង្អុលបង្ហាញនូវបុញ្ញកិរិយាវត្ថុ ៣ យ៉ាង គឺ

១) ទានមយ: កុសលកើតដោយការធ្វើទាន

២) សីលមយ: កុសលកើតដោយការរក្សាសីល

៣) ភាវនាមយ: កុសលកើតដោយការអប់រំ ។

សមណបព្វជិត គួរជាអ្នកខ្សហាំដឹកនាំកុលបុត្តជាគ្រហស្ថ មិនឲ្យមានសេចក្តីប្រមាទ ក្នុងកុសលធម៌គ្រប់យ៉ាង ដើម្បីរៀបចំលាងជម្រះមន្ទិលជីវិតឲ្យបរិសុទ្ធក្នុងបច្ចុប្បន្ន ជាកិច្ចត្រៀមខ្លួនបង្ការទុកឲ្យហើយតាំងអំពីបច្ចុប្បន្ន ដើម្បីឲ្យកាយវាចាចិត្តបរិសុទ្ធ ទើបបានយកសួគ៌គតិសុគតិទេវលោកបាន ។

កិច្ចវត្តនៃសមណព្រាហ្មណ៍និងកុលបុត្ត ចប់តែប៉ុណ្ណេះ ។

# អប្បមាទធម៌

សហជីវិន ទ្រឹញ ភិញ អនុរដ្ឋលេខាធិការក្រសួងធម្មការ រៀបរៀង

នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរត្នត្រ័យ ដោយគោរព

បន្ទាប់ពីបទនមស្ការនេះទៅ សូមលើកយកអប្បមាទធម៌ «សេចក្ដីមិនប្រមាទ» មកពណ៌នា ដើម្បីជាគ្រឿងជួយគប់រំជនជាតិក្នុងពិភពលោក ដែលកំពុងមានសេចក្ដីស្នេហាចំពោះប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍ប្រទេសជាតិ មាតុភូមិ រៀងកល់រូបកល់ជាតិ ។

បពិត្រលោក-អ្នកត្រូវការប្រយោជន៍ទាំងឡាយ

ហេតុដែលនាំឲ្យលើកយក អប្បមាទធម៌ មកពណ៌នាលាតត្រដាង ជូនក្នុងឱកាសនេះដោយយល់ឃើញថា ធម៌នេះជាកំពូលធម៌ទាំងឡាយ ដែលអាចញ៉ាំងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចបាន ។

អប្បមាទធម៌នេះ ចាប់តាំងពីពេលដែលព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងឡើងក្នុងលោកកាលណា ព្រះអង្គតែងទ្រង់សំដែងប្រោសប្រទានសព្វសត្វនិករជាច្រើនលើកច្រើនគ្រា ដរាបទាល់នឹងពេលទៀបទ្រង់ព្រះបរិនិព្វានទៀត ព្រះអង្គក៏ទ្រង់ឈ្វេងយល់ដោយក្រែងសត្វក្នុងពិភពលោកភ្លេចអប្បមាទធម៌នេះ ទ្រង់ធៀតសំដែងផ្ដាំទុកផ្ដាច់ជាចុងក្រោយបំផុត ដូចមានជាប់នៅសព្វថ្ងៃនេះថា:

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ

វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ

ម្នាលភិក្ខុទាំងឡាយ តថាគត ដាស់តឿនអ្នកទាំងអស់គ្នា សង្ខារទាំងឡាយមានការសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ ។

ក៏អប្បមាទធម៌នេះ ពិតជាធម៌ដែលព្រះសម្ពុទ្ធ ទ្រង់ពិចារណាជ្រើសរើសឃើញផ្ទាល់ព្រះអង្គឯងថា គេធម៌ណាអាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចក្នុងបច្ចុប្បន្ន ភពនិងប្រយោជន៍ក្នុងបរលោកដូចជាអប្បមាទធម៌នេះគ្មាន ។ ព្រោះហេតុនោះហើយបានជាព្រះសម្ពុទ្ធ ទ្រង់មានព្រះពុទ្ធដីកាផ្ដាំហើយផ្ដាំទៀតថា ចូរសត្វក្នុងពិភពលោក កុំភ្លេចអប្បមាទធម៌នេះនោះឡើយ ។

ពាក្យថា អប្បមាទធម៌នេះ ជាភាសាបាលី ប្រែចេញជាភាសាខ្មែរ ថា "ការមិនប្រមាទ, សេចក្ដីមិនប្រហែសធ្វេស ។

សេចក្ដីមិនប្រមាទនេះ ចែកជាពីរផ្នែក:

១- មិនប្រមាទក្នុងការលះ ។

២- មិនប្រមាទក្នុងការចំរើន ។

សូមអធិប្បាយពាក្យពង្រីកសេចក្ដីនៃការមិនប្រមាទទាំង ២ ផ្នែក មួយម្ដងដូចតទៅនេះ ។

**១. មិនប្រមាទក្នុងការលះ** បានសេចក្ដីថា អំពើណាៗ ដែលជនជាតិប្រព្រឹត្តទៅហើយ នាំឲ្យខូចខាតផលប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍សាធារណជន អំពើនោះៗ ត្រូវតែលះបង់ចោលដោយដាច់ខាត សូម្បីតែបន្តិចបន្តួចក៏មិនត្រូវប្រថុយប្រព្រឹត្តឬប្រកបឡើយ ។

បើកាលណាជនជាតិមានសេចក្ដីប្រមាទ ដោយនឹកស្មានថាអំពើតិចតួចមិនជាការប៉ុន្មានទេ ហើយនៅតែទទួលប្រព្រឹត្តទៅទៀត ជននោះឯងមុខជានឹងបានទទួលលទ្ធផលជាទុក្ខពុំខានឡើយ ។

**២ មិនប្រមាទក្នុងការចំរើន** បានសេចក្ដីថា អំពើណាៗ ដែលជនជាតិប្រព្រឹត្តទៅហើយ នាំឲ្យផុសកើតផលប្រយោជន៍ និងសេចក្ដីចំរើនរុងរឿងផ្ទាល់ខ្លួន និងសាធារណជន ទោះបីតិចឬច្រើនក៏ដោយ អំពើនោះ ៗ ជនជាតិត្រូវតែមានសេចក្ដីព្យាយាមបន្តសកម្មភាពទៅទៀត ពុំត្រូវធុញទ្រាន់នឿយណាយ ដោយមនោគតិប្រកបដោយការប្រមាទ ហើយស្មានថា អំពើតិចតួចពុំងាយនឹងសម្រេចអ្វីបានឡើយ ។

សូម្បីក្អមទឹក ដែលគេបើកមាត់ចំហទុកចោលក្នុងទីវាលក៏គង់ពេញ ពោរទៅដោយដំណក់ទឹកភ្លៀង ដែលធ្លាក់តក់ ៗ ចុះពីអាកាសមកដែរ ។

សេចក្ដីប្រៀបធៀបនៃការមិនប្រមាទទាំងពីរផ្នែកមានកំពស់ស្មើគ្នា ។

កាលបើដូច្នេះ ជនជាតិណាក៏ដោយក្នុងពិភពលោក គួរតែនាំគ្នា

ប្រព្រឹត្តសុចរិតយុត្តិធម៌ឲ្យបានម៉ឺងម៉ាត់ គឺត្រូវស្រឡាញ់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍សាធារណជន ប្រយោជន៍ជាតិមាតុភូមិ សាសនា មហាក្សត្រខ្លួន ព្រមទាំងជនជាតិដទៃផង មិនត្រូវបៀតបៀនញាំញីបៃជាន់ សង្កត់សង្កិនយកផលប្រយោជន៍ អំពីគ្នាទៅវិញទៅមក ដោយសារតែមានសេចក្ដីប្រមាទឡើយ ។ ប្រព្រឹត្តបែបនេះ ដើម្បីរក្សាការពារឧត្តមប្រយោជន៍ឲ្យបានស្ថាពរ ព្រមទាំងជួយពង្រីកពង្រឹងសន្តិសុខ សន្តិភាពឲ្យបានទូលំទូលាយពាសពេញសាកលលោកផង ។

អវសានកថា សូមផ្សាយសប្បុរសធម៌ គ្រប់សញ្ញាតិសូមបានប្រកបដោយសេចក្ដីសុខសេចក្ដីចំរើន ព្រមទាំងតាំងនៅស៊ុបក្នុងព្រះពុទ្ធសាសនាអស់កាលជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ ។

# ប្រស្នាព្រះឥន្ទ[១]

លោក ប៊ូ - ប៉ូ រៀបរៀង

១- ព្រះឥន្ទក្រាបបង្គំទូលសួរប្រស្នាចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ពួកទេវតានិងមនុស្សអសុរ នាគ គន្ធព្វ ព្រមទាំងពួកជនជាច្រើនដទៃទៀត មានធម៌អ្វីជាគ្រឿងចងរួបរឹតទុក បានជាពួកសត្វទាំងនោះតាំងប្រាថ្នាថា សូមឲ្យយើងទាំងឡាយជាអ្នកគ្មានពៀរ គ្មានអាជ្ញា គ្មានសត្រូវ គ្មានព្យាបាទគ្នា ក៏គង់សត្វទាំងនោះនៅតែជាអ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទគ្នាដដែល ?

ព្រះពុទ្ធអង្គទ្រង់ព្យាករថា បានជាពួកសត្វទាំងនោះមិនបានសម្រេចតាមចិត្តប្រាថ្នាដូច្នោះ ព្រោះមានឥស្សា ( សេចក្ដីច្រណែន ) និងមច្ឆរិយៈ ( សេចក្ដីកំណាញ់ ) ជាគ្រឿងចងរួបរឹតទុក ។

២- ព្រះឥន្ទ- ចុះសេចក្ដីច្រណែននិងសេចក្ដីកំណាញ់មានអ្វីជាដើមហេតុ នាំឲ្យកើតឡើង ?

ព្រះពុទ្ធ- សេចក្ដីច្រណែននិងសេចក្ដីកំណាញ់ មានសេចក្ដីស្រឡាញ់និងសេចក្ដីស្អប់ជាដើមហេតុ នាំឲ្យកើតឡើង ។

៣- ព្រះឥន្ទ- ចុះសេចក្ដីស្រឡាញ់និងសេចក្ដីស្អប់ មានឆន្ទៈ(សេចក្ដីពេញចិត្ត)ជាដើមហេតុ នាំឲ្យកើតឡើង ?

---

១- ស្រង់ការសេចក្ដីខ្លី អំពីសុត្តន្តបិដក ទីឃនិកាយ ចរក្ខភាគ មហាវគ្គ សក្កបញ្ហសូត្រ ( សៀវភៅព្រះត្រៃបិដកបាឡី ខ្មែរ លេខ ១៣ ) ។

៤. ព្រះឥន្ទ- ចុះឆន្ទៈ មានអ្វីជាដើមហេតុនាំឲ្យកើតឡើង ?

ព្រះពុទ្ធ ឆន្ទៈ មានវិតក្កៈ ( សេចក្ដីត្រិះរិះ ) ជាដើមហេតុនាំឲ្យកើតឡើង ។

៥- ព្រះឥន្ទ- ចុះវិតក្កៈ មានអ្វីជាដើមហេតុនាំឲ្យកើតឡើង ?

ព្រះពុទ្ធ- វិតក្កៈ មានចំណែកនៃបបញ្ចសញ្ញា (សេចក្ដីសំគាល់ប្រកបដោយធម៌ជាគ្រឿងយឺតយូរ (១) ) ជាមៈហេតុនាំឲ្យកើតឡើង ។

៦- ព្រះឥន្ទ- ចុះភិក្ខុប្រតិបត្តដូចម្ដេច ទើបឈ្មោះថាជាអ្នកប្រតិបត្តនូវបដិបទាជាដំណើរដ៏សមគួរដល់សេចក្ដីរលត់ចំណែកនៃបបញ្ចសញ្ញា ?

ព្រះពុទ្ធ- សោមនស្សមាន២យ៉ាង គឺសោមនស្សដែលគួរសេព១យ៉ាង សោមនស្សដែលមិនគួរសេព១យ៉ាង ។ បណ្ដាសោមនស្សទាំង២យ៉ាងនោះ សោមនស្សបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវសោមនស្សនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ សោមនស្សបែបនេះ (២) ភិក្ខុមិនគួរសេពទេ ។ សោមនស្សបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវសោមនស្សនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ

---

១) សំដៅយកតណ្ហាវិចរិតទាំង ១០៨ ។ ២- សំដៅយកគេហសិតសោមនស្ស គឺសោមនស្សដែលអាស្រ័យនូវផ្ទះ គឺកាមគុណៈទាំង ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

សោមនស្សបែបនេះ(១) ភិក្ខុគួរសេព ។ ក្នុងសោមនស្សដែលគួរសេពនោះ សោមនស្សដែលមានវិតក្កៈ វិចារៈ ក៏មាន(២) សោមនស្សដែលគ្មានវិតក្កៈ វិចារៈ ក៏មាន(៣) សោមនស្សឯណាដែលគ្មានវិតក្កៈ វិចារៈ សោមនស្សនោះប្រសើរជាង ។

ទោមនស្សមាន២យ៉ាង គឺទោមនស្សដែលគួរសេព១យ៉ាង ទោមនស្សដែលមិនគួរសេព១យ៉ាង ។ បណ្ដាទោមនស្សទាំង២យ៉ាងនោះ ទោមនស្សបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ ទោមនស្សបែបនេះ(៤) ភិក្ខុមិនគួរសេពទេ ។ ទោមនស្សបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ ទោមនស្សបែបនេះ(៥)

---

១- សំដៅយកនេក្ខម្មសិតសោមនស្ស គឺសោមនស្សដែលអាស្រ័យនូវនេក្ខម្មៈ គឺការចេញចាកកាមគុណទាំង៥ របស់បុគ្គលដែលប្រកបដោយវិបស្សនា ។ ២- បានដល់សោមនស្សដែលកើតដោយអំណាចនេក្ខម្មៈ និងវិបស្សនា និងអនុស្សតិ និងបឋមជ្ឈាន ។ ៣- បានដល់សោមនស្សដែលកើតដោយអំណាចទុតិយជ្ឈាន តតិយជ្ឈាន ។ ៤- សំដៅយកគេហសិតទោមនស្ស គឺទោមនស្សដែលអាស្រ័យនូវផ្ទះ គឺកាមគុណទាំង ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ របស់បុគ្គលដែលមិនបានសោយនូវអារម្មណ៍ជាទីពេញចិត្ត ។ ៥- សំដៅយកនេក្ខម្មសិតទោមនស្ស គឺទោមនស្សដែលអាស្រ័យនូវនេក្ខម្មៈកើតឡើងចំពោះបុគ្គលអ្នកសោយ អន់ចិត្តព្រោះហេតុតែក្របានសម្រេចនូវអរិយភូមិ ។

ភិក្ខុគប្បីសេព ៗ ក្នុងទោមនស្សដែលគួរសេពនោះ ទោមនស្សដែលមានវិតក្កៈ វិចារៈ ក៏មាន(១) ទោមនស្សដែលគ្មានវិតក្កៈ វិចារៈក៏មាន(២) ទោមនស្សណាដែលគ្មានវិតក្កៈ វិចារៈ ទោមនស្សនោះប្រសើរជាង ៗ

ឧបេក្ខាមាន ២ យ៉ាង គឺឧបេក្ខាដែលគួរសេព ១ យ៉ាង ឧបេក្ខាដែលមិនគួរសេព ១ យ៉ាង ៗ បណ្ដាឧបេក្ខាទាំង ២ យ៉ាងនោះ ឧបេក្ខាបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ ឧបេក្ខាបែបនេះ(៣) ភិក្ខុមិនគួរសេពទេ ៗ ឧបេក្ខាបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ ឧបេក្ខាបែបនេះ(៤) ភិក្ខុគួរសេព ៗ ក្នុងឧបេក្ខាដែលគួរសេពនោះ ឧបេក្ខាដែលមានវិតក្កៈវិចារៈក៏មាន(៥) ឧបេក្ខាដែល

---

១- បានដល់ទោមនស្សដែលកើតដោយអំណាចនេក្ខម្មៈ និងវិបស្សនា និងអនុស្សតិ និងបឋមជ្ឈាន ។ ២- បានដល់ទោមនស្សកើតឡើងចំពោះបុគ្គលដែលប្រកបដោយវិបស្សនាប្រាថ្នានូវអរហត្តផល បើទុកជាប្រឹងប្រែងយ៉ាងណាក៏នៅតែមិនបានសម្រេចនូវបំណង ។ ៣- បានដល់គេហសិតឧបេក្ខា គឺឧបេក្ខាដែលអាស្រ័យនូវផ្ទះ គឺកាមគុណទាំង៥ កើតឡើងចំពោះបុគ្គលដែលល្ងង់ខ្លៅក៏ភាប់ស្អិតក្នុងឥដ្ឋារម្មណ៍ មិនត្រឡប់បែរក្រោយវិញឡើយ ដូចជារុយដែលជាប់ចិត្តនឹងស្ករអំពៅ ។ ៤- បានដល់នេក្ខម្មសិតឧបេក្ខា គឺឧបេក្ខាដែលសម្បយុត្តដោយវិបស្សនាញាណ មិនត្រេកអរនឹងឥដ្ឋារម្មណ៍ មិនស្អប់អនិដ្ឋារម្មណ៍ ។ ៥- បានដល់ឧបេក្ខាដែលកើតដោយនេក្ខម្មៈ និងវិបស្សនា និងអនុស្សតិ និងបឋមជ្ឈាន ។

គ្មានវិតក្កៈវិចារៈក៏មាន(១) ឧបេក្ខាឯណាដែលគ្មានវិតក្កៈវិចារៈ ឧបេក្ខានោះប្រសើរជាង ។ ភិក្ខុលុះតែប្រតិបត្តិយ៉ាងនេះឯងទើបឈ្មោះថាជាអ្នកប្រតិបត្តិនូវបដិបទាជាដំណើរដ៏សមគួរដល់សេចក្ដីរលត់ចំណែកនៃបបញ្ចសញ្ញា ។

៧- ព្រះឥន្ទ- ចុះភិក្ខុប្រតិបត្តិដូចម្ដេច ទើបឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីសង្រួមក្នុងបាតិមោក្ខ ?

ព្រះពុទ្ធ- កាយសមាចារ ( មារយាទផ្លូវកាយ ) មាន ២ យ៉ាង គឺ កាយសមាចារដែលគួរសេព ១ យ៉ាង កាយសមាចារដែលមិនគួរសេព ១ យ៉ាង ។ បណ្ដាកាយសមាចារទាំង ២ យ៉ាងនោះ កាយសមាចារបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ កាយសមាចារបែបនេះ(២) ភិក្ខុមិនគួរសេពទេ ។ កាយសមាចារបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ កាយសមាចារបែបនេះ(៣) ភិក្ខុគួរសេព ។

---

១– បានដល់ឧបេក្ខាដែលកើតដោយអំណាចឈាន មានទុតិយជ្ឈាន និងតតិយជ្ឈានជាដើម ។ ២– ការប្រព្រឹត្តបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងការប្រព្រឹត្តកន្លងសិក្ខាបទជាបណ្ណត្តិវជ្ជៈចំពោះកាយទ្វារ ។ ៣– ការវៀរចាកអំពើទាំងនេះ មានបាណាតិបាតជាដើម ចំពោះកាយទ្វារ ។

វចីសមាចារ ( មារយាទផ្លូវវាចា ) មាន ២ យ៉ាង គឺវចីសមាចារដែលគួរសេព ១ យ៉ាង វចីសមាចារដែលមិនគួរសេព ១ យ៉ាង ។ បណ្ដាវចីសមាចារទាំង ២ យ៉ាងនោះ វចីសមាចារបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវវចីសមាចារនេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ វចីសមាចារបែបនេះ[១] ភិក្ខុមិនគួរសេពទេ ។ វចីសមាចារបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវវចីសមាចារនេះ អកុសល-ធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ វចីសមាចារបែបនេះ[២] ភិក្ខុគួរសេព ។

បរិយេសនា ( ការស្វែងរក ) មាន ២ យ៉ាង គឺបរិយេសនាដែលគួរសេព ១ យ៉ាង បរិយេសនាដែលមិនគួរសេព ១ យ៉ាង ។ បណ្ដាបរិយេស-នាទាំង ២ យ៉ាងនោះ បរិយេសនាបែបណាដែលភិក្ខុដឹងច្បាស់ថា កាលបើអាត្មាអញសេពនូវបរិយេសនានេះ អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅដូច្នេះ បរិយេសនាបែបនេះ[៣] ភិក្ខុមិនគួរសេពទេ ។ បរិយេសនាណាដែលភិក្ខុដឹងច្បាស់ថា

---

១– ការពោលវចីទុច្ចរិត ៤ យ៉ាង មានមុសាវាទជាដើម និងការប្រព្រឹត្តកន្លងសិក្ខាបទដែលជាបណ្ណត្តិវជ្ជៈចំពោះវចីទ្វារ ។ ២– ការវៀរចាកវចីទុច្ចរិត ៤ យ៉ាង និងការមិនប្រព្រឹត្តកន្លងសិក្ខាបទដែលជាបណ្ណត្តិវជ្ជៈចំពោះវចីទ្វារ ។ ៣– បានដល់អនរិយបរិយេសនា ការស្វែងរកមិនប្រសើរ គឺការស្វែងរកបុត្រភរិយាទ្រព្យជាដើម ។

កាលបើអាត្មាអញសេពនូវបរិយេសនានេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើងដូច្នេះ បរិយេសនាបែបនេះ(១)ក៏គួរសេព ។

ភិក្ខុប្រតិបត្តិយ៉ាងនេះ ទើបឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីសង្រួមក្នុងបាតិមោក្ខ ។

៨- ព្រះឥន្ទ- ចុះភិក្ខុប្រតិបត្តិដូចម្តេច ទើបឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីសង្រួមក្នុងឥន្ទ្រិយ ?

ព្រះពុទ្ធ- រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកមាន ២ យ៉ាង គឺ រូបារម្មណ៍ដែលគួរសេព ១ យ៉ាង រូបារម្មណ៍ដែលមិនគួរសេព ១ យ៉ាង សទ្ទារម្មណ៍ដែលគួរដឹងច្បាស់ដោយត្រចៀកមាន ២ យ៉ាងគឺ ។បេ។ គន្ធារម្មណ៍ដែលគួរដឹងច្បាស់ដោយច្រមុះ ២ យ៉ាង គឺ ។បេ។ រសារម្មណ៍ដែលគួរដឹងច្បាស់ដោយអណ្តាត ។បេ។ ផោដ្ឋព្វារម្មណ៍ដែលគួរដឹងច្បាស់ដោយកាយ ។បេ។ ធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្តមាន ២ យ៉ាង គឺធម្មារម្មណ៍ដែលគួរសេព ១ យ៉ាង ធម្មារម្មណ៍ដែលមិនគួរសេព១យ៉ាង

កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឥន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គទ្រង់សំដែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គអាចដឹងសេចក្តីច្បាស់លាស់ដោយពិស្តារបានថា

---

១ ជានិស់អរិយបរិយេសនា ការស្វែងរកដ៏ប្រសើរ គឺការស្វែងរកព្រះនិព្វាន ។

កាលបើភិក្ខុសេពនូវរូបារម្មណ៍បែបណា អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ រូបារម្មណ៍បែបនេះ ភិក្ខុមិនគួរសេពទេ ។ កាលបើភិក្ខុសេពនូវរូបារម្មណ៍បែបណា អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំ-រើនដុះដាលឡើង រូបារម្មណ៍បែបនេះ ភិក្ខុគួរសេព ។ កាលបើភិក្ខុសេពនូវសទ្ទារម្មណ៍បែបណា ។បេ។ កាលបើភិក្ខុសេពនូវគន្ធារម្មណ៍បែបណា ។បេ។ កាលបើភិក្ខុសេពនូវរសារម្មណ៍បែបណា ។បេ។ កាលបើភិក្ខុសេពនូវផោដ្ឋព្វារម្មណ៍បែបណា ។បេ។ កាលបើភិក្ខុសេពនូវធម្មារម្មណ៍បែបណា អកុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ធម្មារម្មណ៍បែបនេះ ភិក្ខុមិនគួរសេពទេ ។ កាលបើភិក្ខុសេពនូវធម្មារម្មណ៍បែបណា អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចំរើនដុះដាលឡើង ធម្មា-រម្មណ៍បែបនេះ ភិក្ខុគួរសេព ។

៩-ព្រះឥន្ទ- ចុះពួកសមណព្រាហ្មណ៍ទាំងអស់សុទ្ធតែជាអ្នកមានវាទៈដូចគ្នា មានមារយាទដូចគ្នា មានឆន្ទៈ គឺលទ្ធិដូចគ្នា មានសេចក្ដីចូលចិត្តដូចគ្នាដែរឬ ?

ព្រះពុទ្ធ- ពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនមានវាទៈដូចគ្នាទេ មិនមែនមានមារយាទដូចគ្នាទេ មិនមែនមានឆន្ទៈគឺលទ្ធិដូចគ្នាទេ មិនមែន

មានសេចក្ដីចូលចិត្តដូចគ្នាទេ ។

១០- ព្រះឥន្ទ- ចុះហេតុអ្វី បានជាពួកសមណព្រាហ្មណ៍ទាំងអស់ មានវាទៈមិនដូចគ្នា មានមារយាទមិនដូចគ្នា មានឆន្ទៈគឺលទ្ធិមិនដូចគ្នា មានសេចក្ដីចូលចិត្តមិនដូចគ្នា ?

ព្រះពុទ្ធ- លោកគឺពួកសត្វមានធាតុគឺអធ្យាស្រ័យច្រើនពន់ពេក មានធាតុផ្សេងៗគ្នា ក្នុងលោកដែលមានធាតុច្រើន មានធាតុផ្សេងៗនោះ សត្វទាំងឡាយប្រកាន់មាំនូវធាតុគឺអធ្យាស្រ័យឯណាៗ ក៏ប្រកាន់មាំនូវធាតុគឺអធ្យាស្រ័យនោះៗ ដោយកម្លាំងចិត្តនិងការស្ទាបអង្អែល តែងពោលថា ពាក្យនេះឯងជាពាក្យពិត ពាក្យដទៃជាពាក្យទទេឥតប្រយោជន៍ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ទាំងអស់ មានវាទៈមិនដូចគ្នា មានមារយាទមិនដូចគ្នា មានឆន្ទៈគឺលទ្ធិមិនដូចគ្នា មានសេចក្ដីចូលចិត្តមិនដូចគ្នា ។

១១- ព្រះឥន្ទ- ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែមានសេចក្ដីសម្រេចគឺព្រះនិព្វានទៀងទាត់ប្រាកដ មានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងទាត់ប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរគឺអរិយមគ្គទៀងទាត់ប្រាកដជាអ្នកមានទីបំផុតគឺព្រះនិព្វានទៀងទាត់ប្រាកដដែរឬ ?

ព្រះពុទ្ធ- សមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែមានសេចក្ដីសម្រេចគឺព្រះនិព្វានទៀងទាត់ប្រាកដទេ មិនមែនមានធម៌ជាគ្រឿងអស់

ចាកយោគៈទៀតផុតប្រាកដទេ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀតផុតប្រាកដទេ មិនមែនជាអ្នកមានទីបំផុតគឺព្រះនិព្វាន ទៀតផុតប្រាកដទេ ។

១២-ព្រះឥន្ទ- ចុះពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែ ជាអ្នកមានសេចក្ដីសម្រេចគឺព្រះនិព្វានទៀតផុតប្រាកដ ។បេ។ មិនមែន ជាអ្នកមានទីបំផុតគឺព្រះនិព្វានទៀតផុតប្រាកដទាំងអស់គ្នានោះ តើព្រោះ ហេតុអ្វី ?

ព្រះពុទ្ធ- ភិក្ខុទាំងឡាយឯណាដែលមានចិត្តចុះស៊ប់ក្នុងព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហាហើយ ភិក្ខុទាំងឡាយនោះឈ្មោះថា ជាអ្នកមាន សេចក្ដីសម្រេចគឺព្រះនិព្វានទៀតផុតប្រាកដ មានធម៌ជាគ្រឿងអស់ទៅ នៃយោគៈទៀតផុតប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរគឺអរិយមគ្គទៀត ផុតប្រាកដ ជាអ្នកមានទីបំផុតគឺព្រះនិព្វានទៀតផុតប្រាកដ ព្រោះហេតុ នោះឯង បានជាពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែ ជាអ្នកមានសេចក្ដីសម្រេចគឺព្រះនិព្វានទៀតផុតប្រាកដ ។បេ។ មិនមែន ជាអ្នកមានទីបំផុតគឺព្រះនិព្វានទៀតផុតប្រាកដទាំងអស់គ្នាឡើយ ។

ព្រះឥន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីញាប់ញ័រគឺ តណ្ហាទុកដូចជារោគ ទុកដូចជាបូស ទុកដូចជាកូនសរ តែងជីកទាញនូវ បុរសនេះឲ្យកើតក្នុងភពនោះៗ ព្រោះហេតុនោះឯង បុរសនេះរមែងដល់នូវ

សេចក្តីខ្ពស់ទាប ។ ខ្ញុំព្រះអង្គមិនបានទូលឱកាសកម្មនៃប្រស្នាណាអំពីសមណព្រាហ្មណ៍ដទៃខាងក្រៅព្រះពុទ្ធសាសនានេះ ប្រស្នានោះព្រះអង្គអ្នកឃើញនូវកាលដ៏វែងបានព្យាករដល់ខ្ញុំព្រះអង្គហើយ មួយវិញទៀតព្រះអង្គបានតាំងដកនូវសរគឺសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់អំពីខ្ញុំព្រះអង្គចេញបានហើយ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ថ្វាយព្រះពរទេវានមិន្ទៈ មហាបពិត្រធ្លាប់នាំយកប្រស្នានេះ ទៅសួរចំពោះពួកសមណព្រាហ្មណ៍ដទៃដែរឬ ?

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គធ្លាប់នាំយកប្រស្នានេះទៅសួរចំពោះពួកសមណព្រាហ្មណ៍ដទៃដែរ ។

ថ្វាយព្រះពរ ទេវានមិន្ទៈ ចុះពួកសមណព្រាហ្មណ៍ទាំងនោះបានព្យាករថ្វាយមហាបពិត្រដូចម្តេចខ្លះ បើមហាបពិត្រមិនទើសទាល់ព្រះទ័យទេ សូមមហាបពិត្រមានព្រះបន្ទូលទៅមើល ។

បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគក្តី បុគ្គលដែលមានរូបប្រហែលព្រះដ៏មានព្រះភាគក្តី អង្គុយក្នុងទីណា ទីនោះមិនទើសទាល់ចិត្តខ្ញុំព្រះអង្គឡើយ ។

ថ្វាយព្រះពរ ទេវានមិន្ទៈ បើដូច្នោះ សូមមហាបពិត្រមានព្រះបន្ទូលទៅមើល ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសំគាល់ពួកសមណព្រាហ្មណ៍ឯ

ណាថា សមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកនៅក្នុង អរញ្ញប្រទេសមាន សេនាសនដ៏ស្ងាត់ ខ្ញុំព្រះអង្គក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរប្រស្នាទាំងនេះ ពួកសមណព្រាហ្មណ៍នោះមិនអាចនឹងដោះស្រាយបាន ក៏ត្រឡប់សួរមកខ្ញុំព្រះអង្គវិញថា អ្នកដ៏មានអាយុឈ្មោះអ្វី ខ្ញុំព្រះអង្គបានប្រាប់ថា បពិត្រអ្នកនិរទុក្ខ ខ្ញុំឯងជាសក្កទេវេន្ទ ជាធំជាងពួកទេវតា ពួកសមណព្រាហ្មណ៍នោះ សួរខ្ញុំព្រះអង្គតទៅទៀតថា បពិត្រទេវានមិន្ទៈដ៏មានអាយុ ចុះព្រះអង្គសាងនូវអំពើដូចម្ដេច បានជាដល់នូវទីនេះ ខ្ញុំព្រះអង្គក៏សំដែងធម៌(១) ដល់ពួកសមណព្រាហ្មណ៍នោះ តាមដែលបានស្ដាប់មក បានរៀនមក ពួកសមណព្រាហ្មណ៍នោះ មានសេចក្ដីត្រេកអរដោយធម៌មានប្រមាណប៉ុណ្ណោះថា សក្កទេវេន្ទជាធំជាងពួកទេវតា យើងទាំងឡាយបានឃើញហើយផង យើងទាំងឡាយបានសួរនូវប្រស្នាឯណា លោកក៏បានដោះស្រាយនូវប្រស្នានោះ ដល់យើងទាំង-ឡាយផង ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់ទៅជាសាវករបស់ខ្ញុំព្រះអង្គទៅវិញ ឯខ្ញុំព្រះអង្គមិនមែនជាសាវករបស់ពួកសមណព្រាហ្មណ៍នោះទេ បពិត្រព្រះអង្គដ៏ចំរើន ឯខ្ញុំព្រះអង្គជាសាវករបស់ព្រះដ៏មានព្រះភាគ ជាសោតាបន្នបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀងមានប្រាជ្ញាជាគ្រឿងត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

ថ្វាយព្រះពរ ទេវានមិន្ទៈ កាលពីដើម មហាបពិត្រធ្លាប់ត្រេកអរ

---

១– វត្តបទ ៣ យ៉ាង ។

សោមនស្សបែបនេះដែរឬទេ ?

បពិត្រព្រះអង្គដ៏ចំរើន កាលពីដើម ខ្ញុំព្រះអង្គធ្លាប់ត្រេកអរសោមនស្សបែបនេះដែរ ។

ថ្វាយព្រះពរ ទេវានមិន្ទៈ ចុះកាលពីដើម មហាបពិត្រធ្លាប់ត្រេកអរសោមនស្សបែបនេះដែរនោះតើដូចម្តេច ។

បពិត្រព្រះអង្គដ៏ចំរើន រឿងធ្លាប់មានមករួចហើយពួកទេវតានិងពួកអសុរបានធ្វើសង្គ្រាមតទល់គ្នា ។ ក្នុងសង្គ្រាមនោះ ពួកទេវតាឈ្នះ ឯពួកអសុរចាញ់ ។ កាលខ្ញុំព្រះអង្គបានឈ្នះសង្គ្រាមនោះ ដាច់ស្រេចហើយ ក៏ត្រិះរិះថា ឥឡូវពួកទេវតានឹងបរិភោគនូវឱជារសទាំងពីរ គឺឱជារសរបស់ទេវតា និងឱជារសរបស់អសុរក្នុងទេវលោកនេះ សេចក្តីត្រេកអរសោមនស្សរបស់ខ្ញុំព្រះអង្គនោះនៅប្រកបដោយគ្រឿងវាយដំ ប្រកបដោយគ្រឿងកាប់ចាក់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានឡើយ បពិត្រព្រះអង្គដ៏ចំរើន ចំណែកខាងខ្ញុំព្រះអង្គត្រេកអរសោមនស្សព្រោះបានស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគនោះ មិនប្រកបដោយគ្រឿងវាយដំទេ មិនប្រកបដោយគ្រឿងកាប់ចាក់ទេ តែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែម្យ៉ាង ។

ថ្វាយព្រះពរ ទេវានមិន្ទៈ ចុះមហាបពិត្រទ្រង់យល់ឃើញប្រយោជន៍ ដូចម្តេច បានជាទ្រង់ត្រេកអរសោមនស្សមានសភាពយ៉ាងនេះ ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គយល់ឃើញប្រយោជន៍ ៦ យ៉ាង គឺ

ទី ១- កាលដែលអាត្មាអញកើតជាទេវតា ស្ថិតនៅក្នុងឱកាសនេះ អាត្មាអញបានទទួលអាយុថ្មីទៀត ។

ទី២- ចិត្តរបស់ខ្ញុំព្រះអង្គត្រេកអរក្នុងត្រកូលណា ខ្ញុំព្រះអង្គច្យុតពីទេវតាហើយជាអ្នកមិនវង្វេងចូលទៅកើតក្នុងត្រកូលនោះ ។

ទី៣- ខ្ញុំព្រះអង្គជាអ្នកត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធជាម្ចាស់ ទ្រង់មានប្រាជ្ញាមិនកាន់ច្រឡំ ព្រះអង្គមានសេចក្តីដឹងខ្លួន មានស្មារតីតម្កល់ខ្ជាប់ នៅដោយសេចក្តីដឹងខុសត្រូវ ។

ទី៤- បើសម្មោធិញាណ(១) នឹងមានដល់ខ្ញុំព្រះអង្គក្នុងខាងមុខដោយសេចក្តីដឹងខុសត្រូវ ខ្ញុំព្រះអង្គជាអ្នកប្រាថ្នាដើម្បីឲ្យបានដឹងខុសត្រូវសេចក្តីដឹងខុសត្រូវនោះឯង ជាសំខាន់របស់ខ្ញុំព្រះអង្គក្នុងមនុស្សលោក ។

ទី៥- ព្រះអង្គមុខជានឹងច្យុតពីមនុស្ស ហើយបានទៅកើតជាទេវតាដ៏ឧត្តមក្នុងទេវលោកវិញ ។

ទី៦- ពួកទេវតានោះ ឧត្តមជាងទេវតាទាំងពួង ជាអ្នកមិនថយថោក ជាអ្នកមានយស ស្ថិតនៅក្នុងលំនៅណា លំនៅនោះមុខជានឹងមាន

១) សម្មោធិញ្ញាណ សំដៅយកសកទាគាមិមគ្គ ( អដ្ឋកថា ) ។

ដល់ខ្ញុំព្រះអង្គគង់ភពជាទីបំផុតមិនខាន(១) ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គយល់ឃើញនូវប្រយោជន៍ទាំង ៦ ប្រការហ្នឹងឯង បានជាសំដែងនូវសេចក្តីត្រេកអរសោមនស្សមានសគារព យ៉ាងនេះ ។

ខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាមិនទាន់សម្រេច នៅមានសេចក្តីសង្ស័យងឿងឆ្ងល់ តែងត្រាច់ស្វះស្វែងរកព្រះតថាគត អស់កាលជាយូរអង្វែងមកហើយ ។ ខ្ញុំព្រះអង្គសំគាល់នូវពួកសមណៈឯណា ដែលជាអ្នកនៅក្នុងទីស្ងាត់ ក៏នឹកស្មានថាជាព្រះសម្ពុទ្ធ ហើយចូលទៅអង្គុយជិតពួកសមណៈនោះ ។ ខ្ញុំព្រះអង្គសួរពួកសមណៈនោះថា សេចក្តីជ្រះថ្លាតើដូចម្តេច? ពួកសមណៈនោះមិនអាចដោះស្រាយ ក្នុងមគ្គនិងបដិបទាទាំងឡាយបានឡើយ ។ កាលដែលពួកសមណៈទាំងនោះ ស្គាល់ខ្ញុំព្រះអង្គថាជាសក្កទេវរាជមកពីស្ថានទេវតា ក៏សួរខ្ញុំព្រះអង្គថា ទេវរាជបានសាងកុសលដូចម្តេចទើបដល់នូវសម្បត្តិនេះ ។ ខ្ញុំព្រះអង្គក៏សំដែងធម៌តាមដែលបានស្តាប់មកប្រាប់ដល់សមណៈទាំងនោះឲ្យប្រាកដក្នុងទីប្រជុំជន ពួកសមណៈទាំងនោះក៏នាំគ្នាពេញចិត្តដោយហេតុថា យើងទាំងឡាយបានឃើញវាសវៈទេវរាជហើយ ។ ម្យ៉ាងទៀត កាលដែលខ្ញុំព្រះអង្គបានឃើញព្រះសម្ពុទ្ធទ្រង់ឆ្លងផុតចាកសេចក្តីសង្ស័យហើយក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាអ្នកប្រាសចាកភ័យ

១– អដ្ឋកថា ថា ព្រះឥន្ទ្រមុខនោះនឹងបានផ្លូវអនាគាមិមគ្គ លុះច្យុតអំពីអត្តភាពនោះទៅ នឹងបានទៅកើតក្នុងសុទ្ធាវាស មានអវិហាជាដើម មានអកនិដ្ឋភពជាទីបំផុត ។

ហើយបានចូលមកអង្គុយជិតព្រះសមុទ្ទ ។ ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសមុទ្ទទ្រង់ដកចោលនូវសរគឺតណ្ហាចេញបានហើយ រកបុគ្គលប្រៀបផ្ទឹមគ្មាន ទ្រង់មានព្យាយាមច្រើន ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គជាពូជពង្សនៃអាទិច្ចគោត្រ ។ បពិត្រព្រះអង្គទ្រង់ទិទុក្ខពីកាលមុន ខ្ញុំព្រះអង្គព្រមទាំងទេវតាបានធ្វើនូវការនមស្ការឯណាចំពោះព្រះព្រហ្ម ក្នុងថ្ងៃនេះខ្ញុំព្រះអង្គសូមថ្វាយនមស្ការនោះចំពោះព្រះអង្គវិញ ខ្ញុំព្រះអង្គសូមធ្វើនូវការថ្វាយបង្គំចំពោះព្រះអង្គដោយខ្លួនឯង ។ ព្រះអង្គជាព្រះសមុទ្ទពិតមែន ព្រះអង្គជាសាស្ដាប្រសើរ ក្នុងលោកនេះព្រមទាំងទេវលោកនឹងរកបុគ្គលណាមួយមកប្រៀបផ្ទឹមនឹងព្រះអង្គគ្មានឡើយ ។

លំដាប់នោះ សក្កទេវិន្ទត្រាស់នឹងបញ្ចសិខគន្ធព្វបុត្តថា នែអ្នកបញ្ចសិខៈ អ្នកឯងជាបុគ្គលមានឧបការច្រើនដល់យើងពិតមែន ដោយហេតុអ្នកបានធ្វើព្រះដ៏មានព្រះភាគឲ្យទ្រង់ប្រោសប្រាណជាមុន ទើបយើងបានចូលមកគាល់ព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ យើងនឹងតាំងអ្នកទុកក្នុងទីដូចជាបិតា អ្នកនឹងបានជាស្ដេចនៃពួកគន្ធព្វ ម្យ៉ាងទៀត យើងនឹងឲ្យនាងភទ្ទាសុរិយវច្ឆសាដល់អ្នក ព្រោះថានាងភទ្ទាសុរិយវច្ឆសានោះ អ្នកក៏ចង់បានមកជាយូរដែរហើយ ។ គ្រានោះ ព្រះឥន្ទ្រទ្រង់យកព្រះហស្ដទះផែនដីហើយបន្លឺនូវឧទានអស់វារៈ ៣ ដងថា ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

កាលដែលព្រះដ៏មានព្រះភាគ កំពុងតែសំដែងនូវវេយ្យាករណ៍នេះ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី គឺកគាទិក្កិលេស ប្រាសចាកមន្ទិល គឺទិដ្ឋិ និងវិចិកិច្ឆា ក៏កើតដល់ព្រះឥន្ទ្រនិងពួកទេវតាតាំង ៨ ម៉ឺនឯទៀតថា យំកិញ្ចិសមុទយធម្មំ សព្វន្តំ និរោធធម្មំ ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះរែងរលត់ទៅវិញជាធម្មតា ។

ប្រស្នាណាដែលព្រះឥន្ទ្របានអាពធនាទូលសួរហើយ ប្រស្នានោះព្រះដ៏មានព្រះភាគទ្រង់បានព្យាករហើយដោយប្រការដូច្នេះ ។

ប្រស្នាព្រះឥន្ទ្រ ចប់ ។

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ប៉ាង ខាត់ រៀបរៀង*

**អនិភាជ** គុ. ដែលមិនសង្កត់សង្កិន, ដែលមិនបៀរបៀន ។ បុំ. បរិកាត ។

**អនិភូត** គុ. ដែលមិននឹង, ដែលមិនបិតនៅ, ដែលកំរើក ។

**អនិមន្ត្រិត** គុ. ដែលគេមិននិមន្ត, ដែលគេមិនហៅ ។ – **ភោជិន៑** គុ ដែលបរិភោគដោយឥតគេអញ្ជើញ ។

**អនិមិត្ត** គុ. ដែលមិនមាននិមិត្ត, ដែលមិនមានហេតុ, ដែលមិនមានអារម្មណ៍ ។ នបុំ. ការមិនមាននិមិត្ត ។ – **និមិត្ត** គុ. ដែលមាននិមិត្តជាយមិនមាននិមិត្ត, ដែលមិនប្រាជ្ញា, ដែ មិនបង់បាន ។

**អនិមិឞ** បុំ. “ដែលមិនបិទភ្នែក” ទេវតា ។

**អនិមេឞ** គុ. ដែលមិនបិទ (ភ្នែក), ភ្ញៀងវៃ, ដែលបើក (ភ្នែក) ។ បុំ. ការមិន-

បិទ, ទេវតា ។ – ក្សេត្រ នបុំ. ខេត្តនៃព្រះវិស្ណុ ។– ទូ្បតី បុំ. ត្រី ។ អនិមិសាក្ស គុ. ដែលមានភ្នែកមិនបិទ ។

អនិមិសេក្ខណ គុ. ដែលមានភ្នែកមិនបិទ ។

អនិមីលិត គុ. ដែលមានភ្នែកមិនបិទ ។

អនិមេស បុំ. ការមិនបិទភ្នែក ។ បុំ. ទេវតា ។ គុ ដែលបើក (ភ្នែក) ។

អនិយត គុ. ដែលមិនទៀងទាត់, ដែលមិននឹង, ដែលមិនប្រាកដ, ដែលមិនតាំងនៅ ។ - បុំស្កា ស្រ្តី. ដែលមានប្តីមិនទៀងទាត់ ,, ស្រ្តីដែលមានចរិយាមិនបរិសុទ្ធ ។ – វត្តិ គុ. ដែលមានកិរិយាប្រព្រឹត្តមិននឹងធឹង ។ អនិយតាត្មន៑ អនិយត+អាត្មន៑) គុ. ដែលមានអាត្មន៑មិនទាន់ទូន្មានហើយ ។

អនិយន្ត្រណម៑ ក្រ.វិ. ដោយមិនកំណត់, ដោយសេរី ។ អនិយន្ត្រណា ស្រ្តី ការមិនមានកំរិត ។

អនិយម បុំ. អនិយម, ការមិនមានកំណត់, ការមិនមានច្បាប់, ការបណ្តោយឲ្យប្រព្រឹត្តទៅ ។

អនិយមិត គុ. ដែលមិនមានកំណត់, ដែលមិនមានច្បាប់, ដែលមិនទៀងទាត់។

អនិយុក្ត គុ ដែលមិនប្រកប, ដែលបុគ្គលមិនអនុញ្ញាតឲ្យ ។ បុំ. ជនដែលគេមិនតែងតាំងឲ្យ ។

អនិយោគ បុ. អនិយោគ, ការមិនសមប្រកប ។ អនិយោគិន គុ. ដែលមិនទាក់ទង ។

អនិរ គុ. ដែលមិនមានការប្រព្រឹត្តទៅ ។

អនិរាកូត បុំ. ដែលមិនរាំង ។

អនិរុត្ត គុ. ដែលមិនច្បាស់លាស់, ដែលមិនបាច់ពន្យល់, ដែលមិនគប្បីនិយាយ ។ — គាថា នបុំ. ចំរៀងមិនច្បាស់លាស់ ។

អនិរុទ្ធ គុ. ដែលមិនរាំង, ដែលមិនគ្រប់គ្រង ។ បុំ. បុត្រនៃប្រទ្យុម្ន ឬ កាមៈ, ព្រះឥស្សរ, នាមព្រះអរហន្តមួយក្នុងពុទ្ធសាសនា ។ — បថ នបុំ. "វិថីដែលមិនមានការរាំង" អាកាស, បរិយាកាស ។ — ភាវិនី ស្ត្រី. ភរិយានៃព្រះអនិរុទ្ធ ។

អនិរូបិត គុ. ដែលមិនសង្កេតមើល, ដែលសង្កេតមើលមិនបាន ។

អនិឃាត គុ. ដែលដកចេញមិនបាន, ដែលយកមិនបាន ។

អនិជិត គុ. ដែលមិនឈ្នះ, ដែលឈ្នះមិនបាន ។

អនិណិក្ត គុ. ដែលមិនបរិសុទ្ធ ។

អនិណិត គុ. ដែលដោះស្រាយមិនបាន ។

អនិទ៌យម៑ ក្រ.វិ. ដោយសេចក្តីអាណិត ។

អនិទ៌ឝា គុ. អនិទ៌ឝ (ដែលធ្វើការជម្រះមិនសម្រេចក្នុង ១០ ថ្ងៃ ក្រោយការកើត ឬ ការស្លាប់) ។ អនិទ៌ឝាហ គុ. ដូចគ្នា ។

អនិទ៌ិឞ្ដ គុ. ដែលមិនពន្យល់, ដែលមិនបញ្ជាក់ ។ – ការិន៑ គុ. ដែលមិនធ្វើនូវការដែលបុគ្គលតម្រូវហើយ ។

អនិទេ៌ឝ បុំ. ការមិនមាននិទ្ទេស, ការមិនមានច្បាប់, ការមិនមានសេចក្តីពន្យល់ ។ អនិទេ៌ឝេន ដោយមិនមានការសំដែងចេញ, ដោយមិនពិស្តារ ។ អនិទេ៌ឝ្យ គុ. ដែលបុគ្គលមិនគប្បីសំដែងចេញ ។

អនិធារិត គុ. ដែលមិនកំណត់ ។

អនិព៌ន្ធរុឞ៑ គុ. ដែលមានកំហឹងមិនឈប់ ។

អនិភ៌រ គុ. ដែលមិនក្រៃលែង, ដែលបន្តិចបន្តួច ។

អនិភិ៌ន្ន គុ. ដែលជាប់គ្នា, រដឹក, ដែលមិនបែក ។

អនិភេ៌ទ បុំ. ការមិនបំបែកចេញ, ការមិនសំដែងចេញ ។

អនិម៌ល គុ. ដែលមិននិម៌ល, កខ្វក់ ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(ភាគ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកកាន់វៃឆ្លាស់បើបានអាន
> នឹងចេះរបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ
>
> យូរ-អ៊ិន

## សាមកុកខ្សែ ៥៩

តាំងពីឡេវពីប្រើហងគុង នឹងជូឡុងទៅវាយទ័ពកួចប៉ែកបានបន្ទាយ នៅកាលហាន់ស៊ុយ រហូតទៅដល់ចូចូឲ្យសំបុត្រទៅស៊ុនក្វន ឲ្យលើកទ័ពទៅវាយយកស្រុកកេងជីវ ។

ឡេវពីដឹងដូច្នេះ ក៏ឲ្យត្រៀមកងទ័ពលើកទៅជាមួយនឹងខុងបេង ដោយបន្ទាន់ លុះទៅដល់កាលហាន់ស៊ុយ ក៏ឲ្យទាហានជូឡុងទៅសួរថា ដែលជូឡុងទៅធ្វើការសង្គ្រាមនឹងចូចូគ្រានេះ បានជ័យជំនះ ដោយប្រការម្តេច? ទាហាននោះក៏ជំពាបឡេវពីតាមដំណើរដែលបានធ្វើការមកពីដំបូងគ្រប់ប្រការ ឡេវពីបានដឹងដូច្នេះ ក៏មានចិត្តសប្បាយណាស់ ពិចារណាមើលទៅមុខភ្នំ ក្រោយភ្នំ ឃើញមានផ្លូវប្រកបល្អសុទ្ធតែផ្លូវស្រួលស្រឡះ ទើបនិយាយនឹងខុងបេងថា គម្រោះប្រាជ្ញារបស់ជូឡុងដែលគិតធ្វើសង្គ្រាមនេះ សុទ្ធតែជាវោហារទាំងអស់ ហើយកុំឲ្យហៅជូឡុងនឹង

ទាហានទាំងពួងមកប្រជុំព្រមគ្នា រួចនិយាយនឹងជូឡុងថា អ្នកមានសេចក្តីគាប់ប្រសើរក្នុងការសង្គ្រាមច្រើនណាស់ យើងនឹងតាំងឲ្យមានកិត្តិយសហៅថា ទាហានខ្លា ហើយឲ្យរៀបតុលៀងអាហារតាមសេចក្តីស្មោះសរ ទទួលអំណរសប្បាយ លុះវេលាល្ងាចមានបំរើចូលមកប្តឹងទៀវពីថា ឥឡូវចូចូនឹងលើកទ័ពធំមកតាមផ្លូវកំស្ងាត់ផ្លូវតូច ដើម្បីនឹងច្បាំងដណ្តើមយកវាលហាន់ស៊ុយវិញឲ្យបាន ទៀវពីឮដូច្នោះក៏អស់សំណើចហើយថា ដែលចូចូនឹងលើកទ័ពមកប្រាថ្នាដូច្នោះមិនឈ្នះយើងទេ ព្រោះយើងតាំងទ័ពមាំណាស់ហើយ ឥឡូវនឹងឲ្យទាហានលើកទៅតាំងបន្ទាយមួយទៀត ដើម្បីនឹងទប់ទាំងទ័ពនៅទិសបស្ចិម ចុងវាលហាន់ស៊ុយឲ្យយ៉ាងមាំ ៗ

ឯចូចូក៏ប្រុងប្រៀបទាហានត្រៀមទុកស្រេច ទើបចាត់ឲ្យស៊ុឡុងជានាយកងទ័ពមុខនឹងលើកទៅ អងបេងជាភ្នាក់ងាររក្សាទ្វារចូលទៅគំនាប់ចូចូ ហើយថា ទូលបង្គំបានរៀនមើលទំតាំងបន្ទាយដឹងថា ទ័ពនេះមានជ័យឬបរាជ័យ ត្រាទេះទូលបង្គំនឹងសុំអាសាទៅធ្វើកដការស៊ុឡុងតាមសតិបញ្ញាយកជ័យជំនះឲ្យបាន ចូចូមានសេចក្តីត្រេកអរណាស់ តាំងអងបេងជានាយកងទ័ពមុខទាហានស្តាំជួយគាំពារស៊ុឡុង លុះចាត់ចែងស្រេចហើយក៏លើកកម្រង់ទៅក្នុងតេងក្លួនសាន់ទិសទក្ខ៊ ស៊ុឡុងនឹងអងបេងនាយទ័ពខ្ទង់ស្តាំ ក៏នាំទាហាន លើកលេងទៅដល់វាលហាន់ស៊ុយ ស៊ុឡុងក៏ប្រឹក្សាថា យើងខ្ទង់ទឹកទៅតាំងបន្ទាយនៅត្រើយម្ខាង តើជាយ៉ាងម្តេច ?

អងបេងថា , បើទឹងថ្លឹងទៅក៏បាន តែខ្លាចក្រែងទៅមិនទាន់ដល់ទឹកថ្លែងស្រាប់តែមានសត្រូវលើកមកស្ទាក់ ក្នុងខណៈនោះតើយើងទឹងដោះរេះទៅខាងណាបាន ស៊ុឡងតបថា កាលគ្រាហានស៊ុនធ្វើសង្គ្រាមទឹងព្រះចៅឈប៉ាអងនោះ ក៏បានលើកពលទៅតាំងបន្ទាយនៅក្បែរមាត់ទឹកចំពោះការសឹកទឹងសត្រូវ ម្ដេចក៏នៅយកជ័យជំនះបាន ដូចគ្រានេះយើងទឹងលើកទៅតាំងបន្ទាយទប់ទល់ដល់មាត់ទឹកនោះ តើទឹងខ្លាចចាញ់ដោយហេតុអ្វី ? អងបេងថា កាលគ្រាហានស៊ុននោះ ហានស៊ុនឃើញពលព្រះចៅឈប៉ាអងកំពុងទៀយហត់អត់អាហារ បានជាលើកយោធា ទៅតាំងបន្ទាយនៅក្បែរមាត់ទឹកបាន វេលានេះអ្នកអាចដឹងថា កំឡាំងដូឡងទឹងហាងតុងនោះជាប្រការម្ដេច បានជាអាចទៅតាំងបន្ទាយឲ្យដូចហានស៊ុននោះ ខ្ញុំមិនយល់ឃើញផងសោះ ស៊ុឡងថា បើអ្នកមិនយល់ឃើញផងទេ ក៏តាមចិត្តចុះ បើដូច្នោះត្រូវអ្នកឯងនាំទាហានទៅតាំងបន្ទាយក្បែរមាត់ទឹកខាងទិសបូព៌ាឲ្យជាយ៉ាងមាំចុះ ដើម្បីកុំឲ្យកើតអន្តរាយបាន ស៊ុឡងក៏នាំទាហានទាំងពួងធ្វើស្ពានផែថ្លងខៈទូហានស៊ុយ ទៅតាំងបន្ទាយតាមដែលនិយាយគ្នានោះ ។

ឯហាងតុងទឹងដូឡងទាំង ២ នាក់ ក៏នាំគ្នាចូលទៅគំនាប់ឡៅពីហើយថា ខ្ញុំបាទទាំង ២ នាក់ ទឹងសុំអាសាលើកទាហានទៅច្បាំងទឹងកងទ័ពចូចូយកជ័យជំនះគ្រានេះឲ្យបានទៀត ឡៅពីក៏យល់ឃើញផង ហាងតុង ទឹង

ជូឡុងក៏លើកទ័ពចេញទៅ លុះទៅដល់កណ្តាលផ្លូវ ហង់តុងនិយាយនឹងជូឡុងថា ដែលស៊ីឡុងលើកទ័ពមកគ្រានេះ មានកម្លាំងខ្លាំងជាពន្ទឹកណាស់ យើងកុំអាលចូលទ័ពវាយទ័ពខាងគេ ត្រូវឲ្យគិតគ្នេរមើលកម្លាំងទាហានគេសិន បើឃើញអស់ដៃចុះវេលាណាបានការចំណាប់ខាងយើងហើយ សឹមលើកទាហានទន្ទ្រានចូលវាយប្រសព្វខ្ទប់យកជ័យជំនះ ឲ្យបានដោយងាយ ជូឡុងយល់ឃើញផង ក៏ស្រុះស្រួលបបួលគ្នា ទៅតាំងបន្ទាយតាមពាក្យប្រឹក្សា។ ។

លុះវេលាព្រឹកឡើង ស៊ីឡុងក៏លើកទាហានចេញមកទឹងតយុទ្ធគ្នានឹងជូឡុងចេះតែទៅប្រុងចាំនៅទីស្នាមគ្រោះទាល់តែថ្ងៃរសៀល ក៏មិនឃើញទ័ពជូឡុងចេញទៅតស៊ូគ្នា ស៊ីឡុងក៏ឲ្យទាហានគងមុខឃិតឆ្បាញ់គម្រន់ទៅមុខបន្ទាយ ហង់តុងឃើញដូច្នេះ ក៏ប្រាប់ជូឡុងថា សត្រូវបាញ់ឆ្បមកគ្រានេះ បែបពួកទាហានទាំងពួងនោះ ឃើញជារសាយដៃអស់ហើយ បើយើងនឹងលើកកំហុសចូលទៅវាយមុខជានឹងបែក អ្នកទាំង ២ កំពុងតែនិយាយគ្នាមិនទាន់ផុតមាត់ ស្រាប់តែមានពួកល្បាតចូលមកប្រាប់ថា ទ័ពមុខស៊ីឡុងថយទៅហើយ ហង់តុងអរណាស់ក៏លើកទាហានចេញទៅព្រមគ្នា ហើយឲ្យវាយឃោះគងទូងស្គរស្រែកហោអឹងកង លើកកងទ័ពចេញទៅវាយប្រសព្វខ្ទប់ទ័ពស៊ីឡុង ៗ ក៏បែកទ័ពត្រឡប់រត់ទៅដល់ទន្លេក្បែរពលហាន់ស៊ុយ ពួកពលដួលត្រឡប់ជាន់គ្នាស្លាប់ជាច្រើនណាស់

ចំណែកខ្លួន ស៊ីឡុង ដែលមានកម្លាំងច្រើនក៏តែទៅដល់បន្ទាយអង់បេង ហើយសួរអង់បេងថា អ្នកឯងបានឃើញទាហានយើងទន់ថយកម្លាំងនឹងសត្រូវ ហេតុម្តេចបានជាមិនលើកទៅជួយ ?

អង់បេងតបថា ខ្ញុំបាទនឹងលើកទ័ពទៅជួយលោកក៏គ្មាននរណាទៅថែរក្សាបន្ទាយ កាលពីដំបូងដែលលើកទ័ពទៅនោះ ខ្ញុំបាទក៏បានឃាត់ទាំងពីងពក លោកកុំឲ្យលើកទៅ លោកក៏មិនព្រមស្តាប់ពាក្យខ្ញុំ បានជាថ្វេះការទាំងម៉្លេះលោកនឹងបន្ទោសនរណា ស៊ីឡុងឮដូច្នោះ ក៏ខឹងណាស់ គិតនឹងសម្លាប់អង់បេងចេញ អង់បេងឃើញស៊ីឡុងខឹងខ្លាំងដូច្នោះក៏គិតថា សេចក្តីអន្តរាយនឹងកើតមានដល់ខ្លួនជាប្រាកដលុះ ដល់ពេលយប់ អង់បេងក៏ឲ្យទាហានរបស់ខ្លួនយកភ្លើងដុតបំផ្លាញបន្ទាយនោះ ភ្លើងក៏ឆេះដាលពលឡើង ស៊ីឡុងឃើញដូច្នោះក៏ភ័យណាស់ លើកទាហានរត់ចោលបន្ទាយនោះទៅ ឯអង់បេងក៏រត់ឆ្ពង់ទន្ទេហាន់ស៊ុយទៅស្ម័គ្រចូលនៅនឹងជូឡុងៗ ក៏នាំយកខ្លួនអង់បេង ចូលទៅគំនាប់ឡៅពី អង់បេងជំរាបឡៅពីថា កងតំបន់ហាន់ស៊ុយនេះ ខ្ញុំបាទដឹងស្គាល់យល់ច្រកល្ហកផ្លូវទាំងអស់ ៗ

ឡៅពីឮដូច្នោះ ក៏ពេញចិត្តណាស់ ទើបនិយាយថា អ្នកមកនៅនឹងយើងហើយ ការដែលយើងនឹងគិតវាយយកស្រុកហាន់តុងនោះ ឃើញថាគង់នឹងបានសម្រេចដូចសេចក្តីប្រាថ្នាហើយក៏តាំងអង់បេងឲ្យធ្វើជានាយទាហានសម្រាប់នាំផ្លូវធ្វើការសង្គ្រាមតទៅ ឯស៊ីឡុងរត់ទៅដល់ចុងទូហើយ

ក៏ទូលកប់រៀបសេចក្ដីថា តឡូអែងបេងចេញជាក្បត់តេចូលទៅនៅទីង ឡៀតហើយ ។

ចូឆូ ឮដូច្នោះ ក៏ខឹងណាស់ ទើបប្រមូលពលទាហានបានព្រមព្រៀង ហើយ ទីងលើកទៅវាយដណ្ដើមយកបន្ទាយដំបន់ហាន់ស៊ុយមកវិញ ឯដូឡុងលុះមានជ័យជំនះហើយ ក៏ប្រុងប្រៀបតាំងបន្ទាយមាំមួនណាស់លុះឮដំណឹងថាចូឆូទីងលើកទ័ពមកវាយ ឃើញថាខ្លួនតាំងបន្ទាយនៅទីនោះពុំស្រួល ក៏ប្រមូលពលទាហានលើកថយទ័ពត្រឡប់ទៅតាំងនៅក្បែរខេត្តហាន់ស៊ុយ ត្រើយខាងលិច ហើយឲ្យកបន្ទាយជាមាំមួននៅទីនោះ ។

ឯឡៀតនោះ លុះដល់ថ្ងៃរសៀលក៏នាំខុនបេងចេញត្រួតមើលប្រកផ្លូវខុនបេងថា ដំបន់ហាន់ស៊ុយនេះ មានភ្នំនៅខាងជើងជាច្រើនស្រទាប់ល្មមទីងបញ្ចុះទាហានបាន ១.០០០ ប៉ុយ ហើយក៏នាំគ្នាវិលមកចូលបន្ទាយវិញ ទើបឲ្យហៅដូឡុងចូលមកបង្គាប់ថា អ្នកឯងត្រូវនាំទាហាន ៥០០ ឲ្យយកស្គរនឹងត្រែទៅប្រចាំការនៅទីជើងភ្នំខាងលើទឹក កាលណាដល់ពេលកណ្ដាលយប់ បើឮស្នូរផាវអុចក្នុងបន្ទាយយើងជាសញ្ញាហើយ ត្រូវឲ្យផ្លុំត្រែវាយឃោះគោះគងទូងស្គរឲ្យឮអឺងកងក្នុងវាលនោះ តែកុំបីចេញច្បាំងឡើយ ខណៈនោះដូឡុងក៏តាំងនាំទាហានទៅប្រចាំការ តាមពាក្យខុនបេងបង្គាប់ ឯខ្ញុំខុនបេងនោះ លុះរសៀលត្រដាក់ក៏ឡើងទៅនៅលើកំពូលភ្នំខ្ពស់ ចាំមើលកលការចូឆូតេទីងធ្វើប្រការម្ដេច ។

លុះវេលាព្រឹកតាហានចូលទីងចេញចម្បាំង ទៀតពីកយាក់វាំងពួកតាហានឡើងទៅសម្ដុកចន្ទាយមិនឲ្យចេញតស៊ូគ្នា តាហានចូលេយើញជ្រ ចេញនោះ គិទគតិតាល់ណាស់ លុះដល់ពេលព្រលប់ក៏នាំគ្នាត្រឡប់វិលទៅវិញ ដល់ពេលកណ្ដាលអធ្រាត្រ ខុងបេងមិនបានឃើញតាហានចូលទៅកុងបន្ទាយ តាំងពីថ្ងៃត្បូងក៏គ្មានដងឹតសូរឲ្យតាំងអស់ ក៏ឲ្យតាហានអចផាវជាសញ្ញាឡើងផូឡុងដែលតាំងពួនបង្កប់នោះ លុះពេលបានឮជ្រោះ ក៏ឲ្យតាហានកំយឃោះគោះគងវូងកោជុំត្រែឡើងព្រមគ្នា ចូចបានឮក៏ភ័យណាស់ សំគាល់ថាទៀតពីទៅប្លន់បន្ទាយ ទើបឲ្យតាហានចេញទៅមើល តាហានក៏វិលត្រឡប់ទៅប្រាប់ចូចវិញថា ខ្ញុំបាទចេញទៅមើលមិនឃើញមានអ្វីសោះ ។

លុះដល់ពេលយប់ស្ងាត់ ទើបឮសម្លេងឃោះគងខួងកោជុំត្រែអុចផាវ សន្ធឹកសន្ធាប់ជាចំឡែកណាស់ តាំងពីយប់នោះវិលទៅទៀតដល់៣យប់ ក៏មិនបានឈប់សំរាកបានសោះ ចូចនោះក៏ចេះតែព្រួយបារម្ភពន់ប្រមាណ ទើបឲ្យថយទ័ពត្រឡប់ពីទីនោះចម្ងាយប្រហែល ៣០០ សិន (១២ គ.ម.) ក៏តាំងបន្ទាយនៅទីវាលធំទូលាយមួយអន្លើ ខុងបេងត្រឡេកទៅឃើញក៏អស់សំណើច ហើយនិយាយនឹងទៀតពីថា ចូចនេះល្អតែខាងការរណរង្គសង្គ្រាមម៉្យាង ត្រង់ឧបាយសឹកទឹកមិនយល់សោះ ថៃ:ន សូមអញ្ជើញលោកទៅតាំងបន្ទាយនៅត្រើយម្ខាងនោះចុះ ។

ទៀតពីឮដូច្នោះក៏សួរថា លោកនឹងឲ្យយើងទៅនោះ ដោយឧបាយ

កលគិតយ៉ាងម្ដេច? ខុនបេងថា ខ្ញុំគិតទុកថាបើចុច្ចូលើកទ័ពមកគ្រានេះ ខាងលោកនឹងឡៀហង, បេងគាត ឲ្យធ្វើជាបែកទ័ពបោលបន្ទាយទឹង គ្រឿងសាស្ត្រាវុធចេញ ខាងខ្ញុំនឹងត្រៀមទាហានទុកឲ្យព្រមទាំងបែកស្ដាំ ទឹងឆ្វេងទៅចាំឯកំពង់ បើឃើញខ្ញុំបក់ទង់ជាសញ្ញា ចូរឲ្យអ្នកត្រឡប់មុខ វាយចុះ ឡៀតយល់ឃើញត្រូវ ទើបនាំទាហានឆ្លងទៅប្រញាប់ ។

ឯចុច្ចូនោះ លុះឃើញឡៀតឆ្លងទៅតាំងបន្ទាយដូច្នោះក៏ទឹកពិភាល់ណាស់ ទើបសរសេរសំបុត្រចាត់បំរើឲ្យនាំទៅឲ្យឡៀតសេចក្ដីថា នឹងណាត់ពេលច្បាំងគ្នាវេលាណា ខុនបេងសរសេរតប នឹងច្បាំងគ្នាវេលាព្រឹកស្អែក លុះព្រឹកឡើងទាំងសង្ខាងក៏លើកទាហានចេញទៅឈប់នៅមុខគ្នានៅកៃសានព្រមគ្នាទាំងសង្ខាង ចុច្ចូជិះសេះចេញទៅឈរនៅក្បែរទង់ចម្បាំង ឲ្យទាហានវាយស្គរ ៣ បទ ហៅឡៀតចេញទៅនិយាយគ្នា ឡៀតក៏យកឡៀហង, បេងគាត់ នាំទាហានស្រុកសែឈួន ដែលបានមកទុកនោះចេញទៅជាមួយ ចុច្ចូឃើញឡៀតចេញមកក៏យកសែសេះចង្អុលមុខហើយជេរឡៀតថា អាមនុស្សអកតញ្ញូបង់សត្យបាត់សុចរិតគិតមកទុរយសទ្រុស្ដក្បត់នឹងម្ចាស់ផែនដី ។

ឡៀតតបថា អាណាមកពោលបង្កាច់គេចម៉ើលអាយយើងដូច្នេះមិនត្រូវសោះ ព្រោះយើងជាពូជព្រះពង្សព្រះចៅហៀនគេជាម្ចាស់កាន់ព្រះដម្រាស់ចេញមកប្រាប់អាសត្រូវពងសម្បត្តិប៉ុណ្ណោះ អាណាធ្វើខុសសម្លាប់

ព្រះអគ្គមហេសីម្ចាស់ផែនដីដោយអំណាចចិត្ត ប្រព្រឹត្តទុច្ចរិតគិតលើខ្លួនជាស្តេចសំរេចរាជការ បៀតបៀនប្រាថ្នាយករាជសម្បត្តិចិត្តទ្រនង់ស័ក្តិអានោះឯងមក លើកទុកដាក់ខ្លួនជាគ្រូវិញមិនពេញជាក្បត់ទេឬ? ចុច្ចដូច្នោះក៏ខឹងណាស់ ប្រើស៊ីឡុងឲ្យចូលចាប់ឯងនឹងឡៅពីៗ ក៏ប្រើឡៅហាងឲ្យចេញរង់ទទួល ។

ខណៈកាលឡៅហាងនិងស៊ីឡុងចូល ប្រយុទ្ធគ្នាដោយក្មេងលំពែងឡៅពីក៏គេចលៀសចូលទៅនៅក្នុងកងទ័ព លុះឡៅហាងតស៊ូនិងស៊ីឡុងពុំបាន ឡៅពីក៏ធ្វើជាបែកទ័ពគេឡប់រត់ទៅ ចូចូឃើញដូច្នោះក៏បង្គាប់ទា-ហានទាំងពួងថា បើនរណាចាប់ខ្លួនឡៅពីបាន យើងនឹងឲ្យបំណាច់ធ្ងន់ធ្វើជាចៅហ្វាយស្រុកសែឈ្មួន ទាហានទាំងពួងឮដូច្នោះក៏នាំគ្នាស្រែកហ៊ោដេញតាមឡៅពីទៅ ។

ឯឡៅពីនិងទាហានទាំងពួងធ្វើជាបាក់ទ័ពគេឡប់រត់ទៅអស់ ពោលគ្រឿងសាស្ត្រាវុធនៅក្នុងទីស្នាមចម្បាំង តាំងតែរត់តម្រង់ទៅតាមផ្លូវសំដៅទៅកលហាន់ស៊ុយ ទាហានចូចូបានបន្ទាយក៏សប្បាយចិត្តណាស់ចូលដណ្តើមយកទ្រព្យរបស់និងគ្រឿងសាស្ត្រាវុធប្រពាក់ប្រពូន ចូចូក៏ឲ្យវាយឃ្មោះគោះគងខូងគេហៅទាហានឲ្យឈប់ ទាហានទាំងពួងថា យើងខំនឹងដេញតាមចាប់ឡៅពីឲ្យបាន ហេតុម្តេចក៏លោកហាមឃាត់វិញ ចូចូថា យើងពិគ្រោះមើលកលការឃើញខុសប្លែកណាស់ ដែល

ទៀតពីជួងវរខ្មែរមកតាំងបន្ទាយក្រោយខាងណោះ មិនទាន់ធ្វើការយុទ្ធប៉ុន្មាន ក៏បែកទៅគួរឲ្យសង្ស័យ ខ១. ដែលហៅលោះសេះទិងគ្រឿងសាស្ត្រាវុធទុកក្នុងបន្ទាយជាច្រើនក៏គួរឲ្យសង្ស័យ ខ១, ហេតុនេះត្រូវតែយើងរំសាយកងទ័ពចេញសិន កុំអាលឲ្យទាហានទាំងពួងរើសយកទ្រព្យរបស់ទាំងនេះឡើយ បើនរណាហើយមិនស្ដាប់យើងនឹងសម្លាប់ជីវិតបង់ ថាហើយក៏រំសាយកងទ័ពត្រឡប់ទៅ ។

ខណៈកាលចូចូរំសាយទ័ពត្រឡប់ទៅនោះ ខុងបេងក៏ឲ្យលើកទង់ត្រីទៀងជាសំគាល់ ទៀតពីឃើញក៏បរពលចូលមកវិញឲ្យហ៊ងតុងចេញជាប៉ែកស្ដាំ ឲ្យជូឡុងជាប៉ែកឆ្វេងវាយខ្ទប់ប្រសព្វគ្នាទាំងសងខាង ចូចូមិនអាចតស៊ូបានក៏បែកទ័ពត្រឡប់រត់ទៅ ខុងបេងក៏ឲ្យដេញតាមទៅទាំងពេលកណ្ដាលយប់នោះ ចូចូរត់ទៅដល់ជិតស្រុកទៀតគេងក្រទៀកឃើញពន្លឺភ្លើងឆេះឡើងក្នុងស្រុកគ្រប់ទិសទាំង ៤ ក៏ភ័យណាស់ ទើបដឹងច្បាស់ថា ស្រុកនោះខូចអន្តរាយដោយសត្រូវអស់ហើយ ព្រោះពីដើមនោះខុងបេងប្រើជៀមង៉ាន់ឲ្យទៅក្បាស្រុកប៉ាសេជាជំនួសអ៊ុយអៀន ហើយឲ្យទៀវហ៊ុយ អ៊ុយអៀន ២ នាយនោះ លើកទៅវាយស្រុកឡាំគេងបាន ចូចូក៏រត់ទៅតាមផ្លូវសំដៅទៅគយអេងបេងគួន ។

ឯទៀតពី-ខុងបេងដែលលើកទាហានតាមចូចូនោះ ក៏ចូលទៅក្នុងស្រុកឡាំគេង ហើយបញ្ចុះបញ្ចូលទាហានទិងអាណាប្រជានុរាស្ត្រឲ្យនៅ

ជាប្រក្រតី ថ្ងៃមួយលៀវពីសួរខុងបេងថា ដែលចូឆូលើកទ័ពមកធ្វើការសង្គ្រាមនឹងយើងគ្រានេះហេតុម្តេចក៏គាត់គាំងបាញ់យើងនោះដោយប្រការអ្វី ខុងបេងឆ្លើយថា ចូឆូនោះជាមនុស្សមានសន្តានចិត្ត មិនទទឹងទួនរមែងគិតសង្ស័យច្រើន ឃើញចំណានតែប្រើទាហានចូលច្បាំងម្យ៉ាង ហេតុដូច្នេះទើបថ្វាះធ្លាយបាញ់យើងដោយងាយ លៀវពីថា ឥឡូវឃើញថាចូឆូនឹងរត់ទៅនៅគយអេងបេងគួនហើយ មានពួកតែមួយ លោកនឹងគិតឧបាយប្រការម្តេចទើបនឹងបានខ្ទួនចូឆូនោះ? ខុងបេងថាខ្ញុំគិតទុកស្រេចហើយទើបឲ្យទៀវហ៊ុយនិងអ៊ុយអៀននាំទាហានទៅជា ២ ផ្លូវចាំស្ទាក់ស្កាត់កាត់យកស្បៀងចូឆូឲ្យបាន ហើយទើបប្រើហាងតុងនឹងជូឡុងទៅដុតផ្លូវក្បែរភ្នំដែលចូឆូនឹងទៅនោះចេញ នាយទាហានទាំង ៤ ពួកទទួលបង្គាប់ហើយក៏លាលៀវពី ខុងបេងលើកទាហានឲ្យមនុស្សនាំផ្លូវទៅ ៗ

ចូឆូទៅនៅកងបន្ទាយអេងបេងគួន ប្រើទាហានឲ្យទៅយាមល្បាតមើលគ្រប់ដំបន់ ទាហានល្បាតវិលទៅជំរាបចូឆូថា ឃើញទាហានលៀវពីកាត់ដើមឈើបិទផ្លូវតូចនឹងផ្លូវធំជិតទាំងអស់ ហើយយកភ្លើងដុតប្រចាំមិនដឹងថាទាហានលៀវពីនឹងពួនបង្កប់នៅទីណាខ្លះ មិនដឹងប្រាកដសោះចូឆូឮដូច្នោះក៏ចេះតែគិតសង្ស័យ ៗ

ខណៈនោះមានមនុស្សទៅប្រាប់ចូឆូថា ទៀវហ៊ុយ, អ៊ុយអៀនលើកទាហានទៅស្កាត់នឹងដណ្តើមយកស្បៀងរបស់យើងហើយ ចូឆូក៏សួរ

ទាហានចាំងតួងថា នរណានឹងអាសាចេញទៅតស៊ូនឹងទៀវហ៊ុយ,អ៊ុយអៀនបាន ខៅជូឆ្លើយថាខ្ញុំបាទនឹងសុំអាសាទៅតស៊ូឲ្យបាន ចូជូក៏ចាត់ទាហានឲ្យខៅជូ ១.០០០ ខៅជូក៏រៀបលើកចេញទៅតាមផ្លូវគយអេងបេងគួន ដើម្បីចាំការពាររក្សាស្បៀងមិនឲ្យជាអន្តរាយ ។

ឯបណ្ដាភ្នាក់ងារដែលឃុំរក្សាស្បៀងនៅទីនោះ ឃើញខៅជូទៅដល់ក៏សប្បាយចិត្តណាស់ថា បើយើងមិនបានអ្នកមកជួយ ក៏ឃើញថានឹងទៅមិនដល់គយអេងបេងគួនទេ ទើបយកស្រាបាយនិងសាច់ជ្រូកមាន់ទាមកលៀងឲ្យខៅជូបរិភោគ ខៅជូផឹកស្រាស្រវឹងខ្លាំងណាស់ ក៏ដើរនាំមុខរទេះស្បៀងទៅ លុះទៅដល់កណ្ដាលផ្លូវ ភ្នាក់ងារដែលនាំស្បៀងក៏និយាយនឹងខៅជូថា វេលានេះល្ងាចហើយខាងមុខដំបន់ស្រុកប៉ោដវមានភ្នំនៅក្បែរមាត់ផ្លូវកណ្ដាលវាល យើងនឹងទៅឥឡូវនេះ ក្រែងមានភ័យអន្តរាយ ។

(នៅមានត)



ព្រះវិហារវត្តពោធិប្រផុំផន ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

# ប្រវត្តិវត្តពោធិ៍ប្រជុំជន

## ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

### ជាវត្តគណៈមហានិកាយ

លោកចាប-ពិន រៀបរៀង

វត្តនេះ តាំងពីចាប់ផ្ដើមកសាងឡើង រហូតមកដល់ព.ស. ២៥ ៨ គ.ស. ១៩៦៥ ប្រមាណជាង ១០០ ឆ្នាំហើយ ។

ដំបូងបង្អស់ ទីវត្តនេះ ឋិតនៅត្រង់ទួល ១ ហៅទួលអូរខ្សាច់ ជិតឆ្នេរទន្លេមេគង្គ ត្រើយខាងត្បូង អ្នកស្រុកហៅថា វត្តអូរខ្សាច់ ។, តែនាមជាផ្លូវការនៃវត្តនេះបានផ្លាស់ប្ដូរជាច្រើនលើក មានឈ្មោះថាវត្តពោធិ៍អស្ចារ្យ ជាដើម និងផ្លាស់ប្ដូរចៅអធិការតៗគ្នាជាលំដាប់, តាំងពីដំបូងមកដល់ឆ្នាំ១៩៦៥ មានចៅអធិការ ៨ រូបហើយ ដូចរៀបរាប់ខាងមុខនេះ

ទី១ ចៅអធិការព្រះនាមសោម, លោកគ្រូអង្គនោះទទួលអនិច្ចធម្មក្នុងសមណៈភេទ ។

ទី២ ចៅអធិការព្រះនាមសុខ, លោកគ្រូអង្គនេះសឹកចាកសិក្ខាបទ ។

ទី៣ ចៅអធិការព្រះនាមប៉ែន, លោកគ្រូអង្គនេះរុះរើវត្តទៅសាងនៅត្រង់មាត់អូរ ១ ហៅអូរអុងធារ ឈៀងត្បូងសានវត្តចាស់ ចម្ងាយប្រមាណ ៨០០ម៉ែត្រសន្មតនាមថា "វត្តពោធិ៍អស្ចារ្យ" សាងហើយលោកសឹកចាកសិក្ខាបទទៅ ។

ទី៤ ចៅអធិការព្រះនាមឯក(១),លោកគ្រូអង្គនេះជំនាញខាងវិបស្សនាធុរៈលោកបានរៀបចំវត្តស្រួលបួលហើយ ក៏សឹកចាកសិក្ខាបទទៅ ។

ទី៥ បន្ទាប់ពីលោកគ្រូព្រះនាមឯកមក ពុទ្ធបរិស័ទជើងវត្ត បានជ្រើសតាំងលោកគ្រូព្រះនាម គង់-សួស ជាចៅអធិការ លោកគ្រូអង្គនេះបានចាត់ការស្ថាបនាក្នុងវត្តច្រើនយ៉ាង ជាអាទិ៍ គឺ

-សាលាបុណ្យគ្រឿងឈើប្រក់ក្បឿង, រោងឧបោសថគ្រឿងឈើប្រក់ក្បឿង ។

-ព្រះពុទ្ធរូបអង្គធំ ដោយមានលោកឧកញ៉ាសុវត្ថិកោគាសាម-ហ៊ូ ជាស្ថាបត្យករ ។

-ធ្វើបុណ្យបញ្ចុះសីមា ។ល។

លោកគ្រូអង្គនេះ ជំនាញខាងវិបស្សនាធុរៈ លោកបានប្រព្រឹត្តធុតង្គនៅក្នុងព្រៃជាយូរឆ្នាំ ។

ដោយគុណសម្បត្តិនេះ ក៏ខ្ចរខ្ចាយកិត្តិស័ព្ទជ្រាបទៅដល់សម្តេចព្រះមហាសង្ឃរាជព្រះនាមទៀង សង្ឃនាយកគណៈមហានិកាយ, សម្តេចទ្រង់ប្រោសប្រទានសមណៈស័ក្តិ ជាព្រះវិសុទ្ធមុនីសាសនវង្ស ទីពជា-គណៈកិត្តិយស ។

ក្រោយមក ដោយមានភ័យអំពីទឹកទន្លេមេគង្គ ហូរច្រោះច្រាំងបាក់ដីវត្ត លោកបានចាត់ការរុះរើវត្តពោធិអស្ចារ្យទៅសាងជាថ្មី នៅត្រង់តំបន់

---

១- ជាបិតារបស់លោកគ្រូធម្មិស្សរោ ឯក-ញឹម នៅវត្តពិភពរង្សី ភ្នំពេញ សព្វថ្ងៃ ។

១ ហៅទួលទ័ពលាវ ចម្ងាយប្រមាណ ៤ គីឡូម៉ែត្រពីវត្តចាស់ ហើយផ្លាស់នាមវត្តទៅជា «វត្តពោធិ៍ប្រជុំជន» ។

វត្តនេះ ឋិតនៅទួលទ័ពលាវបាន ៣០ ឆ្នាំ មិនទាន់តាំងបានសាងវិហារជាដុំដៅឡើយផង ក៏ព្រះវិសុទ្ធមុនីសាសនវង្ស គង់-សួស ទទួលអសញ្ញកាលទៅក្នុងព្រះជន្មាយុ ៨៦ឆ្នាំ ។

ទី៦ បន្ទាប់ពីលោកគ្រូព្រះវិសុទ្ធមុនីសាសនវង្សគង់-សួស ពុទ្ធបរិស័ទជើងវត្ត ព្រមទាំងព្រះភិក្ខុសង្ឃក្នុងវត្ត បានព្រមព្រៀងនិមន្តលោកគ្រូទិត-ចន្ទ ធ្វើជាចៅអធិការ ។ ចៅអធិការអង្គនេះ គ្រប់គ្រងវត្តបានតែត្រឹម ២ ឆ្នាំ ក៏ទទួលអនិច្ចធម្មទៅ ។

ទី៧ លំដាប់ពីលោកគ្រូទិត-ចន្ទមក ទីចៅអធិការវត្តពោធិ៍ប្រជុំជនត្រូវបានទៅលោកគ្រូព្រះនាម អៀង-មៅ ។ គួរអនិច្ចាណាស់លោកគ្រូអៀង-មៅធ្វើចៅអធិការបានតែត្រឹម ២ ឆ្នាំក៏ទទួលអនិច្ចធម្មទៅទៀត ។

ទី៨ បន្ទាប់ពីលោកគ្រូទិត-ចន្ទ ពុទ្ធបរិស័ទជើងវត្តព្រមទាំងព្រះភិក្ខុសង្ឃបានព្រមព្រៀងគ្នាជាឯកច្ឆន្ទជ្រើសយកលោកគ្រូព្រះនាមយក់-អ៊ុនធ្វើជាចៅអធិការវត្តពោធិ៍ប្រជុំជននេះឡើងរហូតដល់សព្វថ្ងៃ ។

ដល់មកសម័យលោកគ្រូ យក់-អ៊ុន ជាចៅអធិការក៏ភ័យអំពីទឹកទន្លេមេគង្គក៏កើតមានម្តងទៀត, ទឹកហូរច្រោះច្រាំងបាក់ស្រុតជិតដល់វត្ត វត្តពោធិ៍ប្រជុំជនក៏ត្រូវរុះរើទៀត មកឋិតនៅត្រង់កន្លែងសព្វថ្ងៃនេះ ។

ឯលោកគ្រូយក់-អ៊ុន គាំងពីបានធ្វើចៅអធិការមក លោកបានយកព្រះទ័យទុកដាក់ចំពោះការកសាងវត្តពោធិប្រជុំជន ជាកេរ្តិ៍ដំណែលពីគ្រូឧបជ្ឈាយ៍របស់លោកឡើងរុងរឿងចម្រើនជាលំដាប់ ជាអាទិ៍គឺលោកព្យាយាមបាត់ការធ្វើវិហារអំពីបេតុងអារម៉េ ដោយបច្ច័យអ្នកស្រុកជើងវត្តនិងបុណ្យកឋិនបុណ្យផ្កា, អស់រយៈវេលា ៩ ឆ្នាំ ទើបបានហើយស្រេចជារូបកងវិហារ ដ៏មានភាពល្អសមសួនតាន់សម័យនិយម ដូចមានរូបភាពដែលថតយកមកដាក់នៅទំព័រខាងដើមនេះ, ហើយលោកបានចាត់ចែងបញ្ចុះសីមា ដើម្បីជាឧបោសថាគារ សម្រាប់ព្រះសង្ឃធ្វើសង្ឃកម្មតាមពុទ្ធានុញ្ញាតតទៅ និងបាត់ការធ្វើបុណ្យឆ្លងយ៉ាងឧឡារិក ជាកិច្ចបង្ហើយបុណ្យខាងផ្នែកវិហារត្រឹមប៉ុណ្ណោះ, ហើយលោកនេះតែព្យាយាមស្ថាបនាកិច្ចការតូចធំផ្សេង ១ ត ១ តទៅទៀត ។

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

## ដែលមាននៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

លោកញ៉ុក-ថែម រៀបរៀង

## កថាមុខ

ដោយយល់ឃើញថា ឯកសារផ្សេងៗ ជាភាសាជាតិ ដែលបុរាណាចារ្យ បានចិតចំរៀបរៀងជាកំណាព្យក្តី ជាពាក្យរាយក្តី ហើយបានចារចារឹកលើស្លឹករឹតក្តី សរសេរកត់ទុកដោយទឹកខ្មៅចិនលើសន្លឹកក្រាំងក្តីសឹងមានសេសសល់នៅក្នុងហោត្រៃនៃវត្តទាំងឡាយ និងនៅក្នុងបណ្ណាល័យនានា ជាពិសេស ក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ ក៏មានចំនួនច្រើនស្តុកស្តម្ភសមដែរ ។

ដោយយល់ឃើញថា កវីក្តី អ្នកនិពន្ធក្តី ដែលចិតចំនិពន្ធ រឿងរ៉ាវឬអត្ថបទច្បាប់ផ្សេងៗ ទុកជូនកូនចៅរបស់លោកឲ្យសិក្សាប្រតិបត្តិត ៗ មកយូរអង្វែងហើយ ទោះបីស្នាដៃនោះៗ កន្លងហួសសម័យនិយមយ៉ាងណាក៏ដោយ ក៏គួរតែកូនចៅជំនាន់ក្រោយ ៗ ថែរក្សាទុកដោយល្អដែរ មិនត្រូវបោះបង់ចោលឬបំផ្លាញចោលសោះឡើយ ។ ផ្ទុយទៅវិញ គួរតែកូនចៅជាន់ក្រោយ ស្រង់យកឯកសារសំខាន់ៗខ្លះ ដែលមានប្រយោជន៍ យកមកបោះពុម្ពផ្សាយ សំរាប់សិក្សារៀនសូត្រ ដើម្បីថែរក្សាការពារនិងពង្រីកវប្បធម៌ជាតិ ឲ្យបានចំរើនលូតលាស់ឡើងតាមកាលៈទេសៈ ។

ដោយយល់ឃើញថា ក្នុងសម័យអាណានិគមនិយមបរទេសក្នុងកំឡុងជិតមួយសតវត្ស វប្បធម៌ជាតិ មានចលនាអក្សរសាស្ត្រជាដើម បានធ្លាក់ចុះក្នុងស្ថានភាពរៀវរេកយ៉ាងខ្លាំង ដោយពួកអាណានិគមនិយមបានបង្ខំឲ្យកូនខ្មែរ ខិតខំសិក្សា ស្រឡាញ់រាប់អាន លើកតំកើងតែវប្បធម៌របស់ជាតិគេតែប៉ុណ្ណោះ ។

ដោយយល់ឃើញថា ក្រោយប្រទេសជាតិមាតុភូមិបានទទួលឋានៈជារដ្ឋឯករាជ្យពេញបរិបូណ៌មក គ្រូនិងសាស្ត្រាចារ្យខាងផ្នែកខ្មែរព្រមទាំងសិស្សានុសិស្សទាំងឡាយបានយកចិត្តទុកដាក់ ចង់ចេះចង់ដឹងនូវវប្បធម៌ អារ្យធម៌ជាតិ មានចលនាអក្សរសាស្ត្រជាដើម កាន់តែមានចំនួនច្រើនកើនឡើងជាលំដាប់ ។ ហេតុដូច្នេះហើយ បានជាក្នុងសម័យបច្ចុប្បន្ននេះ សិស្សនិងនិស្សិតទាំងឡាយភាគច្រើន មានចំណេះចេះដឹងភាសានិងអក្សរសាស្ត្រជាតិគាប់ប្រសើណាស់ ផ្ទុយស្រឡះកាលពីជំនាន់សម័យអាណានិគមនិយមបរទេស ។

ទោះបីក្នុងកាលៈទេសៈបច្ចុប្បន្ននេះ មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ មិនទាន់មានថវិកាចំណាយសំរាប់បោះពុម្ពផ្សាយ នូវឯក-សារផ្សេងៗ ដែលជាស្នាដៃរបស់បុរាណាចារ្យពីព្រេងនាយមកឲ្យបានសព្វគ្រប់ក៏ពិតមែន ប៉ុន្តែការស្រង់យកមកតែខ្លីៗ នូវអត្ថបទៈផ្តើមនិងបញ្ចប់នៃឯកសារនីមួយៗ ព្រមទាំងប្រាប់ចំណងជើងរឿង នាមអ្នកនិពន្ធ កាល

បរិច្ឆេទ របៀបនិពន្ធ លក្ខណៈឯកសារនិងប្រភពរឿង ព្រមទាំងទីតំកល ទុកនូវឯកសារនោះ ៗ ក៏មានប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវជា បង្គួរដែរ ជាពិសេសចំពោះសិស្សនិងនិស្សិតផ្នែកខ្មែរនៅវិទ្យាស្ថានជាតិ គរុកោសល្យនិងនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដែលចង់ចេះដឹងឲ្យបានវែងឆ្ងាយតទៅទៀត ក្រៅអំពីឯកសារក្នុងកម្មវិធី សិក្សា ៗ

ឯកសារទាំងឡាយ ជាសាស្ត្រាស្លឹករឹតក្តី ជាក្រាំងក្តី ដែលខ្ញុំបាន ស្រង់យកតែសេចក្តីខ្លី ៗ សម្រាប់ចុះផ្សាយក្នុងទីនេះ ខ្ញុំបានបញ្ជាក់ ប្រាប់ ចំណងជើងរឿង នាមអ្នកនិពន្ធ កាលបរិច្ឆេទជាដើមសព្វគ្រប់ លើ ឯកសារនិមួយ ៗ, ប៉ុន្តែមានឯកសារជាច្រើនដែលរកនាមអ្នកនិពន្ធនិងកាល- បរិច្ឆេទពុំទាន់ឃើញ ដូចជាពួកសាស្ត្រាច្បាប់ផ្សេងៗជាដើម ៗ

ខ្ញុំសូមបញ្ជាក់ថា មានឯកសារខ្លះ មានចំណងជើងផ្សេងៗគ្នាដល់ ២·៣ អទ្ទើក៏មាន ឧទាហរណ៍ រឿងទុំទាវ មានឯកសារដល់ ៣ គឺជា ក្រាំង ១ ជាស្លឹករឹត ២ ៗ ច្បាប់សរសេរលើសន្លឹកក្រាំងដាក់ចំណងជើងថា «រឿងទាវឯក» ៗ ឯច្បាប់ជាសាស្ត្រាស្លឹករឹតដាក់ចំណងជើងថា «រឿង ទុំទាវ» ទៅវិញ ឯកសារទាំងពីរនេះ របស់បណ្ណាល័យពុទ្ធសាសន- បណ្ឌិត្យ ៗ ឯច្បាប់សាស្ត្រាស្លឹករឹត ១ ទៀតដាក់ចំណងជើងថា «សាស្ត្រា ទាវឯក» ឯកសារក្រោយនេះបានមកពីវត្តព្រែកក្រើសខេត្តកណ្តាល ៗ

ឯកសារនៃរឿងតែមួយនេះ មានន័យស្របគ្នាខ្លះ លើសខ្លះពីគ្នាខ្លះ ៗ
ប្រហែលកើតឡើង ដោយការនិពន្ធតែងក្នុងកាលៈទេសៈផ្សេងគ្នា ៗ

ឯឯកសាររឿងរាមកេរ្តិ៍ខ្មែរទាំងរឿងរ៉ាវផ្សេង ៗ ខ្លះទៀត ដែលមាន
លក្ខណៈ ដូចខាងលើគឺជាក្រាំងក៏មានជាសាស្ត្រាស្លឹករឹតក៏មាន ៗ ឯពួក
សាស្ត្រាច្បាប់សោតទៀត ដែលមានចំណងជើងប្រហែល ៗ គ្នាក៏មានខ្លះ
ដែរ ឧទាហរណ៍ ដូចពួកសាស្ត្រាច្បាប់ក្រមមានច្រើនបែប ខ្លះដាក់ចំ
ណងជើងថា សាស្ត្រាច្បាប់ក្រម, សាស្ត្រាក្រមច្បាប់ សេចក្តីច្បាប់ក្រម
សេចក្តីតម្រាច្បាប់ក្រមជាដើម ៗ ច្បាប់ទាំងនេះពិតមែនតែមានចំណងជើង
ប្រហែលគ្នា ៗ ប៉ុន្តែមិនមែនមានពាក្យពេចន៍ឬអត្ថន័យស្របគ្នាទាំងអស់ទេ ៗ

មួយវិញទៀត ខ្ញុំសូមជំរាបអ្នកអានឬអ្នកសិក្សាស្រាវជ្រាវថា ឯកសារ
ជាសាស្ត្រាស្លឹករឹតនិងក្រាំង ដែលខ្ញុំបានខ្ចីពីបណ្ណាល័យពុទ្ធសាសន-
បណ្ឌិត្យយកមកពិនិត្យ ស្រង់ចម្លងអត្ថបទខាងដើមបន្តិចខាងចុងបន្តិចនេះ
ខ្ញុំមិនបានពិនិត្យមើលដោយសព្វគ្រប់ទេ ព្រោះឯកសារខ្លះវែងពេក ដែល
ខ្ញុំគ្មានពេលនឹងពិនិត្យឲ្យបានចប់ចុងចប់ដើម ៗ ដូច្នេះការប្រមូលឯកសារ
ផ្សេង ៗ យកមកបោះពុម្ពផ្សាយនេះ ដើម្បីជូនជាពត៌មានថា តើឯកសារ
នោះ ៗ មានតំកល់ទុកក្នុងទីណា ? កវីឬអ្នកនិពន្ធមាននាមដូចម្តេច ?
បាននិពន្ធអំពីកាលណា ? រឿងនោះ ៗ មានប្រភពដើមនៅឯណា ?
ឯកសារនោះ ៗ មានលក្ខណៈដូចម្តេច ? របៀបនិពន្ធដូចម្តេច (ជាពាក្យ

កាព្យឬពាក្យកាយ)? ប៉ុន្តែនៅមានឯកសារជាចំនួនច្រើនដែរ ដែលខ្ញុំរកនាមអ្នកនិពន្ធនិងកាលបរិច្ឆេទពុំទាន់ឃើញ ជាពិសេស ពួកសាស្ត្រាច្បាប់ផ្សេង ៗ នៅវិបផុត ខ្ញុំមានសេចក្តីសង្ឃឹមទុកជាមុនថា ការបោះពុម្ពផ្សាយបញ្ចូលឯកសារជាសាស្ត្រាស្លឹករឹតនិងជាក្រាំង ក្នុងទស្សនាវដ្តីអនុសំ-វច្ឆរៈនៃមហាវិទ្យាល័យនេះនឹងបានជាគុណប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវ ឬ និស្សិតផ្នែកអក្សរសាស្ត្រខ្មែរ ប្រសិនបើយើងចង់ឃើញចង់ពិនិត្យមើលនូវឯកសារដើមផ្ទាល់ ក៏អាចធ្វើទៅបាន ព្រោះខ្ញុំបានចង្អុលបង្ហាញលក្ខណៈឯកសារនឹងកន្លែងតំកល់ទុកសព្វគ្រប់អស់ហើយ ។

មួយវិញទៀត ខ្ញុំសូមអភ័យទោសអំពីសំណាក់អ្នកសិក្សាស្រាវជ្រាវនឹងអ្នកអានទូទៅថា ក្នុងគ្រាជាបឋមនេះ ខ្ញុំមិនទាន់បានចាត់រៀបចំឯកសារផ្សេង ៗ ទៅតាមក្រុមតាមពួកឬតាមជំនាន់នៃសតវត្សទេ ព្រោះការស្រាវជ្រាវរកឯកសារទាំងឡាយ ជាស្លឹករឹតក្តីជាក្រាំងក្តីមិនទាន់ចប់អស់ត្រឹមប៉ុណ្ណោះទេ នៅមានឯកសារជាច្រើនទៀត ដែលត្រូវយកមកបញ្ចូលក្នុងបញ្ជីឯកសារនេះជាបន្ទាប់ទៅទៀត ។

ប្រសិនបើការបញ្ជាក់របស់ខ្ញុំ នៅមានភ្លាំងភ្លាត់ឬគក់គួងខ្វះចំពោះនាមអ្នកនិពន្ធក្តី កាលបរិច្ឆេទក្តី ប្រភពរឿងក្តី ខ្ញុំសូមទទួលយកការកែតម្រូវ ឬគតិមានផ្សេង ៗ ដែលមានទាក់ទងនឹងឯកសារនេះ អំពីសំណាក់អស់លោក ដោយគោរពនិងដោយសុទ្ធចិត្តជានិច្ច ។

# សាស្ត្រាស្លឹករឹតនិងក្រាំង

បំណងជើង «សាស្ត្រាពោធិវង្ស» ។

អ្នកនិពន្ធ ព្រហ្មបរិរក្ខ ឬបរិរក្ខ(ព្រហ្ម)[១] ។

កាលបរិច្ឆេទ ថ្ងៃព្រហស្បតិ៍ កើតខែស្រាពណ៍ឆ្នាំម្សាញ់ ព.ស.២៤២៤ ច.ស. ១២៤៣ ។

របៀបនិពន្ធ ពាក្យកាព្យបុរាណ (បទកាកគតិ - ពំនោល - ព្រហ្មគីត កុដន្តលីលា ) ។

ប្រភពរឿង ក្រុមនិបាតជាតក ៥០០ ជាតក៍ ឬក្នុងរឿងហារយជាតក៍ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៨ ខ្សែចប់ជុំជាតក៍ គម្ពីរនេះពិតមែនតែមាន ៨ ខ្សែស្លឹករឹតចប់ ប៉ុន្តែចំនួនសន្លឹកក្នុងខ្សែនីមួយៗ មានចំនួនច្រើនណាស់ គឺពី ៥០ សន្លឹករហូតដល់ ១០០ សន្លឹកក៏មាន ដូច្នេះគប្បីយល់ថា គម្ពីរនេះជាមហាកំណាព្យមួយដែលជាស្នាដៃនៃកវីខ្មែរ ១ រូប កាលពីមួយសតវត្សមុននេះ ។ នៅពុទ្ធសាសនបណ្ឌិត្យ មានឯកសារជាសាស្ត្រាស្លឹករឹតនេះ ២ គម្ពីរ លេខសាស្ត្រា ៥៤៧-៥៤៨ ។

អត្ថបទដើម នេះបទកាកគតិ ។ អហំអញខ្ញុំ គោត្រឈ្មោះព្រហ្ម- បរិរក្ខ

---

១- រឿងនេះ បាននិពន្ធរឿងជាមហាកំណាព្យមួយទៀតដែលមានបំណងជើងថា «សាស្ត្រាស្កុគន្ធបើង» ជារឿងយ៉ាងវែង ១ ដែរ កាលពី ព.ស. ២៤២៩ ច.ស. ១២៤៨ ។

តែងនឹងមកនឹក រំលឹកសេចក្តី កាលព្រះជិនស្រី សារពេជ្ញ
សាស្តា ។ កាលព្រះអង្គគង់ អន្ទោលក្នុងវង់ វដ្តសង្សារ សាង
ព្រះបារមី ក្សត្រថ្ងៃប្រាថ្នា ឲ្យបានត្រាស់សា- រពេជ្ញសម្ពុទ្ធ ។
ហេតុនេះអញខ្ញុំ គន់គិតរំពៃ- ពឹងដោយវិញ្ញាត អង្គព្រះបារមី
សេចក្តីវិសុទ្ធ វិសេសដោយបទ លោកអត្ថទេស្នា ។ល។

**អត្ថបទបញ្ចប់** បរិបូណ៌ចប់និទាន ដូចមានក្នុងបាលីថា សុវេចកណ្ឋចរ
ចា បរិបូណ៌បានខ្សែ ៤ ។ លើកនាំជានិទាន រឿងនេះមានក្នុង
សេចក្តី និបាតនេះឯងនៃ ជុំជាតកសុវេចហោង ។ អញខ្ញុំខំ
ឧហាត ខំសង្វាតយកបុណ្យជូន ពុំគិតគេស៊ីផង ប្រឹងរៀប
រឿងព្រះសាស្តា ។ សរសើរព្រះទរនាថ យោងយកជាតិកាល
ណោះណា ទុកក្នុងព្រះសាសនា ដល់ ៥.០០០ វស្សាហោង ។

—X—

**បំណងជើង** „សាស្ត្រាជាវរឿង„

**អ្នកនិពន្ធ** អ្នកឧកញ៉ាចក្រី (កែវ) ដោយមានពញាវត្តកោសា (កែវ)
ជួយរៀបរៀងផង ។

**កាលបរិច្ឆេទ** ថ្ងៃសុក្រ ៧កើត ខែផល្គុណ ហេមន្តរដូវ ឆ្នាំរកា ព.ស.
២៣៨០ ម.ស. ១៧៥៩ ។

**របៀបនិពន្ធ** ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-ភុជង្គលីលា)

**ប្រភពរឿង** រឿនជាតកមួយ ? (គរីបានបញ្ជាក់ថា ចៅពញាស្រីអញ្ចិត (ស្រី) នាំយកមកអំពីស្រុកសៀម ) ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត មាន ៨ ខ្សែ ចប់ជុំជាតក់ ។ ឯកសារនេះនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញមាន២គម្ពីរ លេខសាស្ត្រា ៥៤៩-៥៥០ ។

**អត្ថបទផ្ដើម** នេះបទគាកគតិ ។ អហំនមោ នមក្កាពេ អញ្ជលិយំ សុសិរសា ពុទ្ធសេដ្ឋំ លោកុត្តមំ គមោនុពោ ។ នមធម្មំ សុខាវហំ អរិយៈបថោ ទេវជនំ មោក្ខមគ្គា សន្តិកពេ និយ្យានិកំ ។ នមសង្ឃំ វរវិសុទ្ធោ ទក្ខិណេយ្យំ សន្តិន្ទ្រិយ បុញ្ញក្ខេត្តំ អនាសវំ សមិទ្ធយោ ។

អហំវន្ទិ នមោបឆ្គំ នមស្សកាពេ ក្រញូក្រាបនមស្ការ វន្ទាសេដ្ឋា អញ្ជលិយោ លើកអញ្ជលី ។ សុសិរសា ផ្គុំហត្ថា ដាក់ដល់សិរសី ពុទ្ធសេដ្ឋា វន្ទាព្រះស្រី សារៈពេជ្ឈុនី ប្រសើរសួស្តីសម ។ល។

**អត្ថបទបញ្ចប់** ។ នេះបទព្រហ្មគីត ។ គិក្ខុអើយរម្លលគោត កម្មៅ ថោតឆុកគិតតែ កន្ទ្រឹសប្បស្សារៈ ជាទេវគ្គពុំឃ្នាក់ឃ្នា ។ ឯងនាឥសម្រេច ចេរឺឥច្បាត់យោនយកជាតិ ជាចិញ្ចាងឥអាច ប្រពន្ធទេវគ្គស្មោះ ។

ហៃអស់តាំងផងផង ចូរគ្រាប់គ្រង់ព្រះធម៌ថ្លៃ ព្រះធម៌នេះ

គាប់ក្រៃ ចូរមហាជនគន់គិតយក ។ និទាននេះទៀងទេ

គតាំងប្រៀបប្រាំតាំមក សំដែងចែងរៀរក តាមដោយបុណ្យបទបាលី ។

រៀងកល់តាល់ផល់ចប់ បរិបូណ៌គ្រប់សព្វសេចក្តី លុះដុំព្រះជាតិ

ហៅខ្សែប្រាប់សូរេចហោង ។

—X—

បំណងជើង «សាស្ត្រា ជយឆត្ត» ។

អ្នកនិពន្ធ បណ្ឌិត (គោ)(១) ។

កាលបរិច្ឆេទ ថ្ងៃពុធ ៧ កេចខែមាឃ ឆ្នាំខាល នក្សត្រ (ម.ស. .?(២)

របៀបនិពន្ធ ពាក្យកាព្យ (បទភាគគត.ពំនោល-ព្រហ្មគីត-កុដុម្ពលីលា)

ប្រភពរឿង ហាសយជាតក ឬ ៥០០ ជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត មាន ១០ ខ្សែចប់ដុំជាតក ។ ឯក

---

១- ឈ្មោះរបស់កវីនេះ មិនអាចយល់បានច្បាស់លាស់ទេ ព្រោះអត្ថបទដើមដែល បញ្ជាក់ឈ្មោះរបស់កវីប្រើពាក្យបាលី ប៉ុន្តែដាក់ណាត្យ ខ្មែរដូច្នេះ :-

អហំកោនាមៈ ចន្ទបត្តសម្មតោ នាមេរាជតោ សន្ទតិនាមយំ ។ (ល្បងប្រែសម្រួល ខ្ញុំឈ្មោះកោសន្មតហៅចន្ទបត្ត . . . ពីរឃ្លាទៀតមានន័យមិនសូវច្បាស់ ប្រ ហែលវិបត្តិដោយអក្ខរាវិរុទ្ធ ដោយការចារចម្លងត ៗ គ្នា ?) ។

សូមដាក់ជូនអ្នកស្រាវជ្រាវក្រោយៗ ទៀត ។

២- កាលបរិច្ឆេទបញ្ជាក់អំពីថ្ងៃ ខែ-ឆ្នាំ-វគ្គ ផ្ទាំងបញ្ហាទេ ប៉ុន្តែត្រង់សករាជវិញ មានបញ្ហាដែលត្រូវយកមកដោះស្រាយបញ្ជាក់ ព្រោះអត្ថបទដើមក្នុងសាស្ត្រាស្លឹករឹតដូច្នេះ ។

*សារនេះនៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញមាន ៣ គម្ពីរ លេខសាស្ត្រា ៣៥៣-៣៦៤-៣៦៥-គប្បីយល់ថា ជឿនជ័យខត្តនេះ ជាមហាកំណាព្យមួយទៀត នៃកវីខ្មែរយើង ។*

---

សុភមស្តុ សួស្តីស្រីសុ- ភមង្គលា ជយជយោ វិវេវិវ វិវេកាព្យា សសព្វបរមត្ថ ។ ទៀងទុកតំណ ឯកអាសប្បត សក់ខាលឥក្សត្រ មាឃមាសពារពុធ ប្រាកដទៀងទាត់ ប្រាំបីរោនរត្ន បវរសេដ្ឋោ ។ . . .

ក្រង់ឃ្លា “ឯកអាសប្បត” យើងគួរយល់ថា កវីចង់បញ្ជាក់អំពីសករាជ តើសករាជអ្វី? តាមប្រពៃណីខ្មែរយើង កវីឬអ្នកនិពន្ធអំពីបុរាណ ក្នុងសម័យអង្គរក្តី សម័យលង្វែកក្តី សម័យខាងដើមនៃក្រុងឧដុង្គមានជ័យក្តី ច្រើនបញ្ជាក់អំពីមហាសករាជ ។ មហាសករាជនេះកើតក្រោយគ្រិស្តសករាជ ៧៨ ឆ្នាំ ។ ដល់មកចុងសម័យឧដុង្គនិងខាងដើមសម័យក្រុងភ្នំពេញយើងនេះ គេនិយមប្រើសករាជ ៣ គឺពុទ្ធសករាជ, មហាសករាជ និងចុលសករាជ ឬសករាជណាមួយ ប៉ុន្តែក្នុងសម័យអាណានិគមបរទេស គេនិយមប្រើតែគ្រិស្តសករាជមួយជាផ្លូវរាជការទូទៅរហូតដល់សព្វនេះ ព្រោះសករាជនេះគេទុកដាក់ជាសករាជសាកលទៅហើយ គេនិយមប្រើជាផ្លូវការទូទៅក្នុងរវាងអន្តរជាតិ ។

ក្រង់ឃ្លា “ទៀងទុកតំណ ឯកអាសប្បត” ចុងឃ្លាទីពីរមិនចាប់ចុងចួន នឹងចុងឃ្លាទីមួយទេ ។ ដូច្នេះ ក្រង់ឃ្លាទីពីរនេះគួរកែជា “ឯកពាសប្តន ឬឯកទ្វាសប្តន” ទើបអាចចាប់ចុងចួនក្រង់ឃ្លាទី ១ “ទៀងទុកតំណ” បានត្រឹមត្រូវតាមច្បាប់កាព្យបទកាកគតិ ។ ឃ្លានេះមានន័យថា ១២៧៦ នៃម.ស. ត្រូវនឹង គ.ស. ១៣៥៤ ប៉ុន្តែកាលបរិច្ឆេទនេះហាក់ដូចវែងឆ្ងាយពេក?

ប្រសិនបើយើងយល់ថា អ្នកចារចម្លងតពីគ្នាមក ច្រឡំអក្សរ ធ ជា ន ដូចចុងឃ្លានោះគេអាចច្រឡំ ន ជា អ វិញក៏បាននៃរ ។ ដូច្នេះគួរជា “ឯកធសប្តន” អានថា (ឯក—ធ—សាប់—ត) មានន័យថា ម.ស. ១៦៧៦ ត្រូវនឹង គ.ស. ១៧៥៤ ។ ——/

អត្ថបទផ្តើម បវរគាកគតិ ។ អហំវន្ទេ អញ្ជលីយៈ បគ្គយ្ហំ សិរសាបណៈ

សព្វញ្ញុតំ បញ្ញាញាណំ វរទេវតោ ។ . . . .

កិរកាលវន្ទន៍ ជាតិជាលវន្ទន៍ ខណ្ឌកប្បកំបាំង យើង

ជីនះដោយដាន ញេយ្យញាណពុទ្ធ ធម្មទេសនំ គឺធម៌ទេស្នា ។

ពីពុទ្ធឧស្ចឯង ប្រុះប្រាជ្ញាឈ្នះ ដុំជាតក៍អតីតា វែរបើក

បទូល ដោយបូណ៌គាថា ប្រោសប្រស់អស់មហា ជនជាតិ

ទាំងឡាយ ។ . . . . . . . .

. . . . . . . . . . ។ល។

អត្ថបទបញ្ចប់ សរសើរកាលកំណើត ព្រះអង្គកើតដោយគន្ធន៍ ហៅ

ហារយ ជាតក់ហោង យើងជីនដោយព្រះគាថា ។ និទាននេះ

រៀបរាប់ ចងដួបចាប់ដោយកាព្យ ពីខ្សែប្រាំបួនប្រា-កដ-

បរិបូណ៌បទបាលី ។ ប្រកបប្រាកដហោង ដោយទំនង់ព្រះគម្ពីរ

សំដែងជាភាទ៍ ហៅខ្សែដប់គ្រប់ចប់ថែង ។

---

យោបល់នេះ ជិតនឹងកាលបរិច្ឆេទនៃរឿងខ្យងស័ង្ខ ដែលករីបានបញ្ជាក់ថាក្នុង ម. ស. ១៦៥១ គឺថារឿងជយទត្ត កើតក្រោយខ្យងស័ង្ខ ២៥ ឆ្នាំ ។ ដូច្នេះគប្បីយល់ថា រឿងនេះកើតឡើងចុងសម័យលង្វែក ឬខាងដើមសម័យឧដុង្គ ។ តាមយោបល់ផ្ទាល់ យល់ឃើញថា កាលបរិច្ឆេទនេះសមរម្យជាងខាងលើ ។

បំណាំងជើង សាស្ត្រា វរនុជវរនេត្រ”

អ្នកនិពន្ធ អ្នកឧកញ៉ាព្រះឃ្លាំង (ទង)[១] ជាចៅហ្វាយឃ្លាំងមណីរត្ន ។

កាលបរិច្ឆេទ ថ្ងៃអង្គារ ១៤ កើត ខែកត្តិក ឆ្នាំខាលអដ្ឋស័ក ម.ស.
១៧២៨ (គ.ស. ១៨០៦) ។

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុដ្ឋលីលា)

ប្រភពរឿង បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ៦ ខ្សែ ចប់ជុំជាតក់ ។ នៅ
បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានឯកសារនេះ ២ ចប់លេខ
សាស្ត្រា ៤៦៣-៤៦៤ ។

អត្ថបទផ្តើម អហំនមោ នមស្សាគាវេ អនុស្សរិតំ វត្តិទ្វិ ពុទ្ធគុណំ
គុណសេដ្ឋំ សគ្គេហិតោ ។
មហាសករាជៈ ឯកស័ប្តតោអ ដ្ឋស័តព្យគ្យ នាមសំវច្ឆរៈ
កុម្ភវារេ កត្តិកមាសេ កាលពេញបូណ៌មី ។

---

១ គួរកត់សំគាល់ថា អ្នកឧកញ៉ាព្រះឃ្លាំង ‹‹ទង›› នេះ ជាកវីឯកមានកិត្តិនាមល្បីល្បាញក្នុងសម័យនោះ ។ លោកជាព្រះរាជគ្រូនៃព្រះបាទសម្តេចព្រះហរិរក្សរាមា (ព្រះអង្គដួង) ជាចាងហ្វាងក្រុមព្រះរាជនិពន្ធ ។ លោកបាននិពន្ធរឿង ឬ អត្ថបទ ជាពាក្យកាព្យ ច្រើនរឿង ដូចរឿង ភោគកុលកុមារ ច្បាប់សុភាសិត និងលោកនេយ្យពាក្យកាព្យ ដែលជារឿងយ៉ាងវែង ប្រកបដោយខ្លឹមសារគួរទុកជាមហាកំណាព្យ ១ នៃកវីខ្មែរបុរាណ ។

ខ្ញុំនាម កញ្ញា ព្រះយ៉ាំង«នង» ជាចៅហ្វាយយ៉ាំងមណី
រិះគិតផ្ចាញ់ រំពឹងពិតពីពូជពង្សពោធិ-សត្វសាងបារមី ។

. . . . . . . . . ។ល។

អត្ថបទបញ្ចប់ សូរេចធម៌ទេស្នា ឲ្យអស់មហាជនគ្រប់ប្រាណ ប្រាំបី ហ្មឺនសឹងបាន លុះធម្មាភិសម័យ ។ ខ្ញុំគន់ខ្ញុំគិតលើក ចងជា ល្បើកកាព្យនេះនៃ តែងចប់នៅនាថ្ងៃ ពីរកើតខែអស្សុជណា ។ មមែបញ្ចស័ក និទានជាក់តាមសុភាព ពាក្យពុំសូវពិរោះពប ទំតែកើតចង់បានផល ។ និទាននេះទៀងទេ តពីខ្សែប្រាំ-មកដល់ ព្រះវរនេត្រយង់យល់ ជួបជួនព្រះវរមាតា ។ រៀង-រាល់ពាល់ចុងចប់ ចែកសព្វគ្រប់តាមបទបា- លីលុះដុំជាតក៍ជា ខ្សែប្រាំមួយសូរេចហោង ។

—X—

បំណងដើម «សាស្ត្រា វរវង្ស សូរវង្ស»

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ

របៀបនិពន្ធ៍ ពាក្យកាព្យ (បទកាកគតិ- ពំនោល- ព្រហ្មគីត កុជង្គ-លីលា និងបទឥន្ទ្រជិត)

ប្រភពរឿង បញ្ញាសជាតក ។

**លក្ខណៈឯកសារ** សាស្ត្រាស្លឹករឹត មាន ៤ ខ្សែចប់ក៏មាន មាន ៥ ខ្សែក៏មាន ។ ឯគម្ពីរដែលមាន ៤ ខ្សែចប់ មានសេចក្ដីផ្ដើម និងសេចក្ដីបញ្ចប់ដូចអក្ខបទខាងក្រោមនេះ លេខសាស្ត្រា ៥៧៤ ។ ឯគម្ពីរដែលមាន ៥ ខ្សែចប់ គឺខ្សែទី ១ មាន ៤៤ សន្លឹក ខ្សែទី ២ មាន ៤២ សន្លឹក ខ្សែទី ៣ មាន ៤៧ សន្លឹក ខ្សែទី ៤ មាន ៣៣ សន្លឹក ខ្សែទី ៥ មាន ២៣ សន្លឹក លេខសាស្ត្រា ៥៧១[១] ។

**អក្ខបទផ្ដើម** បទកាកគតិ ។ អញខ្ញុំទូនអង្គ វរវន្ទាទ្រង់ ទូនអង្គ-
ដាក់កាយ ជុំជិតគម្ពល់ ដាក់ដល់សិនសាយ លុតលើកថ្វាត់-
ថ្វាយ ដាក់កាយបញ្ចង់ ។ សរសើរបារមី ពន្លកជិនស្រី
រុងរឿងកន្លង ដូចកេត្រាមាស ទុកាសឥតហ្មង ផុកអស់សត្វ
ផង សល់សែនសំខ្យា ។ ដូចគម្ពីរជ្រៅ បើកបានទៀងទៅ
សួគិសុខថៃថ្លា ត្រេចត្រង់ដាក់ដល់ មណ្ឌលនៃមហា និព្វាន-
សុខា ថៃថ្លាកន្លង ។ . . . . .
. . . . . . . ។ល។

១– តាមច្បាប់សាស្ត្រាលេខ ៥៧១ មានអក្ខបទផ្ដើមខុសពីខាងលើ គឺគ្មានបទនមស្ការ ផ្ទឹម ថា៖ "បទកាកគតិ" ។ នេះគួរអស្ចារ្យ តាមព្រះរាជ្យធម្ម សារពេជ្ររុងរឿង សង្ខេបអស់អញ លំពេញពេកក្រៃ ពីព្យាយាមនៃ លំបាកមហិមា ។ ធ្វើហេតុផ្ដិតប្ដោះ ឲ្យដល់កាលណោះ សម្ដេចភគវា . . . . . ប៉ុន្តែនិលបញ្ចប់អក្ខបទ ស្របគ្នានឹងខាងលើដែរ ។

អត្ថបទបញ្ចប់ គួររៀនគួរស្ដាប់ គួរត្រងគួរត្រាប់ គួរគិតអនិច្ចា គួរ

ប្រែគួរប្រាស គួរលោកគួរលោ ពីសង្សារ កំណើតជួនជាតិ ។

សាធុសម្ដាយ ចូរស្ដាប់និយាយ ដំណើរព្រះបាទ វរវង្សគោក-

យ៉ាក លំបាកសល់ខាត ក្នុងហាសិបជាតក៍ ថែងចប់ម៉្ងៃះហោង ។

(វេលានេះណា រសៀលស៊ុរិយា ទន់ទាបទៅហើយ សមល្មម-

ទីងចប់ គ្រាន់គ្រប់ហ្នឹងហើយ ព្រះពុទ្ធម្ចាស់អើយ ទេស្នា-

ធម៌ថ្ងៃ ។ ជាតកនិដ្ឋិតំ ដុំជាតកំ តារចប់ម៉្ងៃះឯង សូរចេអក្ខរ

និដ្ឋិតាចប់ថែង ក្នុងចិត្តសូះស្វែង និដ្ឋិតំចប់ហោង(១) ) ។

—X—

បំណាងជើង សាស្ត្រា មុច្ចលិន្ទ (ចន្ទគោរម) ។

អ្នកនិពន្ធ បណ្ឌិត ស្អាត ឬ សំអាត ។

កាលបរិច្ឆេទ ថ្ងៃសុក្រ ៩កើតខែអាសាឍ ឆ្នាំម្សាញ់ ព.ស. ២៣៧៦

(គ.ស. ១៨៣៣)

របៀបនិពន្ធ ពាក្យកាព្យ (បទកាកគតិ-ពំនោល-ព្រហ្មគីត-កុជង្គលីលា)

ប្រភពរឿង បញ្ញាសជាតក ឬហាសិបជាតក៍ (ប៉ុន្តែអ្នកនិពន្ធ បាន-

បញ្ជាក់ថា ប្រែពីភាសាសៀម) ។

---

១— ពីរវគ្គខាងចុង ក្នុងវង់ក្រចក ប្រហែលជាអត្ថបទរបស់អ្នកចារចម្លងទេដឹង? ព្រោះ ច្បាប់សាស្ត្រាលេខ ៤៣៤ ឥតមានអត្ថបទពីរវគ្គខាងចុងនេះទេ ។

លក្ខណឯកសារ សាស្ត្រាស្លឹករឹត មាន៧ខ្សែរចប់ ។

ឯកសារនេះ នៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យមាន១គម្ពីរ

លេខសាស្ត្រា ៥៧៧ ។

អត្ថបទផ្ដើម នេះបទកាកគតិ ។ ទសករផ្កាផ្ទុំ ស្មោះស្មើបទុម ដាក់ដល់

សិរពេ បង្គំសម្ដេច សារពេជ្ញពុទ្ធោ ប្រសើរឧត្តមោ លើស

លែងលោកា ។ ស្ដេចជាគ្រូគ្រប់ ទូទាំងភូមិកត ពីងព្រះបេ-

ស្ដា ឥន្ទព្រហ្មយមយក្ខ ហ៊ឹនចក្រវាឡ មូលមកវន្ទា បង្គំកត្ដី

. . . . . . . . . . . . . . .

សកករាជតាំងក ទោត្រីស័កឆ(១)មង្គលសួស្តី ម្សាញ់នក្សត្រ

ពិឡ្សេរិ៍ អាសាឍមាសី សុក្រ៥កើតជាក់ ។ នៃនាមអញ

ខ្ញុំ តាមដោយគោរម្យ ឧត្តមសិទ្ធិសក្តិ បណ្ឌិតសំអាក

សង្វាតរួសរក្ស ចិត្តចង់ស្មោះស្មគ្រ គាប់កាលចិន្តា ។ . .

. . . . . . . . . . . . . . ។ល។

អត្ថបទបញ្ចប់ ។បទព្រហ្ម។ និទាននេះទៀតគេ ពិតពីខ្សែរប្រាំមួយខ្ទី

តែងតាមបទបាលី ដោយពាក្យស្រីនិយាយទេ ។ ទោះបីបើ

ខាតខុស ខ្វះលើសលោះពីពាក្យគេ កែគិតឲ្យគ្រប់តែ ប្រាំ

ពីរខ្សែស្សូរបេហោង ។

---

១- យោបល់ ត្រង់ពាក្យថា "សកាជតាំងក ទោត្រីសកឆ . . " ប្រហែលជា "ទោត្រីស័ក្កឆ" វិញទេ ? ប្រសិនបើដូច្នេះមែនមានន័យថា ២៣៣៦ នៃពុទ្ធសករាជ ។

# សិលាចារឹកត្រពាំងរុន

ស្រាវជ្រាវដោយ ឌឹក-គាម

## ពាក្យផ្ដើម

រាប់ឆ្នាំមកហើយ ដែលខ្ញុំជាប់ចិត្តអានសិលាចារឹកខ្មែរ ។ ការអានសិលាចារឹករបស់ខ្ញុំនៅស្ទួចស្ទើងណាស់ មិនគួរល្មមនឹងយកមកដាក់ក្នុងសៀវភៅសោះ ។

ការជាប់ចិត្តអានសិលាចារឹកខ្មែរនេះ ធ្វើឲ្យខ្ញុំនៅតែនឹកមមៃក្នុងអក្សរសាស្ត្រខ្មែរ ។ នៅពេលខ្ញុំទៅលេងអង្គរវត្តម្ដងៗ ខ្ញុំធ្លៀតតែដើរអានសិលាចារឹក ខ្លះក៏អានបានស្រួល ខ្លះក៏អានមិនបានស្រួល ។ នៅពេលដែលខ្ញុំទៅប្រទេសឥណ្ឌា ឆ្នាំ ១៩៦៣ ដោយសេចក្ដីជាប់ជំពាក់ជានិច្ចក្នុងសិលាចារឹក ហើយខ្ញុំយល់ថា សិលាចារឹកខ្មែរមានលំនាំមកពីសិលាចារឹកឥណ្ឌានោះ ក្នុងខណៈដែលខ្ញុំទៅមើលប្រាសាទបុរាណក្ដី ខ្ញុំចូលបណ្ណាល័យក្ដី ខ្ញុំតែងតែដើរពិនិត្យរកមើលសិលាចារឹកឥណ្ឌា រហូតដល់ខ្ញុំបានជួបនូវសិលាចារឹកមួយនៅក្នុង Epigraphica India vol. XVII, page 12 ដែលមានកិនការដូចសិលាចារឹកខ្មែរយើងដែរ ។

សិលាចារឹកត្រពាំងរុននេះ ខ្ញុំយកទាំងសំស្ក្រឹតទាំងខ្មែរមកជូនទាំងស្រុង ហើយម្យ៉ាងទៀតខ្ញុំរៀបរៀងសិលាចារឹកនេះ នៅតាមទម្រង់ដើមឥតមានកែប្រែទេ តែនៅខាងចុង ខ្ញុំបានរៀបជាបទានុក្រមចំពោះពាក្យ

ខ្វះផលពិបាក ឯពាក្យដែលឆាយអានខ្ញុំទុកឲ្យលោកអ្នកអានរៀនអានដោយខ្លួនឯងទៅចុះ ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពដល់វិញ្ញាណក្ខន្ធរបស់លោកអ្នកនិពន្ធសិលាចារឹក ដែលបានចារទុកឯកសារឲ្យខេមរជនដល់សព្វថ្ងៃនេះ ។

## សិលាចារឹកត្រពាំងរុន

ចារដោយកវីន្ទ្របណ្ឌិត

សិលាចារឹកត្រពាំងរុន នៅទីរតីភូមិដំដែក ចម្ងាយប្រហែល ៤ គ.ម. ហើយនៅបស្ចិមភូមិរុនប្រហែល ៤ គ.ម. ។ ចម្ងាយពីគីឡូម៉ែត្រ ២៨០ តាមផ្លូវជាតិភ្នំពេញ សៀមរាប ប្រហែល ១ គីឡូកន្លះ ទិសខាងត្បូង ក្នុងខេត្តកំពង់ធំ ។

កវីន្ទ្របណ្ឌិត ជាកូនរបស់នាងវិនាថា ត្រូវជាចៅរបស់គោវិន្ទដែលជាភដបំរើរបស់ព្រះបាទជ័យវរ្ម័នទី២ នៅដើមសតវត្សទី៩ ។ លោកកវីន្ទ្របណ្ឌិតជាសាស្ត្រាចារ្យខាងភាសាសំស្ក្រឹត មិនតែប៉ុណ្ណោះ លោកជាសាស្ត្រាចារ្យខាងវេយ្យាករណសាស្ត្រនយោបាយសាស្ត្រ ហើយនិងសាសនសាស្ត្រ ។ គោវិន្ទមានបុត្រាគឺៈជយេន្ទ្រវល្លភ, ឧបេន្ទ្រវល្លភៈនរវិរ ។ ឯបុត្រី២គឺៈសង្កសិណា និងវិនាថា ជាមាតារបស់គោវិន្ទ្របណ្ឌិត ។

សិលាចារឹកជាភាសាខ្មែរនេះ ពណ៌នាពីការធ្វើអំណោយទ្រព្យដើម្បីទទួលផលព្រះវិស្ណុ ហើយនិងជាឯកសារមួយដែលអាចឲ្យយើងបាន

ដឹងនូវស្ថានភាព នៃអទិទ្ធិតបុរី ។ អទិទ្ធិតបុរីនេះជាធានីមួយបណ្តាធានី ធំៗ នៃប្រទេសកម្ពុជា ដូចសម្ភុបុរី និងវ្យាធបុរីជាដើម ។

សិលាចារឹកគ្រញាំងរុងជាភាសាខ្មែរនេះ គ្រាន់តែបង្ហាញឲ្យឃើញ នូវការផ្ទេរនូវកម្មសិទ្ធិនៃដីធ្លី និងអ្នកបំរើប៉ុណ្ណោះ ។ ឯភាសាសំស្ក្រឹតវិញ និយាយអំពីការគោរពតាមផ្លូវសាសនា និងពង្សាវតារខ្លះៗ ។

ខ្ញុំនាំយកសិលាចារឹកគ្រញាំងរុងនេះ មកជូនដើម្បីឲ្យលោកអ្នកអាន យល់នូវបែបសិលាចារឹកខ្លះ ហើយនិងលំនាំភាសាខ្លះ ។ ភាសាដែលលោកតែងពេលនោះជាភាសាធម្មតា ហើយឈ្មោះមនុស្សដែលមាននៅក្នុងសិលាចារឹកនេះ មិនយកតាមភាសាសំស្ក្រឹតឡើយ គឺពិតជាឈ្មោះមនុស្ស ប្រើតាមសំដីសមញ្ញ ។

ភាសាខ្មែរដែលលោកកវិន្ទ្របណ្ឌិត យកមកប្រើនោះជាសំដីសមញ្ញ តែដូចជាពិបាកស្តាប់បន្តិច ខាងពាក្យ និងខាងវេយ្យាករណ៍ ។

នៅក្នុងសិលាចារឹកគ្រញាំងរុង ខ្ញុំសូមជូន

១– បែបព្យញ្ជន



ព្យញ្ជនៈនៅក្នុងវគ្គមិនសូវប្រើទេ ។ សូមកុំស្មានថាសម័យនោះខ្មែរយើងមិនទាន់មានព្យញ្ជនៈបែបនោះ ។ នៅសម័យនោះព្យញ្ជនៈក្នុងវគ្គ ច្រើនតែខ្ចីព្យញ្ជនៈ នៅក្នុងអវគ្គមកប្រើ សូម្បីតែសព្វថ្ងៃ ក៏យើងសរសេរអវគ្គ ជំនួសវគ្គខ្លះដែរ ។.

ដំណាង=តំណាង

## ២– បែបស្រះនិស្ស័យ



# អត្ថបទនៃសិលាចារឹកត្រពាំងរុន

ជាភាសាសំស្ក្រឹត ចារដោយកវីន្ទ្របណ្ឌិត(១)

សិទ្ធិ ស្វស្តិ ឱម នមោ ភគវតេ ភស្មេឝាយ

១. យេនាធិឞ្ឋិតមវ្យក្ត- មលំ សកលសម្ភូយេ
បុរុមស៑ ស យទីយាង្ឃ្រិ ភាសុទេវេន្ទមគ្គុ តម៑ ។
២. យស្យ នាភិភវាម្ភោជ- ជន្មនាម្ភោជជន្មនា
ខ្យាតំ បរមកត៌ត្វំ ស្រព្ត្រោគេបតន្វភូតាមិ ។
៣. មាហាត្ម្យមគ្យទ៑ យស្យាស្តា- ន្នាភិជាម្ពុជសម្ភវៈ
មេរុយត៌ិ បទ្មយោគ្យាទ៑- ទេវាគាមាទិវាលយៈ ។
៤. បាទាទ៑ យស្យ ជគទ្វន្ត្យាត៑(២) ប្រភវន្តិ សុរាបគា
ត្រៃលោក្យបាវនី ប្រាហ មហត្វំ បរតោ'ធិកម៑ ។
៥. វាមនស្យ ត្រិភិល្លោកាន៑ ក្រមតោ វិក្រមក្រមែះ
យស្យាគ្រាហ្យស្វភាវត្វំ វិទ្វទ្ភិរនុមីយតេ ។
៦. វិហុធាបិ វិរុទ្ធានាំ យទ៑ឃាការកម្មិណាម៑
អចិវទ្ធិ ប្រុណ្ណាម្មេវ គ្រេទ្ធយត្វមុទាហ្វុតម៑ ។

---

១– សំស្ក្រឹតនេះ ខ្ញុំចំឡងតែតាមលំនាំដើមទេ ឯអក្ខរាវិរុទ្ធ ខ្ញុំទុកនៅដូចដើម ។ ២– ជគទ្វន្ទ្យាត្រូវក្រវន្តិ ។

៧. អនុភ្យោ' នុត្តមោ' វ្យក្តំ    យស៑ ស្វិត្រ ប្រវេបនាត៑
អន្តុនិវេគយន៑ ស្វំ    មហាទ្វ្យោ' បិ មហត្តមះ ។

៨. សាម្យំ ស្វិំត្រ ភូតេបុ    យស្យ សំសេវ្យសេវិតាម៑
អគ្ន្យាទេវិ គត្តិស្តុ    ភាញុតាបុ្តនភាប្តិក្ខុត៑ ។

៩. បុរុម្រោត្តមតាម្មេវ    សមស្តាំស្តុជតា បរាន៑
ស្វិតះ ស្តុឯមាខ្យាតំ    បរមត្វមក្រុត្រិមម៑ ។

១០. ក្រមេណ ក្រមតោ យស្យ ត្រិលោកំ វរិភគតះ
មុហុលិសាជំកោរស្ន-    មណភិហោមាង្រ្សិបថិតាម៑ ។

១១. យត្ក្រាធសំប្រសត្តិភ្យាំ    វុទ្រាជៅ សំវិភូវិតុះ
នមស្តុទ្វីតាន្តស្មៃ    វិប្ណវេ ប្រភវិប្ណវេ ។

១២. នមទ្វំ គុលិន យស្យ    ត្រិគុលានិ វិវេជិវេ
យុគបត្រ្តិបុរញ្ជេតុ-    ជិយស្តុម្នា ឥវិ ត្រយះ ។

១៣. ហិរណ្យរេតសា តបុះ    ហិរណ្យសទ្ធម៌ាប៊ិមេ្វ
ហិរណ្យគភ៌ាយ ៩មោ    ហិរណ្យាក្សាវិជិន្ទ្រេ ។

១៤- អាសីទាភិរំធេរុវ្ហីម៌ វេហាវេទេធិភូធរេះ
រាជា ត្រៃជយវម៌េតិ មហេន្ទ្រាទ្រិកូតាស្បទះ ។

១៥- សោមាន្វយប្រទីបោយ- ស្សោមស្សូរ្យធ្វជនជិវនេ
សោមេគូរេ សទា ភក្តះ សោមសោមេ្យវហេហុបគ្រិយា។

១៦- ជយេន្ទ្រទាសទាមាភ្ស-[១] ទន្និន្ទិតបុរោទ្ធវះ
ជយេន្ទ្រវិល្វភាខ្យាំ យ- ស្តស្យ ភូតេ្យ វហេត្បុនះ ។

១៧- គោវិន្ទនាម្នោ វិប្រស្យ វេទវេទាង្គវេទិនះ
គោវិន្ទភក្តស្យ សុតោ យោ គោវិន្ទនិមាកូតះ ។

១៨- អាត្មទេវេគេ តំ វ្រង្គាម្និ វលិកប្បូរនាម្និ ប
កុលទេវាន្នវក្សទ្បស៍[២] ស្វយញ្ញ សមតិម្ពបត៍ ។

១៩- ជយេន្ទ្រវិល្វភ្រាតា ភិសុទេរៅ ជយឝ្យេជះ
ភូតេ្យ ភវទ្យស្តត្យនោ រាជ្ញម៌[៣] ត្រៃជយវម៌ណះ ។

២០- ន្ទូបេន្ទ្រវិល្វភាខ្យាំ យប៌ គ្រីទ្ធាំ គ្រៃជយវម៌ណះ
តតះ ប្រាប បុនភូតេ្យ វិភូវ គ្រៃន្ទ្រវម៌ណះ ។

---

១- . . . ភូទន្និន្ទិត . . . > ភូទិ + អន្និន្ទិត . . . ។ ២- កុលទេវាន្នវក្សត្យ-ស្ប
. . . ។ ៣- រាជ្ញត្រៃជយវម៌ណ: ។

២១. តយោត្រាំតា កនិដ្ឋោ យះ  ប្រទុម្មុច៌ គ្រឹត្រូវម្មិណាះ
ភូត្យម៌ គ្រឹនរីរាខ្យា-  មជាទ៌ យោ ភត្តិភក្តិតះ ។

២២. គ្រឹត្រូគ្នូរាលយោ លិង្គំ  ម្រម្ភោរជាម្ទូរាប្ភិះ
សំស្ថាប្យ យោ ទទៅ តត្រ  ទាសៃស៌ សិទ្ធបុរំ យុតម៌ ។

២៣. ភាគិនេយវិរស្តេហាំ យស៌  សង្កមិណាគាមធ្ធូក
គ្រឹត្រូវម្មិសុតស្យាប្តគិ៌  គ្រឹយគោរម្មិណោ ភវតិ ។

២៤. គ្រឹយគោរម្មិណោ ភូត្យ–  ស្យ រាជ្យោស្តទបត្យយោះ
គ្រឹហាមិរម្មិគ្រឹគារន-  វម្មិណោរបិ បារកះ ។

២៥. សង្កមិណាស្យ តស្យាបិ  ភាគិនេយោ វិភូវ យះ
រវិគាឋាហ្វយោ ភូត្យគិ៌  គ្រេម្ហ គ្រឹជយវម្មិណាះ ។

២៦. យស្តតះ ប្រាប្តសន្មានោ  ភូត្យស្ត ត្បុត្រយោរបិ
គ្រឹប.ប៌វម្មិភូបាល–  គ្រឹមទ្រោជេត្រូវម្មិណោះ ។

២៧. តស្យ ឥប្តា វិភូវាយ៌–  ស្យាត្ថតស្យ មតស្យតាម៌
បញ្ចគវ្យាភិជានោ យះ  បញ្ចវ្យាករណាន្តគះ ។

---

២៨. គវ្យូហ៌គមគាស្រ្តាណិ  កាវ្យំ ភារតវិស្តរម៌
រាមាយណញ្ច យោ' ធីត្យ  គិប្យានបញ្ញឺធីគបតិ ។

២៩. កុលកម្មិគ្រតិទ្រវ៉ៀ-   វុន្ធតោ’ បិ ស្វភាវតះ
វិនយាវិស្មយាភ្យាំ យោ   ឥវៃភាក្ឫតិរារភៅ ។

៣០. ជាត្យន្ធះ បររគ្រម្ម៉ុ   ក្លីវ៉ះ បរគ្មហោប៉ុ យះ
កលៅ បក្រេ ក្ឫតាបារ–   មបិ កាលាត្សុរ្យុបរិតិ ។

៣១. (ភាៈ)ត្យាមួតស្រុតា យស្យ   សត្រ្យីត្យុទធិរេវ ឥ
វិរូធេ សទ្ទូទគ្មាបិ   ភាៈសវេន្ទោហិមាទ្រិតះ ។

៣២. គ្រីមទ្រាជេន្ទ្រវិម្មិគ្រ្យ–   សូនុយស្យូរយសន្ធិភះ
រាជា គ្រីជយវម្មេតិ   វ្យោមមាគ្គាឬ្ដរាជ្យភាក៑ ។

៣៣. មហាវិឥតោលក្សូវាន៑   ទ្វិមន្ធុរិធវិទ្វិមាម៑
អហីនភោគសទ្មា យោ   វិភៅ វិប្ឍវិភាបរះ ។

៣៤. ធម្មិជាំ វលិតំ គូវំ   ក្ឫតវិទ្យំ ប្រិយម្វទម៑
យំ ប្រាប្យៃកបតិម៑ ប្ឫថ្វី   ជហាស ទ្រុបទាត្មជាម៑ ។

៣៥. កីណ៌ាង្ឃ្យស្យ រណោ ទ្ឫប្ត   ទ្វិមន្មក្ដែគិ គិលីមុខៃះ
ស្រស្តាង្គនាកបាមោទ–   លុវ្វៃភិ យស្យ ភីស្យមា ។

៣៦. យស្យ ធូបិតនេត្រេវ   កីត្តិយ៑ជ្រូហារិភុជាម៑
ធូមែរភិទ្រុតា ទិក្សុ   វិវេគាវិបុរាណ្យបិ ។

៣៧. ស បញ្ចវគ្គស្សាសី– ទ្រាជ្ឈគិ គ្រឹជយវម្មិណោះ
អភិសេកក្រិយាការំ តឋាបយិស្សទាប្ចិតះ ៗ

៣៨. ស វណ្ណវីមិមាមប្ចាមិ វិប្ចណ្ណកោ្ត វិជានតះ
មហីធរគគិទ្ធាវែះ បុរេ ស្មិនិ សមតិប្បបតិ ៗ

៣៩. សកេ្យត្រកិង្ករង្គ្រាមមិ សបគុទ្រវ្យ សំយុតមិ
ភគ្គា ភិហេ្យបបាភចិំ ទទៅ ទានវេរិណោ ៗ

៤០. ជាតា មហាសុតស្តស្ស បញ្ចវគ្សស្ស យោ យតិះ
កៃវសិទ្ធន្តនិណ្ណាតោ វិធិនាតិប្បបតិ[១] កុ្បតី ៗ

៤១. បិត្បភក្តយា ទេបេ បៃត្បកេ ស បិនាកិនះ
លិង្គំ វិនាយកញោ្ចមំ វិធិនាតិប្បបតិ កុ្បតី ៗ

៤២. និស្សេបទ្រុមាវនិបាលមេ៉លិ មាលាវជោរុក្បឹតរុគ្នបថះ
វេទាធិរន្ត្រធិណាន្ធជាតោ យោ ភូបតិគិ គ្រឹជយវីរវម្មា ៗ

៤៥. ទគ្គះ ស្នុរគិ គឹភកលះ កលង្កឹ
កាន្តិភិរេតិ កុ្រត មទយសគ្រេំ
ជិតិ ស្វសគាំ៖គ្រឃ ភិលាបតិ

---

១- ពេមសោក្ពុំដើមបិះ ឧត្តិពាបំបុិនាមប្បុតិ ។

កាន្ត្យធិកោ ឃោ វិទធេ វិជាត្រា ។

៤៦. និត្យតោយោឃា មហតះ ប្រវ្ឫត្តា
វិហាយ ភូភ្ឫន្វិហានវ្យន៑
គង្គេវ វិទ្យា យះនេកហាគ្គិ
ជគាម ភូម្នា គុណរត្នសិន្ធុម៑ ។

៤៧. នីលោត្បលឝ្យាមរុចាងសិនា-
មាយូណ្ណិតានាម៑ សមទន៑ ទ្ឫឞ្ដិះ
ទ្ឫប្រេ ទ្ឫគះមិ ភា ហរិណោក្សណាភិ-
វីយោទ្វតោ យស៑ សមធីរ្វិភ្ឫវ ។

៤៨. ស្វវិន្ទុមធ្យេ បិ គតាវិសេនា
សសាធនាប្យាត្មសុប្ឫទ្វតាបិ ·
ឯកេវ និគ្វសបរា សមុគ្គា
សំស្ឫត្យ យំ កាមវគេវ យេ បិត៑ ។

៤៩. កេវ្ឫកំ វិជាយោទ្គតវាហិនីនាម៑
ជេតាសក្ឫទ្យោ យុធិ រាជនាគាន៑

យឝោសម្ភូតំ លោកភុជាម៑ សមគ្យ-

ញ្ញហារ បក្សីន្ទ្រ ឥភោរុសត្វះ ។

៥០. មត្តីត្តិនេ បៀប វិនម្រវិក្រ្តះ

ប្រាក្យាធិតាយា មម វិញ្ចិតាយាះ

កិញ្ញីវិតេនេតិ រុបៅ កីត្តិះ

ប្រិយាបិ យាតា ទុះទិក្យុ ។

៥១. ស បញ្ចគវ្យស្តស្យាបិ គូបស្យាហារយ៉្យបុង្គៈ

វិភូវិតមតោ មន្ត្រី សទន្តៈបុរទគៈះ ។

៥២. កវិន្ទ្របណ្ឌិតាឡ្យាម៑ ស គ្រីត្វាម៑ វិក្រទន្ទនីះ

ទោលាទិរិភវៃស្តេន សត្កុតះ កម្ពុភូតា ។

៥៣. បុរស្តាទស្យ ទេវស្យ ក្យេច្រមេត៑ ក្ឫតារិធិ

តស្មិ៑ន មន្ត្រិវរេ ប្រាទា. ត្វាម្ភោ’ បិំ ស ះហីបតិះ ។

៥៤. ទត្តមេតត៑ ក្សិតីគេន ក្សេត្រំ កិលាង្គិតំ ក្ឫតី

ស ស្វយំ ស្ថាបិតោ ប្រាទាទ៑ ភក្ត្យា កេទភវ៌ទ្វិបេ ។

៥៥. សោឋគ្យជន្ទភ្ជរិទ្ធាទិ   កុលីនះ កុលនន្ទនះ
នារាយណាហយស្តស្ស   ស្វនុស្សុរិគុណាករះ ៗ
៥៦. ប្រម្ហា ប្រេយសិ សត្យុនៅ តស្មិន៍ ស សមកល្បយតិ
សក្យេត្រកិង្ករក្រាម_   ន្មេរិតាប្ចូនបាលនំ ៗ
៥៧. វិរិផេះ បត្រកៃលើខ្យែ-   ទ្វិជគា ហត្ថកែត្ថ សះ
សាក្យភិន្ទុបភាក្យេត្ថ   កម្មែតតិ កូតភាន្ទុំ ៗ
៥៨. ករីន្ទ្រវិជ ឃាខ្យាំ   យតិ   ត្រិមតីមិ ត្រីបតិប្រិយះ
ភាត្ថី នារាយណោ វិទ្យានា_   បូភាន៍ រាជិសម្មតះ ៗ
៥៩. តេន ទេវលុកំ រក្សយំ   សទាសក្យេត្របាគរំ
បិត្រយញ្ជបិ កុលំ ស្សិមិ-   តិ បិត្រា ប្រកល្បិតំ ៗ
៦០.   កត្តិវ្យ នានាវិធយាតនានាំ
គិក្យញ្ចរទ្ធិយិមកិង្ករវៅយេះ
លក្សីកូតសិ សោ'ស្តុ សទា យុគាន្តាទ
យោ លង្ឃយេតិ កល្បិតមស្យ សិរិ ៗ



រូបភាពពោះអក្ខរបទសំក្រឹត ទំព័រ ១ និង ៣៥ ។



ស្នាមសិលាចារឹកអក្សរបទសំស្ក្រឹត ពីលេខ ៣៦ ដល់ ៦០ ។

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ក)

លោក ឱ. ធាម ស្រហាវ៉្រាវ និង ពៀបពៀង

គ្រានោះព្រះមាតុលី ទេវបុត្របានស្តាប់ទេវរាជត្រាស់បង្គាប់ហើយ ក៏ថ្វាយបង្គំលាទៅកេណ្ឌយកព្រះកាល ឲ្យត្រួតលើពួកទេវគ្គជាទ័ពស្រួច កៀកកាយព្រះករុណាទេពវ៉ែកខាងស្តាំនោះ ចាត់ឲ្យសុរិយោមទេវទែ វ៉ែកខាងឆ្វេងនោះ ចាត់ឲ្យព្រះពាយវិទ្ធុង អង្គអស់កាន់ជាកងទ័ណ្ឌទ័ព ឲ្យព្រះវិស្សុកម្មឦសានទេពឲ្យកាន់ទង់ជ័យ ទេវតាដែលកេណ្ឌកងទេពក្នុងគ្រា-នោះបានពីរកោដិព្រះអង្គ រីឯសព្ទសន្ធឹកលាន់ឮគគ្រឹកគគ្រេងបីដូចហាក់ជាទឹងទ្រុតទ្រោមក្នុងព្រះសុមេរុហោង ហើយព្រះមាតុលី ទេវបុត្រក៏រៀបពេជ្រយន្តកែវរតនមណីផងហើយរង់ចាំស្តេចហោង ៗ រីអង្គសក្កទេវ លុះដល់សុ-ភឫក្សវេលា ក៏ស្តេចយាត្រាមកស្រង់ព្រះភក្ត្ររួចហើយ ព្រះអង្គក៏ទ្រង់គ្រឿងប្រដាប់សម្រាប់យុទ្ធនាការ ហើយព្រះហស្តក៏ទ្រង់កាន់ឆត្រកែវវិជ័យពីព្រះមុនីនាថមហាឥសូរប្រទានមកស្រេចហើយ ព្រះអង្គក៏ស្តេចយាងឡើងគង់លើព្រះរាជរថមណី គ្រានោះទេវបុត្រដែលនិមិតជាអស្សូរ ដ៏ចាំងមួយពាន់អង្គ ដលកាន់មហាវិជ័យពេជ្រយន្តរត្ននោះ សុទ្ធសឹងតែខ្លាំងពូកែមានឫទ្ធិអានុភាព ក៏តាំងសម្តែងតេជតេជៈ ហេតុតែដៃទើងឲ្យជាអពមង្គលនោះ ក៏ស្ទុះល្បឿនលងដើរហើយ ក៏លោតស្រែកសំរែកនោះថា អបរាជ័យហើយ ៗ

នោះក៏ព្រម ៗ គ្នាទាំងអស់ហោង  កាលដែលទឹងលើកពលចេញទៅច្បាំង នោះហោង ៗ លុះលើកមកដល់ពាក់កណ្ដាលផ្លូវ ព្រះសុមេរុគិរី ទើបឲ្យ ជញ្ជប់ទេវបុត្រពាជី  យោធីទេវតាទាំងអស់បោះទ័ពដំចាំមើលរណក័ក្រ អសុរ ៗក្រោនោះ រីឯរណក័ក្រអសុរ លុះបានឃើញអង្គសម្ដេចព្រះឥន្ទ្រាធិរាជលើកទ័ពចុះមក អសុរក៏បរដៃដើយចូលទៅ ហើយក៏ស្រែកថា អើយនែ ព្រះឥន្ទ្រាធិរាជ  អ្នកឯងតើទឹងគិតអានដូចម្ដេច  ក៏បានជាមិនចុះទៅគាល់ ហៅសម្ដេចព្រះវររាជបិតាអញ  ដែលជាចមកំពូលពិនក្រុងលង្កាទ្វីបនោះ ព្រះអង្គដ៏មានឫទ្ធិអានុភាព បង្ក្រាបបានទាំងត្រៃចក្រ  ក៏ឥឡូវនេះព្រះអង្គ ទ្រង់ព្រះក្រោធហើយ  ក៏ត្រាស់ប្រើអង្គអញជាពជបុត្រមកុដយក្ស ឲ្យលើក កងទ័ពយោធា  មកប្រហារជីវិតដោយខ្លួនកម្លាំងឫទ្ធិហោង  ថាបើខ្លាចខ្លួន អម្ចាស់ដែលសេចក្ដីមរណានោះ  ត្រូវឲ្យចូលទៅគាល់បំរើនៅក្រោមព្រះ បាទអង្គព្រះបិតាអញនេះ ទើបបានអញទឹងទុកជីវិតឯងឲ្យរស់នៅហោង ៗ កាលនោះ រីអង្គសហស្សន័យនៃត្រៃចក្របានស្ដាប់ពាក្យអសុរយក្សថាដូច្នោះ ហើយនោះ ព្រះអង្គក៏តបវាចាទៅវិញថា  នែអើយអសុរ  ចិត្តពោរពាលាខ្លួន អញនេះជាធំលើអស់ទេវតាទាំងពួង  អាឯងកុំមកអួតអាងការក្រោធ  ថាអា ពួកអាឯងនោះមានឫទ្ធិខ្លាំងពូកែ   រីឯអាទស្សក័ក្រអសុរនោះអញក៏ស្គាល់ ហើយអានោះពាលប្រព្រឹត្តចិត្តពោរសាមាន្យធ្វើការអពមង្គលដូចសត្វតិរច្ឆាន អញទឹងគប់គិតជាមិត្រមេត្រីនឹងអាទស្សក័ក្រអបលក្ខណ៍អកុសល  ហើយ

អាឯងកុំអាលអួតឫទ្ធិ គិតថាអញខ្លាចអម្ចាស់ មិនហ៊ានកំតាំងច្បាំងនឹងឯង កុំទឹកឡើយ រីឯខ្លួនអាឯងនេះប្រៀបឧបមាបីដូចជាសត្វតិរច្ឆានម្ដេចឡើយ ក៏មកហ៊ានតឫទ្ធិនឹងស្ដេចកេសរាជសីហា សំរាប់តែនឹងក្ស័យជីវ៍ ដោយទ្រូងចក្រអាវុធអញក្នុងគ្រាឥឡូវនេះហោង ។ រីឯអគ្គីណាគ៍គ្រុឌនោះក៏បាន ស្ដាប់ហើយក៏ទ្រង់ក្រេវក្រោធពិរោធដូចជាភ្លើងប្រល័យកល្ប អសុរីក៏ទាំ មាត់សង្កៀតធ្មេញគំរាមស្រែកថាទៅវិញថា ណៃព្រះឥន្ទ្រកុំអហង្ការសោ-មនស្សពេក ល្អហើយគង់តែនឹងឃើញឫទ្ធិគ្នាហោង ម៉្លោះហើយអញនឹងបំ-ផ្លាញជីវិតឲ្យក្ស័យនឹងដៃអញមិនលែងឡើយ ថាហើយទើបត្រាស់បង្គាប់ ប្រាប់ទៅសេនាអាមាត្យពួកពលឲ្យចូល ហោមរោមចាប់កាប់សម្លាប់ទេព ទេព ។ គ្រានោះឫទ្ធិកណ្ណាសិទ្ធិសក្តិយក្សា ដែលជាទ័ពស្រួចអសុរនោះ ក៏ កៀនពួកពលយោធាចូលហោមព័ទ្ធ ។ កាលណោះពួកពលយោធាសេនា យក្សក៏ចូលតតាំងច្បាំង កាប់សម្លាប់គ្នាជាកោលាហលច្របល់គ្នាជាវឹកវរ តាំងសងខាង គ្រានោះរីអគ្គព្រះកាលក៏កៀនពលទេព្តឲ្យចូលតតាំងច្បាំង នឹងពួកពលអសុរ ចាក់កាប់សម្លាប់គ្នាទៅហោង រីឯពួកកុម្ភណ្ឌពលអសុរី នោះ ក៏តាល់តាញ់ថ្វីដៃពួកទេព្ត ម្នាក៏តែយកតែជីវិតរាល់គ្នា ពួកទេព្ត ក៏លុកលុយដេញ ជិតប្រកិតគ្នាតាមទៅដល់មុខដំរីជ័យសិទ្ធរណាគ៍គ្រុឌ ។ គ្រានោះរណាគ៍គ្រុឌសិទ្ធិសក្តិ លុះក្រឡេកមើលទៅឃើញពួកទេព្តដេញ ពាល់អាត្មាដូច្នោះហើយ ក៏ក្រេវក្រោធគិតពេធក្រៃមហិមា ហើយក៏ទ្រង់បរដំរី

ជ័យចូលច្បាំង នឹងពួកទេវាសុរបុត្រ ១ នោះក៏ទីងទ្រាំទ្រតដៃនឹងអសុរ ពុំបាន ក៏បែករត់ខ្ចាត់ខ្ចាយទៅដោយអំណាចឫទ្ធិអសុរនោះហោង ៗ ទើបឥន្ទ្រសហស្សន័យត្រៃនេត្រ ទ្រង់ទតទស្សនាការមើលទៅឃើញ យក្សអសុររាណាក៏ក្រោបរដំរីចូលមកវាយកំចាត់ពួកទេវដូច្នោះហើយ នោះព្រះ-ឥន្ទ្រក៏ចាប់យកចក្រកែវមណីនោះ ក៏គ្រវែងបោះចោលទៅ នោះក៏ឆេះកើតឡើងទៅភ្លើងក្រុត ក៏ឆេះបោមជុំដំរីជ័យ រីឯពួកពលអសុរ ក៏មិនអាចទីងទ្រាំទ្រតទល់បានឡើយ ហើយក៏បបួលគ្នារត់ខ្ចាត់ខ្ចាយប្រញាយទៅទីទៃ ៗ តែពល់គ្នាហោង ៗ គ្រានោះ រីឯរាណាក៏ក្រុងអសុរ លុះឃើញភ្លើងចក្រក្រុតឆេះ ឡើងក្តៅពេលកាយាអសុរក៏គិតភ័យតក្កមា ទើបទាញយកសរពិស្ណុទកដ៏មានអំណាចឫទ្ធិខ្លាំងក្រៃ ក៏ថ្លែងទៅដោយឫទ្ធិអានុភាពអសុរនោះក៏លាន់ឮកក្រើកទាំងអាកាសពសុធា គឹកកង៉រពងញាប់ញ័រគ្រប់ស្ថានវិមាន ក៏ងងឹតអ័ព្ទអស់ទាំងទសទិសា សរនោះក៏បណ្តាលកើតជាទឹកភ្លៀងធ្លាក់ចុះមកលត់ភ្លើងក្រុតនោះរលត់អស់ហោង ៗ ម៉្លោះហើយអសុរក៏គ្រេកអរសោមនស្សក្រៃពេក ហើយក៏បរដំរីជ័យចូលច្បាំង កាលនោះ រីឥន្ទ្រព្រះឥន្ទ្រាធិរាជលុះបានឃើញយក្សវាថ្លែងសរសិល្បកើតទៅជាភ្លៀង មកលត់ភ្លើងចក្រព្រះឥន្ទ្រអស់ដូច្នោះហើយ ហើយក៏វាថ្លៃអំណាចវាហ៊ឹកហាក់ហោហាន បរដំរីជ័យចូលចំលុះទំលាយមកដល់នៅមុខព្រះរាជរថព្រះឥន្ទ្រ នោះព្រះឥន្ទ្រក៏លូកព្រះហស្តចាប់យកព្រះខ័នពេជ្របានស្រេច

ហើយក៏គ្រវីគ្រវាស គ្រវែងបោះបាលទៅដោយឫទ្ធិអានុភាពព្រះអង្គហោង រីឯព្រះខ័នពេជ្រនោះ ក៏បណ្ដាលលាន់ឮក្រើកសន្ធឹកសន្ធាប់អឺងអស់ទាំងមេឃ ក៏កើតជាបន្ទាយពេជ្រព័ទ្ធជុំពលយោធា ទាហានហើយហ៊ុំជុំទាំងដំរីជ័យអសុរផង ។ កាលនោះរណាក័ត្រ្គអសុរ ក៏ចាប់ធ្នូសរលើកឡើងដាក់លើក្បាល ហើយនមស្សការសូត្រសេពព្រះគាថាវិជ្ជាមន្តហើយក៏សម្ដែងថ្លែងទៅមួយរំពេច ហេតុតែអំណាចនោះ ក៏ទំលុះទំលាយបន្ទាយពេជ្រនោះក៏វិនាសអស់ទៅ សរនោះក៏ក្លាយកើតជានាគរាជមានឫទ្ធិចូលមកបោមជុំជិត ហើយក៏ព្រួសពិសចេញមក ។ កាលនោះ រីឯអង្គព្រះឥន្ទ្រាធិរាជទតនិមិត្តតែឃើញឫទ្ធិសរអសុរ ក៏បណ្ដាលកើតជានាគី-នាគា ចូលមកព្រួសពិសហើយក៏លូនចូលមកដល់នៅមុខព្រះរាជរថ រីឯបណ្ដាពួកពលសាគលយោធាទេវទាំងឡាយ ក៏កើតភ័យតក្កមារត់មីមា ហើយព្រះឥន្ទ្រាក៏បើកបរព្រះរាជរថហោះឡើងទៅលើមេឃ គ្រានោះឫទ្ធិគណអសុរជាទ័ពស្រួច ក៏ស្ទុះលោតទៅដោយឫទ្ធិអានុភាព ដល់ហើយក៏ចូលទៅចាប់ចុងចន្ទោលព្រះរាជរថព្រះឥន្ទ្រាឃូសទុកនៅ រីឯទេពព្រះ-មាតុលី ក៏ប្រឹងបររាជរថហោះឆ្យានទៅ រីឯអសុរក៏ប្រឹងចាប់ទង់ទាញព្រះរាជរថនោះទៅវិញទៅមក នៅកណ្ដាលអាកាសជាវិការ ។ រីឯអង្គព្រះឥន្ទ្រាធិរាជ លុះឃើញពួកពលយក្សរាដេញតាមមកចង្វាំងដូច្នោះហើយនោះ ក៏ព្រះអង្គមិនអាចហ៊ានតដៃទទឹងវាំ ក៏ខ្លាចអំណាចយក្សនោះ

ខ្លាំងណាស់ កាលណោះ ព្រះអង្គក៏ក្ដួចយកទាំងកែវមណីនោះទៅផង ក៏រត់ចោលហោះឡើងទៅប្រាសាទវិមានហោង ៗ រីឯបុត្តីកណ្ដអសុកលុះឃើញអង្គព្រះឥន្ទ្រានោះរត់ចុះចោលពីពេជ្រយន្តរថ ចោលផ្លូវហោះហើយនោះក៏អសុក ក៏បានឃើញចក្រកែវមណីរបស់ដែលពីព្រះមហាឥសូរប្រទានឲ្យព្រះឥន្ទ្រានោះ ក៏រើសយកចក្រកែវនោះបានហើយ ក៏មិនបានដេញតាមព្រះឥន្ទ្រាតទៅទៀត អសុកក៏ត្រឡប់វិលមកវិញ លុះដល់ហើយក៏ថ្វាយបង្គំ ហើយក៏ថ្វាយចក្រកែវនោះទៅវរ័ណភ័ក្ត្រយក្សា ថាចក្រកែវនេះជារបស់ព្រះឥន្ទ្រា ទូលព្រះបង្គំជាខ្ញុំ ក៏បានយកមកថ្វាយទុកជាអំណាចថ្វីដៃក្នុងកាយហោង ៗ កាលណោះ វរ័ណភ័ក្ត្រអសុកលុះបានឈ្នះទ័ពសម្ដេចអម្រិន្ទឥន្ទ្រាហើយ ក៏បានទាំងចក្រកែវមកផង ស្រេចហើយក៏ឡើងលើករយោធា វិលហោះចាកគិរីកំពូលព្រះសុមេរុ មកឯនគរក្រុងលង្កាទ្វីបហោង ៗ លុះមកដល់ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំទូលសម្ដេចព្រះវររាជបិតា ហើយថាទូលព្រះបង្គំជាខ្ញុំលើកទ័ពទៅច្បាំងនឹងព្រះឥន្ទ្រាធិរាជ ៗ នោះក៏ចាល ចាញ់គេដៃ នឹងទ្រាំទ្រនៅតតាំងច្បាំងពុំបាន ក៏រត់ចោលទាំងពេជ្រយន្តនិងចក្រកែវមណីរត្ន នោះទូលព្រះបង្គំជាខ្ញុំមកបានរើសយកទាំងចក្រកែវមណីរត្ន ជាទ្រព្យរបស់ព្រះឥន្ទ្រាធិរាជ នោះទូលព្រះបង្គំជាខ្ញុំយកមកថ្វាយសម្ដេចវររាជបិតា នោះទុកជាទីសំគាល់ការឲ្យប្រាកដហោង ៗ កាលនោះ ទសភ័ក្ត្រអសុកក៏ទទួលយកចក្រកែវមណីរត្ន

ហើយក៏ទ្រង់ត្រេកអរសោមនស្សក្រៃពេក ហើយក៏ទ្រង់ឱបក្រសោបកូន ហើយក៏ទ្រង់មានព្រះឱង្ការសរសើរកូនថា កូនអើយ អ្នកមានបុណ្យអានុភាពពូកែខ្លាំងក្រៃ កូនឯងនេះគួរនឹងជាមហេយ្យមហាឥស្សរាធិបតី ក្នុងក្រុងលង្កាទ្វីប នឹងបានគត់ជពង្សវង្សត្រកូលឥឡូវនេះ អាពុកនឹងតាំងនាមឲ្យឈ្មោះជាឥន្ទជិតអសុរាវិញ ឲ្យអ្នកព្រះល្បីកេរ្តិ៍ឈ្មោះសុសសាយសព្វគ្រប់ទិសានៃត្រៃលោកាអាណាចក្រ តាមៈជាយហេតុបុព្វនិមិត្តកូនសំឡាញ់ដែលអ្នកលើកកងទ័ពសេយោធាទៅច្បាំងនឹងព្រះឥន្ទ្រាធិរាជ មានជ័យជំនះឈ្នះទេវរាជដូចសេចក្តីប្រាថ្នា ។ កាលនោះ ឥន្ទជិតបុត្រាហានបានទទួលព្រះនាមពីសម្តេចវររាជបិតាតាំងឲ្យនោះ ក៏ទូនលើពេក្រាបថ្វាយបង្គំដោយសោមនស្ស ហើយក៏វិលទៅប្រាសាទអាត្មាវិញហោង នេះសម្តែងពណ៌នាពីនាងមាលីជាស្រីបំរើ ព្រះមហាឥសូរជាចមក៏ពួលកៃលាស នាងនោះក៏មានរូបឆោមលោមពណ៌ល្អល្អះ តែងតែទៅបេះផ្កាមកក្រងថ្វាយជាទិច្ចនិរន្តរ៍ លុះដល់ពេលវេលាហើយ នាងក៏លាទៅតេបេះផ្កាពុទ្ធជាតមហាហង្ស រំចេក រំដួល ពុតជ្រ លង្វែ កុលាប ម្លុះលា ម្លុះរួត យីស៊ុន កិត្តុនកៃ កណិការ ស្សរកេ ចំប៉ុ ចម្ប៉ា ហើយនាងក៏បេះផ្កាសព្វសារពើជងតាំងពួង ហើយក៏នាងបេះផ្កាសៀតសមព្រះកម្មា ទ្រៀងលេងកំសាន្ត សព្វសំឡេងនោះពិរោះក្បោះក្បាយពយទំនុកតាមដំណើរ

ដើរលេងសប្បាយកំសាន្ត សំកន្តអង្គហើយអង្គុយក្រងមាលា គ្រានោះ ននុគាលអសុរ នៅជាខ្ញុំបំរើសម្តេចព្រះសយម្ភូញាណ ជាអ្នកឆ្មាំទ្វារកំផែងជាន់ខាងក្នុងអសុរនោះ ក៏គ្មានប្រពន្ធ ទីងរួមរស់ប្រតិព័ទ្ធមេត្រីនោះក៏ទេ រីអាយុននុគាលនោះមួយម៉ឺនឆ្នាំមកហើយ លុះបានឃើញនាងមាលីប្រៀងបេះផ្កានោះតែសព្វថ្ងៃសព្វវេលា អសុរននុគាលក៏បណ្តាលដួងចិត្តនោះទឹកស្រឡាញ់ពេញចិន្តា អង្គុយចាំនៅមាត់ទ្វារហើយក៏សើចញញឹមនៅទីមមាត់ទ្វារ លុះនាងដើរមកហើយននុគាលអសុរ ក៏ដើរតាមនាងមាលីទៅទីសួនផ្កា ហើយននុគាលក៏ទៅអែបផ្ទាប់ទីងដើមជ្រៃ លុះបានឃើញនាងអង្គុយក្រងមាលា នោះអសុរក៏រឹតតែចាប់ចិត្តស្រឡាញ់ខ្លាំងឡើងដូចភ្លើងឆេះក្នុងទុក ទីងទប់ទល់អាត្មាពុំបានឡើយ ហើយក៏បេះយកផ្កាមួយនោះបោះចោលទៅលើនាង កាលនោះ រីនាងមាលីស្រីស្ងួត លុះស្រាប់តែភ្ញាក់ខ្លួន ក៏ភ័យភិតហើយនាងក៏ស្រែកឡើងដោយសេចក្តីដែលផ្អើលភ្ញាក់ហើយ ក៏នាងបែរក្រឡេកមើលទៅក្បែរសួនឧទ្យានក៏ឃើញននុគាលយក្សហើយ នាងក៏មានសេចក្តីក្រោធក្រេវក្រញេវក្រញឹងញីង ក៏ចាប់កន្ត្រងមាលាក៏កណ្តៀតដើរមក លុះមកដល់ក៏ចូលក្រាបថ្វាយបង្គំជិតព្រះបាទា សម្តេចព្រះសរពេជ្ញពជនាថាទូលក្តាន់នាងសោយសោកាបរទឹកព្រះនេត្រា ពោលពាណីនាទូលថា អាននុគាលនេះ ពុំព្រហើនមាត់ស្វាយណាស់ ពុំមិនមានខ្លាចក្រែងព្រះបារមីព្រះអង្គនោះឡើយ

ហើយនាងក៏ក្រាបទូលតាមដំណើរ  រៀងរាប់សព្វសេចក្ដីពីដើមដល់ចុង ហើយ នាងក៏ថ្វាយកម្រងមាលាដែលគ្រងនោះទៅជាទីសំគាល់ហោង ។ ទើបអង្គសម្ដេចព្រះឥស្សរនោះ លុះស្ដេចបានទ្រង់ព្រះសណ្ដាប់ នាងមាលីវង្សទូលដូច្នោះហើយ ព្រះអង្គក៏ទ្រង់ព្រះពិរោធក្រោធក្រេវណាស់ ក៏ត្រាស់ប្រើចេតបុត្រឲ្យទៅហៅអានន្ទកាលអស្សុកឲ្យមកជាឆាប់ អញនឹងសួរកិច្ចការរឿងឲ្យបានជាក់ពិតប្រាកដច្បាស់ ។ ទើបចេតបុត្រនោះក៏ក្រាបថ្វាយបង្គំលា ហើយក៏ទៅកាន់ទ្វារ ១ រំពេច លុះដល់ស្រេចហើយ ក៏ថ្លែងព្រះឧង្ការប្រាប់ថាសម្ដេចព្រះឥស្សុកាធិបតី ស្ដេចឲ្យហៅទៅឥឡូវជាឆាប់ ៗ គ្រានោះ នន្ទកាលអស្សុក បានស្ដាប់រឿងចេតបុត្រថ្លែងព្រះឧង្ការត្រាស់ឲ្យហៅហើយ ក៏មានសេចក្ដីភ័យភិតតក្កមាម៉ឺម៉ាឡើងទៅគាល់ជាមួយនឹងចេតបុត្រ លុះមកដល់ហើយ ក៏លូនឡើងទៅក្រាបបង្គំគាល់អង្គសម្ដេចព្រះទសពល ហើយក៏រង់ចាំស្ដាប់ព្រះបញ្ជា ។ ទើបអង្គសម្ដេចព្រះឥស្សរ ទ្រង់ទស្សនាការទតឃើញនន្ទកាលអស្សុកហើយ ពុំលង់ឡើយ ក៏មានព្រះឧង្ការថា ខ្លួនឯងតើដូចម្ដេច ទើបអាឯងហ៊ានព្រះហ៊ានគឃ្លើន ហ៊ានយកផ្កាចោលនាងមាលា រឿងជាស្រីបំរើដំនិតរបស់អញ ម្ដេចឡើយអាឯងមិនក្រែងខ្លាចអំណាចចេស្ដាពងអាជ្ញាសោះឡើយ ។ គ្រានោះ នន្ទកាលអស្សុក បានស្ដាប់ទេវបញ្ជាហើយ ក៏ភ័យភិតតក្កមា ហាក់គួរនាបដូចទន្ទះអស់ទីបាញ់ត្រូវត្រង់អង្គអាត្មា ទើបអង្គអស្សុកទូលសំពេក

ក្រាបទូលថា រីខ្លួនខ្ញុំព្រះករុណានេះដែលបេះផ្កាបោលលេងនឹងទាន់នោះ ឃើញថាមានទោសខុសដល់ជីវិត តាមតែព្រះទ្រង់ប្ដីប្រោសមេត្តាដក ជីវិត ឲ្យបានរស់នៅបំរើជាខ្ញុំក្រោមល្អងធូលីព្រះបាទទៅ ។ កាលនោះ ទើបអគ្គព្រះវៅចមគិរី បានស្ដាប់ពាក្យហើយព្រះអគ្គទ្រង់ខ្ញាល់ខ្លាំងណាស់ ដូចភ្លើងព្រៃឆេះឃ្លូលព្រះទុក ទើបទ្រង់ដាក់ផ្ដាសាដោយវាចាទិត្វថា ខ្លួន អាឯងដែលធ្វើខុសទោសនោះដំក្រៃមហិមា នៃអាពាលា អាឯងចុះចេញ ទៅឲ្យឆាប់ ៗ ឲ្យអាឯងទៅកើតជាក្របីឃ្លៀចនៅក្នុងព្រៃហិមវន្តពនាលី ឈ្មោះហៅកំហែងទូរកា នោះទើបសំមុខពាដែលចិត្តគិតប្រមាថមាក់ងាយ ពុំក្រែងខ្លាចអំណាចបុះម៉ែអញសោះឡើយ ហើយដល់អាឯងបានកូនមួយ ឈ្មោលឈ្មោះទូរគីកាលណា ឲ្យវាបំផ្លាញជីវិតអាឯងឲ្យស្លាប់នោះ ទើប ត្រឡប់បានរួចផ្ដាសា ពីសត្វតិរច្ឆានបានរួចពីកម្មសុំឲ្យអាឯងមកកើតជា យក្សនៅចាំទ្វារអញហោង នៅនាបព្វតាគិរីកៃលាស ។ គ្រានោះ រីនន្ទ កាលនោះបានស្ដាប់ព្រះពជតម្រាស់ត្រាស់ដាក់ផ្ដាសាអាត្មាដូច្នោះហើយ ពុំ លង់ឡើយ កំសែនភ័យភិតតក់ស្លុតរន្ធត់ស្ញើរទឹងក្យ័យជន្មា នឹងក្រាបទូល សុំទោសាពុំបានឡើយសោះ ព្រោះប្រាណធ្វើខុសហើយ ក៏ក្រាបថ្វាយបង្គំ យំលាព្រះឥស្សុរៈចុះចាកពីទីគាល់ ហើយក៏ដើរយំសោកអាមោក្នុងព្រៃ ក៏ នឹកថា ឱខ្លួនអញអើយ មិនគួរឡើយមកប្រព្រឹត្តមិនល្អសោះឡើយ ហើយ សែនស្ដាយកំណើតដែលកើតមកជាអគ្គបុរស ហើយសែនកំសត់អត់ឃ្លាន

គ្មានគូទីងគេរួមរស់ស្នេហ៍ស្នង ដូជាតិលើសអស់បុរសផងទាំងពួង ស្រឡាញ់គេគិតថាទីងបានដូចបំណងប៉ងប្រាថ្នា ត្រឡប់ជាមានទោសទុសវិញព្រាងើយ ទទួនអញ្ញអើយតាំងតែអំពីថ្ងៃដែលទៅមានតែសេចក្ដីទុក្ខ ក សុខគ្មានឡើយ ប៉ុះហើយស្គាល់តែគ្រាច់ដើរដោយព្រៃសំសានស្ងានស្ងាត់ ព្រាត់វិលំនៅដេកដោយដីជាទិព្វប្រក្រតី អស់ពីចេះតែយំសោកដើរទៅបន្តិច ក៏មកគេចគិតក្នុងចិត្តទំងថា ធ្វើម្ដេចពស់នាគាគ្នា កម្មហើយទីងរត់គេចវេះទៅណារួចបាន បើទុកជាប្រាណខ្វាចក៏ខ្វាចមិនកើត តាមតែកំណើតកើតមកក្នុងកម្មពៀរគាមតែបុព្វេចុះ ថាតែម៉្លោះហើយក៏ដើរតម្រង់ទៅក្នុងអរញ្ញ លុះបានដល់នាហេមវន្តពនទិវេសន៍ ក៏ក្លាយកេទនោះនៅកើតជាមហិង្ស ឈ្មោះទូរភាមានពលំកម្លាំងខ្លាំងក្លាហានមហិមា មានកាយនោះធំខ្ពស់ ចិត្តនោះកាចសាហាវ ចិត្តវៀចសម្បុរខ្លួននោះឃ្លៀចស គ្រាច់ចរដើរកាល់ហ្វូងនាងក្របីព្រៃជាបរិវារ ៥.០០០ កំណាន់នៅជាប្រក្រតី ៗ រីទូរភានោះ ក៏មានសេចក្ដីរពំងខ្លួនប្រាណ ប្រមាណមើលព្រឹកល្ងាចអាចពិនិត្យមើលថា បើឃើញនាងក្របីណាហើយផើមសំរាបកូនមកនោះឈ្មោល ក៏គ្មានចិត្តនោះគិតមេត្តាអាណិតស្ដាយម៉ាយក្នុងសញ្ញាថាជាសត្រូវនៃងខ្លួនវិញហោង ហើយក៏វៃសម្លាប់ចោលមិនទុកឱ្យរស់នៅឡើយ ហើយបើកូននោះញីទេក៏ទុកទៅ ៗ រីឯទូរភានោះសោត ក៏មានសេចក្ដីនោះ ហួងហែងប្រចណែនប្រចណ្ឌខ្លាំងណាស់ មិនឱ្យក្របីឈ្មោលផ្ដាស់

ណា ១ មកបែកបួម ចូលបន្ទំបានឡើយ មានតែខ្លួនម្នាក់ឯងនៅសេនត្រកល់ កណ្តាលព្រៃហិមពាន្តហោង ៗ លុះយូរបន្តិចទៅកាលគ្រានោះនាងទិល កេសរក្របញីទូវគានោះ ក៏សេពសំរួមរស់ជានិច្ចប្រក្រតីទៅយូរបន្តិច នាងទិលកេសរនោះក៏មានផ្ទៃពោះកាលណាហើយ ក៏រំពឹងគិតក្នុងចិត្តា បើ អាត្មាអញដែលសំពលកូនមកញីនោះមិនអស់ បើកូនអញឈ្មោលសូម្បី ទឹងស្លាប់អាសាឥតការ នាងមហិង្សគិតដូច្នោះហើយក៏គេចវេះ ពាក់ពួន ពីហ្វូង ក្របញីទាំងពួងទៅពឹងពាក់លាក់ច្រោណាទៅរកស៊ីឯទីទួលភ្នំ លុះ មកដល់ទីគូហាកែវសុរ្យកាន្តបានបក្សពេលវេលា ព្រះសុរិយារះហើយ នាងក៏សំពលកូនមកនោះឈ្មោល សម្បុរខ្មៅល្អស្រស់លើបលោងនាង ទ្រង់ពិនិត្យមើលទៅរូបពង្សារពាងកាយគួរសមមាំមួនសំណាំសំនួន ជា អ្នកមានកម្លាំងខ្លាំងពូកែ ហើយនាងក៏ឧស្សាហ៍ថែទាំចិញ្ចឹមឲ្យបៅទឹកដោះ ហើយ លិទ្ធថ្នមថា ម្នាលកូនស្នេហាមាសម្តាយ កូនណាយម្តាយនឹងទៅ យូរពុំបានឡើយ តែអាពុកអ្នកដឹងកាលណាហើយនឹងនាំគ្នាស្លាប់អន្តរាយ ទាំងម្តាយទាំងកូនសូន្យជីវិត រីនាងទិលកេសរ ជាម្តាយនិយាយប្រាប់ថា អាពុកបាឯងចិត្តអាក្រក់វិសេសដល់វី បើកូននោះញីគាត់ទុកនៅ បើកូន ឈ្មោលហើយគូរ គាត់ក៏រំផសម្លាប់កូនឯងដែលមកជាច្រើនណាស់ហើយ កូនអើយចូរអ្នករក្សាខ្លួនរក់ងឲ្យមាំមួនមែនទែនកុំប្រហែលធ្វេសឡើយ កូន អើយអ្នកសោតក៏នៅក្រោរនៅតែម្នាក់ឯង កន្លង់កណ្តាចកណ្តាលស្ពាន

(នៅមានត)

# ពិធីសម្ពោធបណ្ណាល័យ

## នៅវត្តសាកវ័នតេជោ

រៀបរៀង ដោយព្រះវិន័យធរ អ៊ុម-ស៊ុម

កាលពីថ្ងៃទី១៩ សីហា ១៩៦៥ ពេលព្រឹក មានពិធីសម្ពោធបណ្ណាល័យថ្មីមួយខ្នង បានប្រព្រឹត្តទៅ នៅវត្តសាកវ័នតេជោ សង្កាត់លេខ ៣ ក្រុងភ្នំពេញ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត នៃសម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ក្រោមការឧបត្ថម្ភនៃឯកឧត្តម ទេព-ផន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ និងឯកឧត្តម ឡិញ-ពីញ អនុរដ្ឋលេខាធិការក្រសួងធម្មការ ។

ចាប់តាំងពីម៉ោង ៧ ព្រឹកទៅ សកាពអ៊ូអរទាំងឡាយ កើតមានពេញទាំងផ្ទៃវត្តសាកវ័នតេជោ ។ នៅតាមចំពើមផ្លូវ នៃខ្លោងទ្វារចូល និងនៅតាមកុដិ គ្រប់កុដិ សាលា វិហារ ទង់ជាតិនិងទង់សាសនាទាំងឡាយត្រងត្រាតពេញក្នុងវត្ត បានបក់រវិចរគ្នា ហាក់ដូចជាសំដែងសេចក្ដីអបអរសាទរ ចំពោះពិធីបុណ្យ ។ យុវជនទាំងអស់ដែលស្នាក់អាស្រ័យនៅវត្តសាកវ័នតេជោ ព្រមទាំងពួកពុទ្ធបរិស័ទចំណុះជើងវត្ត បាននាំគ្នាទៅឈរមើរដេរដាសនៅមុខវិហារ ដើម្បីត្រៀមខ្លួនចាំធ្វើគារវកិច្ចចំពោះសម្ដេចព្រះបិតាឯករាជ្យជាតិរបស់ខ្លួន ។

នៅវេលាម៉ោង ៨ ឥស្សរជនជាន់ខ្ពស់ទាំងឡាយ នៅក្នុងព្រះរាជ-

នាទី ទាំងស៊ីវិលទាំងទាហាន ដែលមានជាអាទិ៍គឺ សម្ដេចដហ្វាក់ង ប៉ែន-នុត ឯកឧត្តម អ៊ឹង-ហ៊ុងសាធ ប្រធានរដ្ឋសភា អ្នកអង្គម្ចាស់ នរោត្តម ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ អ្នកអង្គម្ចាស់នរោត្តម-កន្តុល នាយករដ្ឋមន្ត្រី ឯកឧត្តម សឺន-សាន ឧបនាយករដ្ឋមន្ត្រីនិងជាទីប្រឹក្សាផ្ទាល់ព្រះអង្គសម្ដេចព្រះប្រមុខរដ្ឋ ឯកឧត្តម សាន-យុន អគ្គនាយកនៃក្រសួងនានា ក្នុងព្រះបរមរាជវាំង ឯកឧត្តម មៀច-គន់ ព្រះរាជប្រតិភូប្រចាំមន្ទីររាជសហករណ៍ ឯកឧត្តម ទេព ផន ឯកឧត្តម គូ-រុន ឯកឧត្តម ទ្រិញ-ហ៊ញ បានស្ដេចយាងនិងអញ្ជើញជាបន្តបន្ទាប់គ្នា មករួបរួមក្នុងពិធីបុណ្យដ៏មហោឡារិកនេះ ។

នៅវេលាម៉ោង ៩,២០ សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជថ្នាក់ទី ១ សម្ដេចព្រះសុគន្ធាធិបតី ព្រះសង្ឃរាជថ្នាក់ទី ២ និងសម្ដេចព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា យាងនិងនិមន្តមកដល់ ដោយមានព្រះរាជាគណៈ ឋានានុក្រមចំនួន ៣៥អង្គ នៅរង់ចាំធ្វើការ-កិច្ច ថ្វាយចំពោះសម្ដេចព្រះសង្ឃរាជផង ។

នៅវេលាម៉ោង ៩ និង ៣០ នាទី សម្ដេចព្រះប្រមុខរដ្ឋ ដោយមានអស្សរុះជនជាន់ខ្ពស់ជាព្រះរាជបរិពារតាមហែហមផង បានស្ដេចយាងមកដល់, ទាហានធ្វើវន្ទារុង ថ្វាយជាព្រះកិត្តិយស, នារីប្រូបថ្វាយបាចផ្កា យុវនយុវតីទាំងឡាយច្រៀងបទថ្វាយ ព្រះតេជៈជ័យ, ព្រះសង្ឃ ៣៨ អ



បណ្ណាល័យ នៅវត្តសារាវ័នតេជោ ភ្នំពេញ ។

ស្វាធ្យាយជយន្តោ . . . ប្រសិទ្ធីពរថ្វាយព្រះជោគសួស្ដីសិរីមង្គលមហា ប្រសើរ ៗ បន្ទាប់មក ព្រះវិន័យធរ អ៊ុម-ស៊ុម ជាតំណាងព្រះធម្មឃោ-សាចារ្យ ចៅអធិការ ថ្លែងសុន្ទរកថារៀបរាប់អំពីបុព្វហេតុ និងវត្ថុបំណង នៃការស្ថាបនាបណ្ណាល័យ (ដែលចុះជូនក្នុងទំព័រខាងមុខ) ។

លុះចប់សុន្ទរកថាព្រះវិន័យធរ អ៊ុម-ស៊ុម ហើយ សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះសុន្ទរកថា យ៉ាងពីរោះក្បោះក្បាយ ហើយដែលមានសារៈសំខាន់ក្រៃលែង ជាពិសេសព្រះអង្គមានព្រះរាជហឫទ័យព្រួយបារម្ភយ៉ាងខ្លាំង ចំពោះកូនចៅកសិកររបស់ព្រះអង្គ ដោយហេតុឆ្នាំនេះទឹកភ្លៀងពុំសូវបរិបូណ៌ ៗ បន្ទាប់ពីព្រះរាជសុន្ទរកថានៃសម្ដេចព្រះប្រមុខរដ្ឋមក សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ សុំឆ្លៀតព្រះរាជពានព្រះរាជឱកាស សូមឲ្យអ្នកឧកញ៉ាទ្រិញ-ហ៊ាញ អនុរដ្ឋលេខាធិការក្រសួងធម្មការ ធ្វើសារាចរបង្គាប់ទៅគ្រប់វត្តទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យរៀបចំធ្វើពិធីទេសនាមហាជាតកព្រមគ្នាក្នុងថ្ងៃមួយ បួងសួងសូមឲ្យមានទឹកភ្លៀងបរិបូណ៌ ដើម្បីឲ្យកសិករអ្នកស្រែចំការទាំងឡាយបានធ្វើផលដំណាំផ្សេង ៗ មានស្រូវជាដើម បានផលគ្រប់ ៗ គ្នា ។ សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ទទួលព្រះអំណរគុណ ហើយមានព្រះរាជហឫទ័យរីករាយយ៉ាងក្រៃលែង ៗ បន្ទាប់មក សម្ដេចព្រះប្រមុខរដ្ឋទ្រង់ថ្វាយត្រៃចីវរ ចំពោះសម្ដេចព្រះសង្ឃរាជទាំង ២ ព្រះអង្គ និងសម្ដេចព្រះ

ពោធិវង្ស ដែលគណៈកម្មការវត្តសាករ័នគេជា បានចាត់ចែងថ្វាយ ។ បន្ទាប់មកទៀត សម្តេចព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យបំពាក់គ្រឿងឥស្សរិយយស ចំពោះមន្ត្រីសង្ឃ ៦ រូបគឺ ព្រះធម្មឃោសាចារ្យ អ៊ុត-គុប ព្រះពុទ្ធឃោសាចារ្យ រាជ-គីន ព្រះគម្ពីរត្ថេរ ចក់-សេង ព្រះគ្រូវិសុទ្ធិវង្ស រស់ សំ ព្រះវិន័យធរ អ៊ុម-ស៊ុម ព្រះគ្រូទេពកោសល ហុក-អ៊ុម និងប្រធានគណៈកម្មការវត្ត ២ រូបគឺ លោក សឿ-សែម គហបតី តា ប៊ុនឡុង ដែលមានគុណបំណាច់ ក្នុងការស្ថាបនាបណ្ណាល័យនេះ ។ ទៀតក្នុងឱកាសនោះ មានលៀងភេសជ្ជៈ ដល់ភ្ញៀវទាំងឡាយគ្រប់ឋានៈ ។ សម្តេចព្រះប្រមុខរដ្ឋទ្រង់យាងកាត់ខ្សែបូ ជានិមិត្តរូបនៃការសម្ពោធន៍ រួចទ្រង់យាងទស្សនាបណ្ណាល័យថ្មីវិញ ទាំងខាងលើទាំងខាងក្រោម ដោយព្រះរាជហឫទ័យរីករាយក្រៃលែង រួចហើយព្រះអង្គទ្រង់ឡាយព្រះហស្តលេខាក្នុងសៀវភៅមាស ទុកជាអនុស្សាវរីយ៍ថា "សូមឲ្យនូវសេចក្តីសរសើរ គោរពនិងស្នេហា ។ ន-សីហនុ ប្រមុខរដ្ឋកម្ពុជា" មុននឹងព្រះរាជនិវត្តវិញ ព្រះអង្គមានព្រះរាជហឫទ័យសន្តោសប្រណី ដល់ក្មួយៗរបស់ព្រះអង្គ ទ្រង់ព្រះរាជទានត្រាស់បញ្ជាឲ្យយកខ្សែភាពយន្តមកបញ្ចាំង ជូនសាធារណជនទស្សនានៅវេលាយប់ ដើម្បីឲ្យមានសភាពអធិកអធម ក្នុងពិធីបុណ្យនោះផង ។ នៅវេលាម៉ោង ១១ និង ៤៥ នាទី



សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់គោរពព្រះតេជព្រះគុណ ព្រះធម្មឃោសាចារ្យ អ៊ុក—គុប ចៅអធិការវត្តសារាវ័នតេជោ ។

សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះរាជនិវត្តវិញ ដោយមានព្រះរាជបរិពារ ដដែលតាមដង្ហែព្រះអង្គ ។

នៅវេលាម៉ោង ១៩ ប្រារព្ធធ្វើពិធីចំរើនបរិត្ត ដោយបាននិមន្តព្រះសង្ឃព្រះរាជាគណៈ-ឋានានុក្រម ចំនួន ៤៦ អង្គ ដែលមានសម្តេចព្រះពោធិវង្សជាប្រធាន រួចហើយមានប្រគេនទេយ្យទានតាមទំនៀម ។ បន្ទាប់មកនៅវេលាម៉ោង ២០ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយទ្រង់ប្រោសព្រះរាជទានធម្មទេសនា ។ ព្រឹកឡើងថ្ងៃទី ១៦ សីហា វេរភត្តចំពោះព្រះសង្ឃ ១៨០ អង្គ ចំរើនមង្គលសូត្រមហាប្រសើរជាកិច្ចបញ្ចប់បុណ្យ ។

—X—

## សុន្ទរកថា

### សូមថ្វាយព្រះពរ

សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមទ្រង់ជ្រាប ។

ថ្ងៃនេះ ជាអភិលក្ខិតសម័យមួយ ជាថ្ងៃគួរកត់សំគាល់ទុកក្នុងចិត្តដ៏សំខាន់បំផុត ដែលវត្តសាកវ័នតេជោ មានភ័ព្វសំណាងល្អ បានរៀបចំទទួល សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍របស់ខ្លួន ។ នេះគឺជាលើក-

ដំបូងបំផុត ដែលវត្តសាភរ័ទគេជា បានទទួលមហាកិត្តិយស ត្រូវសរសេរចុះទុកក្នុងប្រវត្តិនៃវត្តនេះ ជាមហាមង្គលដ៏ឧត្តមតទៅ ។

ក្នុងនាមនៃព្រះសង្ឃវត្តនេះទាំងអស់ និងក្នុងនាមនៃអាត្មាភាព ជាតំណាងព្រះតេជព្រះគុណព្រះធម្មឃោសាចារ្យ ចៅអធិការ ព្រមទាំងក្នុងនាមនៃពុទ្ធបរិស័ទ ជើងវត្តនេះផង មានសេចក្តីត្រេកអររីករាយយ៉ាងរំភើប ប្លែកពីធម្មតា ក្រោយដែលបានទទួលដំណឹងប្រាកដថា ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រណី ស្តេចយាងមកកាន់ទីនេះ សមតាមបំណងហើយ ។

ជាបឋម អាត្មាភាពសូមព្រះរាជទាន ព្រះបរមរាជានុញ្ញាត សំដែងនូវសេចក្តីស្វាមីភក្តិឥតកម្រើក និងកតញ្ញូតាធម៌ ដ៏ស្មោះស្ម័គ្រឥតបំភ្លេចបាន ចំពោះព្រះមហាករុណាធិគុណនៃព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រណី បានស្តេចយាងមកជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យសម្ពោធបណ្ណាល័យ នៃវត្តសាភរ័ទគេជានេះ ។ បន្ទាប់អំពីនេះ អាត្មាភាពសូមព្រះរាជទានព្រះបរមរាជវរោកាស រៀបរាប់អំពីបុព្វហេតុដែលនាំឲ្យស្ថាបនាកើតបានជាបណ្ណាល័យនេះឡើង យ៉ាងសង្ខេបថ្វាយដូចតទៅនេះ ។



សម្ដេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់ថ្វាយត្រៃចីវរចំពោះសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ។

## សូមថ្វាយព្រះពរ

បុព្វហេតុដែលនាំឲ្យស្ថាបនាបណ្ណាល័យនេះ មាន ៣ យ៉ាងគឺ

១.ទីដែលស្ថាបនាបណ្ណាល័យនេះ កាលពីដើមឡើយជាកន្លែងកុដិ ២ ខ្នង ដែលអតីតសម្តេចព្រះសង្ឃនាយក ព្រះនាមប្រាក់-ហ៊ិន ជាចៅអធិការវត្តនេះ លោកសាងឡើង ។ កុដិនេះ មានសភាពចាស់ទ្រុឌទ្រោមណាស់ ។ កាលពីឆ្នាំ ១៩៦៣ ជាកាលសម័យដែលរាជការក្រុងកំពុងកែទម្រង់រៀបចំក្រុង ឲ្យបានស្អាតល្អប្រសើរ គ្រប់ទីកន្លែង គណៈកម្មការសង្ឃ និងអាត្មាជាតំណាងចៅអធិការ បានពិភាក្សាពីផែនការរៀបចំវត្តឲ្យបានស្អាតល្អប្រសើរ តាមកាលៈទេសៈ ក៏យល់ឃើញស្របគ្នាថា ត្រូវតែកែទម្រង់កុដិទាំង ២ ខ្នងនេះ ឲ្យមានសភាពសមរម្យប្រសើរឡើង ដើម្បីជាលំអដល់វត្ត ឲ្យសមនឹងលំអនៃព្រះរាជធានី ពីព្រោះកុដិទាំង ២ ខ្នងនេះនៅចំកណ្តាលវត្ត ហើយវត្តនេះ ក៏នៅចំកណ្តាលទីក្រុង ប៉ុន្តែ ពុំអាចធ្វើឲ្យសម្រេចក្នុងពេលនោះភ្លាម ៗ បាន ដោយហេតុកុដិនេះ ចាស់គ្រាំគ្រាខ្លាំងណាស់ ហើយបច្ច័យសំរាប់ប្រើប្រាស់ក៏មិនធួនល្មមដល់ការ ទើបព្រមព្រៀងគ្នាថា ត្រូវតែរុះរើហើយស្ថាបនាជាថ្មីឡើងវិញ ។ ជាកុសលល្អណាស់ ដែលវត្តសារាវ័នតេជោមានកំពូលសនាត្រូវបានទទួលមហាកិត្តិយស នៅឆ្នាំ ១៩៦៣ សម្តេចព្រះមហាក្សត្រីយានីបរមបពិត្រ ជាព្រះមាតាជាតិ ទ្រង់សព្វព្រះរាជហឫទ័យប្រោស

ប្រណី ត្រាស់បញ្ជាឲ្យបុគ្គលិកក្រុមពន្ធទូទៅ ដែលមានលោក ផន-ធុល ជានាយក នាំកឋិនទានព្រះរាជទ្រព្យហែចូលមកថត ចំពោះព្រះភិក្ខុសង្ឃវត្តនេះ បានបច្ច័យ បីសែនប្រាំម៉ឺនរៀល (៣៥០.០០០៛០០) ឆ្នាំក្រោយមកទៀត គឺឆ្នាំ ១៩៦៤ ទ្រង់ត្រាស់បញ្ជាឲ្យបុគ្គលិកក្រសួងហិរញ្ញវត្ថុ ដែលមានឯកឧត្តម ចាយ-ធុល ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នាំកឋិនទានព្រះរាជទ្រព្យហែចូល. ជាគ្រាទី ២ បានបច្ច័យមួយសែនប្រាំម៉ឺនរៀល (១៥០.០០០៛០០) រួមបច្ច័យកឋិនទានព្រះរាជទ្រព្យទាំង ២ ដង បានបច្ច័យប្រាំសែនរៀល (៥០០.០០០៛០០) ។ បច្ច័យទាំងប្រាំសែនរៀលនេះ ជាមធ្យោបាយបង្កើតគំនិតគណៈកម្មការសង្ឃ នឹកគិតឃើញស្របគ្នាថា បច្ច័យទាំងនេះទុកដូចជាព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ គួរតែយកទៅកសាងសមិទ្ធិអ្វីមួយ ទុកជាអនុស្សាវរីយ៍ ក្នុងវត្តសារាវ័នតេជោ ដើម្បីជាសម្បត្តិរបស់សង្ឃ កើតមានឡើងក្នុងសម័យសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋទ្រង់ជាប្រធាន ។

២- ដោយអនុវត្តតាមព្រះសង្ឃដីកា លេខ ៣១ណ. ចុះថ្ងៃទី ២០ មិថុនា ១៩៦៣ និងសារាចរ លេខ ៤ សស. ចុះថ្ងៃទី ១៥ មីនា ១៩៦៥ របស់ក្រសួងធម្មការ ស្តីពីការបង្កើតបណ្ណាល័យគ្រប់វត្ត ក្នុងព្រះរាជអាណាចក្រ ។



សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់អធិប្បាយពន្យល់អំពីសារប្រយោជន៍នៃបណ្ណាល័យ ប្រគេនព្រះសង្ឃជាទីសក្ការ ។

៣- ដោយអនុលោមតាមសេចក្តីអំពាវនាវ ពន្យល់ ណែនាំ នៃអ្នកចេកញ្ញា ម៉ែន-ឈុំ កាលនៅក្នុងឋានៈជាអនុរដ្ឋលេខាធិការ ក្រសួង-ធម្មការ ដឹកនាំបង្កើតឲ្យមានបណ្ណាល័យគ្រប់វត្ត ដើម្បីបណ្តុះសតិបញ្ញាស្មារតី ចរិយាព្រះសង្ឃ និងគ្រហស្ថជាពុទ្ធបរិស័ទ ឲ្យមានគំនិតល្អផ្តោះទៅរកមាគ៌ាតែមួយ គឺជាតិ សាសនា និងព្រះរាជបល្ល័ង្ក ។

អាស្រ័យបុព្វហេតុទាំង ៣ យ៉ាង ដូចរៀបរាប់ថ្វាយដោយសង្ខេបខាងលើនេះ ទើបគណៈកម្មការសម្រេចថា ត្រូវតែរុះរើកុដិ ២ ខ្នងនេះចេញ ហើយស្ថាបនាបណ្ណាល័យថ្មីមួយខ្នងនេះ ជំនួសឡើងវិញ ក៏បានខំប្រឹងប្រែង ខំខ្នងឥតទឹកគិតដល់ការនឿយហត់ឡើយ ដរាបទាល់តែបណ្ណាល័យនេះបានហើយស្រេចជាស្ថាពរ ។

សូមថ្វាយព្រះពរ

បណ្ណាល័យថ្មី ដែលតាំងនៅចំពោះព្រះភក្ត្រព្រះអង្គនេះ កើតឡើងដោយបច្ច័យរបស់គបរិទាន ព្រះរាជទ្រព្យផ្ទាល់ ឥតមានបច្ច័យដទៃចូលលាយឡំជាមួយឡើយ អស់តម្លៃ បួនសែន ប្រាំម៉ឺនពីរពាន់ ប្រាំបីរយសាមសិបប្រាំបួនរៀល (៤៥២.៨៣៩៛០០) ។ វត្ថុបំណងក្នុងការស្ថាបនាបណ្ណាល័យនេះ សំខាន់បំផុតមាន ៣ យ៉ាង គឺ :

១- ដើម្បីរក្សាទុកនូវរាជប្រពៃណី របស់មហាក្សត្រគ្រប់ព្រះអង្គ ឲ្យ

បានគង់វង្សជាស្ថាពរ ។

២- ដើម្បីជួយសំរាលព្រះភារៈកិច្ច នៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលព្រះអង្គមានព្រះរាជហឫទ័យមហាធ្ងន់ជានិច្ច ទៅក្នុងគ្រប់វិស័យកសាងជាតិ និងសាសនាជាដើម ឲ្យបានធូរស្រាល ។

៣- ដើម្បីប្រមូលរក្សាទុកនូវ : គម្ពីរបាលី អដ្ឋកថា ដីកា យោជនា បករណ៍ពិសេស ក្បួនខ្នាត ព្រមទាំងឯកសារផ្សេង ៗ ជាច្បាប់ព្រះពុទ្ធសាសនា ឲ្យបានគង់នៅឋិតថេរចិរកាលតទៅ ។

## សូមថ្វាយព្រះពរ

ព្រះសង្ឃគ្រប់រូប ព្រមទាំងពួកពុទ្ធបរិស័ទចំណុះវត្តសាកវ័នតេជោ មានឆន្ទៈដូចគ្នាតែមួយ សូមលើកបណ្ណាល័យទាំងមូលនេះ ថ្វាយចំពោះសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភកជាអម្ចាស់ សូមព្រះអង្គសំគាល់ថា ទុកដូចជាបានស្ថាបនាផ្ទាល់ព្រះអង្គ ហើយសូមរាប់បញ្ចូលក្នុងបញ្ជីសមិទ្ធិសង្គមរាស្ត្រនិយម ដែលមានព្រះអង្គទ្រង់ជាប្រធានតទៅ ។

ជាទីអវសាន អាត្មាភាព និងព្រះសង្ឃទាំងអស់ ហើយនិងពុទ្ធ-បរិស័ទទាំងឡាយ សូមលើកយកមហាកុសល ដែលកើតអំពីការស្ថាបនាបណ្ណាល័យនេះ ជាព្រះរាជកុសល ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានី បរមបពិត្រ ជាអម្ចាស់ជីវិត សូមមហាកុសលទាំងនេះ ជួយទ្រទ្រង់ព្រះ

អង្គ សូមព្រះអង្គប្រាសចាករោគ ភ័យ ឧបទ្រពគ្រប់ប្រការ សូមព្រះអង្គមានព្រះជន្មាទីឃាយុយឺនយូរ អតិរេកសៀស្រេត ក្រៃលែងជាងរយវស្សា គង់នៅជាព្រះបរមសុខ ក្នុងសិរីពេជសម្បត្តិ អស់កាលជាអង្វែងតទៅ ។

សូមថ្វាយព្រះពរជកុសល ចំពោះសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ព្រះប្រមុខរដ្ឋ សូមមហាកុសលទាំងនេះ តាមជួយទ្រទ្រង់បីបាច់ថែរក្សាព្រះអង្គ សូមព្រះអង្គមានជ័យជំនះឈ្នះអស់មារសត្រូវក្នុងសាកលលោក គ្រប់ពេលវេលា ទោះបីព្រះអង្គគង់នៅក្នុងប្រទេសក្តី យាងចេញទៅក្រៅប្រទេសក្តី សូមព្រះអង្គមានព្រះទីឃាយុយឺនយូរ ជាងរយវស្សា ដើម្បីជាមហាម្លប់ដ៏ត្រជាក់ត្រជុំ ឲ្យប្រជាពលរដ្ឋបានជ្រកតរៀងទៅ ។

សូមប្រទេសកម្ពុជា ឋិតនៅក្នុងសុខសន្តិភាព ជានិច្ចនិរន្តរ៍តរៀងទៅ!

សូមពិភពលោកទាំងមូល ប្រកបដោយសេចក្តីសុខ - ស្ងប់!

# ព្រះរាជដំណើរនៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ១
# ស្តេចយាងទៅកាន់ខេត្តបាត់ដំបង

លោក ឌឹក-តាម រៀបរៀង

សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដោយមានសម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សា និងសហជីវិន ទ្រិញ-វ៉ាញ អនុរដ្ឋលេខាធិការនៃក្រសួងធម្មការ ជូនព្រះរាជដំណើរផង ព្រះអង្គបានស្តេចយាងទៅកាន់ខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៩៦៤ តាមព្រះរាជទីនាំងអូតូរ៉ៃពិសេស ។

ក្នុងព្រះរាជដំណើរស្តេចយាងនេះ ចាប់ពីព្រះរាជដំណាក់រហូតដល់ស្ថានីយរាជអយស្ម័យយាន ឯកឧត្តម ទេព-ផន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ បានរៀបចំឲ្យមានក្បួនក្រុមព្រះនគរបាលជាតិអមសងខាងផ្លូវ ជូនព្រះរាជដំណើរផង ។ លោក ហ៊ូ-គឹមហាន់ ជាវិស្វករមគ្គសេតុ និងលោក ថោង-ហ៊ុន នាយកអាជីវកម្មនៃរាជអយស្ម័យយាន និងសហការី បានមកក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជ និមន្តស្តេចយាងកាន់បន្ទប់ពិសេស ដែលមានលំអដោយផ្កា នៅលើតុតូចមួយនៅក្នុងបន្ទប់នោះ ។ សហជីវិន ហ៊ូ-គឹមហាន់ និងសហជីវិន ថោង-ហ៊ុន បាននៅគាល់បំរើសម្តេចរហូតដល់ខេត្តបាត់ដំបង ។ នៅតាមផ្លូវសហជីវិនជានាយករាជអយស្ម័យយាន បានរៀបចំរាត់ចែងព្រះរាជបដិសណ្ឋារកិច្ចយ៉ាងគាប់ប្រសើរ ។

លោកបានរៀបចំក្រយា យ៉ាងប្រណីតថ្វាយព្រះអង្គ និងប្រគេនព្រះភិក្ខុជាព្រះរាជបរិពារទៀតផង ។

ព្រះរាជដំណើរបានប្រព្រឹត្តទៅយ៉ាងស្រួល ៗ ដល់ស្ថានីយពោធិសាត់ សហជីវិន ឌី-ទូច ចៅហ្វាយខេត្តពោធិសាត់ ព្រមទាំងចៅក្រសួងគ្រប់ផ្នែកជាសហការីរបស់លោក បានមករង់ចាំក្រាបថ្វាយបង្គំនៅទីនោះ ។ សម្ដេចព្រះសង្ឃរាជ ព្រះអង្គមានព្រះរាជបន្ទូលសំណេះសំណាលជាមួយមន្ត្រីខេត្ត អស់រយៈកាលប្រហែល ១៥ នាទី ។ សហជីវិន ឌី-ទូច ចៅហ្វាយខេត្ត ពោធិសាត់ បានថ្វាយផ្កាមួយធ្វើពីថ្មម៉ាបជានិមិត្តរូបនៃជោគជ័យក្នុងព្រះរាជដំណើរ ។ ព្រះអង្គបានប្រទានពរចំពោះមន្ត្រីទាំងអស់ឲ្យបានប្រកបដោយសេចក្ដីសុខគ្រប់ៗគ្នា ហើយទីបំផុតព្រះអង្គបានផ្ដាំសហជីវិនចៅហ្វាយខេត្តថា « សូមលោកកុំភ្លេចធ្វើម្ហូប ព្រោះនៅខេត្តពោធិសាត់នេះ មានអ្នកចេះធ្វើម្ហូបពីស្លឹកគ្រោកល្អណាស់ ហើយត្រូវតាមវេទនារបស់ជាតិខ្មែរផង» ។

ថេអ្នកបរចេញពីពោធិសាត់ សហជីវិន ឌី-ទូច ព្រមទាំងសហការីរបស់លោកខ្លះ បានជូនព្រះរាជដំណើរសម្ដេចហូតដល់ស្ថានីយស្វាយដូនកែវ ។ បដិសណ្ឋារកិច្ចដ៏ថ្លៃថ្លានេះសឲ្យឃើញថា សហជីវិនចៅហ្វាយខេត្តពោធិសាត់ បានយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនាគ្មានខ្ចោះ ដែលអាចឲ្យពុទ្ធបរិស័ទជាកូនចៅរបស់លោក ស្រឡាញ់រាប់អាន

ដោយបានឃើញចរិយាយ៉ាងថ្លៃថ្នូរនេះ ។ នៅលើថអុគូរៃ លោកបានគាល់ទូលសម្តេចពីការរីកចំរើននៅក្នុងខេត្តរបស់លោក រហូតដល់ពេលដែលលោកត្រូវចុះ ។

ក្រុះដល់ស្ថានីយមោងឫស្សី ព្រះតេជព្រះគុណ គង់-គូ ចាងហ្វាងនៃពុទ្ធិកវិទ្យាល័យបាត់ដំបង បាននិមន្តមកទទួលព្រះរាជដំណើរសម្តេចចូលក្នុងខេត្តបាត់ដំបង ។ អុគូរៃ បានដល់ស្ថានីយបាត់ដំបង សហជីវិន ទឹម-ង៉ួន ចៅហ្វាយខេត្តបាត់ដំបង ព្រមទាំងពុទ្ធបរិស័ទជាច្រើនកកកុញ បានរង់ចាំទទួលស្វាគមន៍នៃព្រះរាជដំណើរសម្តេច ។ ពីស្ថានីយទៅវត្តពោធិវាល មានក្បួនយ៉ាងគគ្រឹកគគ្រេងដង្ហែសម្តេចរហូតដល់វត្តនោះ ។

សម្តេចទ្រង់គង់នៅវត្តពោធិវាលអស់ពីររាត្រី ។ ព្រឹកដំបូង សម្តេចទ្រង់ព្រះរាជទានព្រះធម្មទេសនា ក្នុងឱកាសបុណ្យសម្ពោធសាមន្ទីរនៅវត្តពោធិវាល ។

នៅពេលដែលសម្តេចទ្រង់ព្រះរាជនិវត្តមកកាន់ព្រះរាជធានីភ្នំពេញ ក៏មានក្បួនដង្ហែដូចកាលដែលសម្តេច ស្តេចយាងដែរ ។ នៅលើអុគូរៃពិសេស សហជីវិន ថោង-ហ៊ុន នាយកអាជីវកម្មនៃរាជអយស្ម័យយាន បានរៀបចំព្រះរាជដំណើរត្រូវជាទីពេញចិត្ត និងគួរយកគម្រាប់ ។ នៅលើអុគូរៃ លោកបានគាល់សម្តេចយ៉ាងគោរព ហើយទទួលព្រះរាជបដិសណ្ឋារកិច្ចគ្រប់បែប ដែលសម្តេចទ្រង់សព្វព្រះរាជហឫទ័យ ។

នៅតាមផ្លូវមកដល់ស្ថានីយមោងឫស្សី ឧបាសក-សិកា នាំជង្វាយជាច្រើន មានក្រយាកញ្ចប់ជាច្រើនយកមកថ្វាយសម្តេច ។

ព្រះរាជដំណើរបានមកដល់រាជធានីភ្នំពេញ ឯកឧត្តម ទេព-ជន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ បានរៀបចំព្រះរាជដំណើរដូចកាលដែលព្រះអង្គស្តេចយាងចេញពីព្រះរាជដំណាក់ដែរ ដោយមានក្បួនក្រុមព្រះនគរបាលជាតិ ហែជូនព្រះរាជដំណើរមកកាន់ ព្រះរាជដំណាក់វត្តឧណ្ណាលោមវិញ ដោយព្រះសុវត្ថិភាព ។

(លេខក្រោយយើងនឹងចុះជូននូវសោរមន្ទីរនៅវត្តពោធិវ៉ាល)